

# អ្នកដំណើរដែលជួយរក្សាសុវត្ថិភាពកុមារ

## របាយការណ៍ផលិតដោយគម្រោងកុមារភាព ផ្នែកបង្ការ

Australian Aid
University of Western Sydney
World Vision

សូមឧទ្ទិសស្នាដៃរបាយការណ៍នេះជូនចំពោះកុមារដែលយើង
បំរើការងារជូនក្នុងប្រទេស កម្ពុជា ឡាវ ថៃ និង វៀតណាម

**អ្នកដំណើរដែលជួយរក្សាសុវត្ថិភាពកុមារ**

ISBN: 978-0-9874441-8-9
រក្សាសិទ្ធិ © ឆ្នាំ ២០១៣ ដោយអង្គការទស្សនៈពិភពលោក

*ផ្នែកណាមួយនៃឯកសារនេះអាចត្រូវបានផលិតឡើងវិញដោយសេរីតែត្រូវបញ្ជាក់ប្រភពឯកសារត្រឹមត្រូវ។*

www.childsafetourism.org
childsafetourism@wvi.org

ការស្រាវជ្រាវសម្របសម្រួលដោយ Aarti Kapoor, Afrooz Kaviani Johnson, និង Verity Kowal, ក្នុងគម្រោងកុមារភាពផ្នែកបង្ការរបស់អង្គការទស្សនៈពិភពលោក។ ការស្រាវជ្រាវត្រូវបានធ្វើឡើងដោយ Dr Amie Matthews, មកពីសាកលវិទ្យាល័យ University of Western Sydney។ របាយការណ៍សរសេរដោយ Dr Amie Matthews និងកែសម្រួលដោយ Aarti Kapoor, Afrooz Kaviani Johnson, និង Verity Kowal។ រចនាដោយ Cam Vien Ha។ រចនាជាភាសាខ្មែរដោយក្រុមហ៊ុន **Rachna Design**។

រូបថតដោយ៖ អង្គការទស្សនៈពិភពលោក / Vannith Touch, Albert Yu, Vichheka Sok, Xuan Thiem Le, Jon Warren។

ផ្នែកបង្ការនៃគម្រោងកុមារភាព គឺជាការផ្តួចផ្តើមគំនិតរបស់រដ្ឋាភិបាលអូស្ត្រាលី តាមរយៈក្រសួងការបរទេស និងពាណិជ្ជកម្ម។ ទស្សនៈដែលត្រូវបានស្តែងចេញក្នុងការបោះពុម្ពផ្សាយនេះ គឺជាទស្សនៈរបស់អ្នកនិពន្ធ ហើយពុំចាំបាច់ត្រូវតែជាទស្សនៈរបស់រដ្ឋាភិបាលអូស្ត្រាលីនោះឡើយ។



# អ្នកដំណើរដែលជួយរក្សាសុវត្ថិភាពកុមារ

របាយការណ៍ផលិតដោយគម្រោងកុមារភាព ផ្នែកបង្ការ

# សេចក្ដីថ្លែងអំណរគុណ

គម្រោងកុមារភាព ផ្នែកបង្ការ សូមថ្លែងអំណរគុណចំពោះ Dr Amie Matthews និងសាកលវិទ្យាល័យ Western Sydney ដែលបានធ្វើការស្រាវជ្រាវ និងសរសេរព្រាងរបាយការណ៍នេះ។

សូមអរគុណចំពោះអ្នកឆ្លើយតបការស្ទាបស្ទង់មតិ និងអ្នកចូលរួមក្នុងការសម្ភាសន៍ជាច្រើននាក់ ដែលបានបរិច្ចាគពេលវេលារបស់ពួកគេដោយក្ដីសប្បុរស ដើម្បីចូលរួមក្នុងការស្រាវជ្រាវនេះ។

គម្រោងកុមារភាព ផ្នែកបង្ការ ក៏សូមបង្ហាញការដឹងគុណ ចំពោះអាជីវកម្មខាងក្រោម ដែលបានគាំទ្រការស្រាវជ្រាវរបស់យើងតាម រយៈការចែកទម្រង់ស្ទាបស្ទង់មតិទៅដល់អតិថិជនរបស់ខ្លួន។ កិច្ចខិតខំប្រកបដោយការសហការរវាងវិស័យទាំងអស់ គឺចាំបាច់ណាស់ ដើម្បីសម្រេចបាននូវសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងដើម្បីធានាឲ្យបានថា កុមារមានសុវត្ថិភាពពីគ្រោះថ្នាក់នានា នៅក្នុងទីកន្លែងគោលដៅទេសចរណ៍។




**Intrepid Travel**
**Aloft Hotel**
**Holiday Inn Silom**
**Rembrandt Hotel**
**Navalai River Resort**
**Suk 11 Hostel**
**Legacy Suites**
**Golden Tulip Madison Suites**
**Ramada D'ma Makassan**
**Zaks Restaurant**
**Yellow Star 88 Travel Agency**
**Khurana Inn**
**Diamond House**
**May Kaidee Cooking School and Restaurant**
**So Cool Travel**
**HI Bangkok**

# មាតិកា


iv សេចក្តីថ្លែងអំណរគុណ

vi ការពន្យល់អត្ថន័យប្រយោគសំខាន់ៗ

2 សង្ខេបរបាយការណ៍

4 សាវតានៃការសិក្សា

6 វត្ថុបំណង និង វិធីសាស្ត្រនៃការស្រាវជ្រាវ

- 7 ដែនកំណត់

7 អ្នកចូលរួមក្នុងការស្រាវជ្រាវ

8 ការរកឃើញសំខាន់ៗ

- 8 ការយល់ដឹងរបស់អ្នកទេសចរអំពីការកេងប្រវ័ញ្ចលើកុមារក្នុងវិស័យទេសចរណ៍
- 10 ការជួបជាមួយកុមារ និងអន្តរកម្មរបស់អ្នកទេសចរជាមួយកុមារក្នុងមូលដ្ឋាន
- 13 កត្តាដែលជះឥទ្ធិពលលើប្រតិកម្មរបស់អ្នកទេសចរចំពោះការកេងប្រវ័ញ្ចលើកុមារ
- 14 ការឆ្លើយតបរបស់អ្នកទេសចរចំពោះការកេងប្រវ័ញ្ចលើកុមារ
- 17 តួនាទីរបស់ឧស្សាហកម្មទេសចរណ៍ និងរដ្ឋាភិបាល
- 19 ការឆ្លើយតបរបស់អ្នកទេសចរចំពោះសារស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

22 សេចក្តីសន្និដ្ឋាន

25 អនុសាសន៍

26 ឯកសារយោង

28 ឧបសម្ព័ន្ធ

- 28 1: លក្ខណៈប្រជាសាស្ត្ររបស់អ្នកចូលរួមក្នុងការស្រាវជ្រាវ
- 32 2: ទម្រង់ការស្ទាបស្ទង់មតិជាភាសាអង់គ្លេស
- 35 3: ប្រធានបទសម្រាប់ការសម្ភាសន៍ពាក់កណ្តាលរចនាសម្ព័ន្ធ

# ការពន្យល់អត្ថន័យប្រយោគសំខាន់ៗ

***"ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារ"*** រួមមានការរំលោភបំពានផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងការមិនអើពើ។ ជារឿយៗ កុមារដែលរងការរំលោភបំពាន តែងជួបប្រទះការរំលោភបំពានច្រើនមុខប្ញូករួមបញ្ចូលគ្នាក្នុងពេលតែមួយ។

***"កុមារ និងមនុស្សវ័យក្មេង"*** មានន័យថាជាមនុស្សទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំ។ យោងតាមច្បាប់អន្តរជាតិ "កុមារ" គឺជាជនទាំងឡាយណាដែលមានអាយុក្រោម ១៨ ឆ្នាំ។ ពាក្យ "មនុស្សវ័យក្មេង" សំដៅដល់អំឡុងពេលនៃការផ្លាស់ប្តូរឈានចេញពីកុមារភាព ឆ្ពោះទៅកាន់ភាពជាមនុស្សធំ ហើយជាទូទៅគឺរួមមានមនុស្សអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ។

***"សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍"*** គឺជាវិស័យទេសចរណ៍ ដែលទទួលស្គាល់ផលប៉ះពាល់របស់ខ្លួន លើកុមារ ( ទាំងដោយផ្ទាល់ និងដោយប្រយោល ) ហើយដើរតួនាទីយ៉ាងសកម្មក្នុងការចូលរួមវិភាគទាន ធ្វើឲ្យមានបរិដ្ឋានទេសចរណ៍ កាន់តែមានសុវត្ថិភាពសម្រាប់កុមារ។ សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ គឺជាផ្នែកមួយនៃ "ទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ" ដែលព្យាយាមកាត់បន្ថយផលប៉ះពាល់ អវិជ្ជមានផ្នែកសេដ្ឋកិច្ច បរិស្ថាន និងសង្គមដែលកើតចេញពីវិស័យទេសចរណ៍។

***"ទេសចរណ៍ផ្លូវភេទកុមារ"*** ពេលខ្លះពាក្យនេះ ត្រូវបានគេប្រើ ដើម្បីពិពណ៌នាអំពី ការរំលោភបំពានផ្លូវភេទលើកុមារ ដែលប្រព្រឹត្ត ដោយអ្នកទេសចរ អ្នកធ្វើដំណើរ ឬអ្នកតាំងទីលំនៅជាជនបរទេស នៅក្នុងប្រទេសមួយ ឬ ប្រទេសជាច្រើនដែលពួកគេទៅទស្សនា ឬរស់នៅ។ ពាក្យនេះមិនឆ្លុះបញ្ចាំងនូវលក្ខណៈខុសច្បាប់ និង លក្ខណៈប្រកប ដោយការរំលោភបំពាន របស់ទង្វើនេះទេ។ ហេតុនេះ គួរប្រើពាក្យ "ការកេងប្រវ័ញ្ចផ្លូវភេទកុមារនៅក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ" ។

'***"អ្នកទេសចរដែលរំលោភបំពានផ្លូវភេទកុមារ"*** ពេលខ្លះ ពាក្យនេះ ត្រូវបានគេប្រើប្រាស់ ដើម្បីពិពណ៌នាអំពីអ្នកទេសចរ អ្នកធ្វើដំណើរ ឬ អ្នកតាំងទីលំនៅជាជនបរទេស ដែលរំលោភបំពានផ្លូវភេទកុមារនៅក្នុងប្រទេសមួយ ឬ ប្រទេសជាច្រើន ដែលពួកគេទៅទស្សនា ឬរស់នៅ។ ពាក្យនេះ មិនឆ្លុះបញ្ចាំងនូវលក្ខណៈខុសច្បាប់ និងលក្ខណៈប្រកបដោយការរំលោភបំពានជាអ្នកប្រព្រឹត្តិនោះទេ។ ហេតុនេះ គួរប្រើពាក្យ "ជនល្មើសផ្លូវភេទកុមារ នៅក្នុងវិស័យទេសចរណ៍ និង ការធ្វើដំណើរ"។
"ទេសចរណ៍ទៅកាន់មណ្ឌលកុមារកំព្រា" គឺជាករណីដែលគ្រឹះស្ថាន "មណ្ឌលថែទាំកុមារ" អនុញ្ញាតិឲ្យ អ្នកទេសចរទៅទស្សនា និងពេលខ្លះទៀតឲ្យអ្នកទេសចរទៅធ្វើការងារស្ម័គ្រចិត្តជាមួយកុមារដែលរស់នៅទីនោះ។ ការថែទាំក្នុង "មណ្ឌល" ឬ "ស្ថាប័ន" គឺជាការថែទាំដែលមិនមានមូលដ្ឋាននៅតាមគ្រួសារ ក្នុងបរិយាកាសជាក្រុម។ មានចរន្ត ជាសាកលដែលព្យាយាមងាកចេញពីការថែទាំក្នុងមណ្ឌល ព្រោះមានភស្តុតាងបង្ហាញឲ្យឃើញថា ការថែទាំនៅតាមគ្រួសារ និងសហគមន៍ គឺជាជម្រើសដ៏ល្អបំផុតសម្រាប់កុមារ។ ការថែទាំក្នុងមណ្ឌល គួរតែជាជម្រើសចុងក្រោយបំផុត និងជាដំណោះស្រាយបណ្តោះអាសន្នប៉ុណ្ណោះ។ ថ្វីបើដូចនេះក្តី ក៏គេឃើញថា "មណ្ឌលកុមារកំព្រា" នៅក្នុងតំបន់ កំពុងមានចំនួនកើនឡើង។ មនុស្សមួយចំនួនលើកឡើងថាការ កើនឡើងនេះប្រហែលជាមានចំណងទាក់ទងជាមួយវិស័យទេសចរណ៍។ "ទេសចរណ៍ទៅកាន់មណ្ឌលកុមារកំព្រា" មានលក្ខណៈ បំផ្លិចបំផ្លាញចំពោះសុខមាលភាពសង្គម សុខមាលភាពផ្លូវកាយ និងផ្លូវចិត្តរបស់កុមារ។



# សង្ខេបអត្ថបទ

របាយការណ៍នេះ តំណាងឲ្យការរកឃើញសំខាន់ៗ ពីការស្រាវជ្រាវជាមួយអ្នកទេសចរ ក្នុងក្រុងបាងកក ប្រទេសថៃ នៅចន្លោះខែ មេសា ដល់ ខែ ឧសភា ឆ្នាំ ២០១៣។ ដោយស្ថាបនាបន្ថែមលើរបាយការណ៍ *សុវត្ថិភាពកុមារក្នុងវិស័យ ទេសចរណ៍៖ ទស្សនៈរបស់ភ្ញៀវទេសចរ* (អង្គការទស្សនៈពិភពលោក ឆ្នាំ ២០១២) ការសិក្សានេះ ពិនិត្យ ស៊ីជម្រៅ បន្ថែមទៀតទៅលើទស្សនៈរបស់ភ្ញៀវទេសចរ ស្តីពីការកេងប្រវ័ញ្ចលើកុមារផ្សារភ្ជាប់ជាមួយវិស័យទេសចរណ៍ក្នុងប្រទេស កម្ពុជា ឡាវ ថៃ និង វៀតណាម។ របាយការណ៍នេះ ក៏បានវាយតម្លៃទៅលើប្រតិកម្មរបស់អ្នកទេសចរ ចំពោះសារការប្រាស្រ័យទាក់ទងស្តីពីសុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍ផងដែរ។ អ្នកទេសចរសរុបចំនួន ២៦៨ នាក់ មកពីទូទាំងសកលលោកតំណាងឲ្យប្រភេទ អ្នកធ្វើដំណើរខុសៗគ្នា អាយុ យេនឌ័រ និងសាវតាសង្គមវប្បធម៌ផ្សេងៗគ្នា បានបំពេញការស្ទាបស្ទង់មតិ និងការ សម្ភាស។ ភ្ញៀវទេសចរដែលចូលរួម បានចំណាយពេលនៅក្នុងប្រទេសថៃរយៈពេលផ្សេងៗគ្នា ហើយអ្នកទេសចរជាច្រើនធ្លាប់បានធ្វើដំណើរ (ឬកំពុងធ្វើដំណើរ) នៅកន្លែងដទៃទៀតក្នុងតំបន់អាស៊ីអាគ្នេយ៍ និងតំបន់ផ្សេងៗទៀត។

## ការរកឃើញសំខាន់ៗពីការស្រាវជ្រាវបានបង្ហាញឲ្យឃើញថា៖

១. **អ្នកទេសចរភាគច្រើន (៧៦%) បានដឹងអំពីបញ្ហាការកេងប្រវ័ញ្ចលើកុមារផ្សារភ្ជាប់ជាមួយ វិស័យទេសចរណ៍ក្នុងតំបន់។** អ្នកទេសចរជាច្រើនបានចង្អុលបង្ហាញអំពីរូបភាពគោលដៅទេសចរណ៍ ដ៏អវិជ្ជមានពេលពួកគេពិភាក្សាអំពីបញ្ហានេះ។ អ្នកទេសចរបានពន្យល់ថា ពួកគាត់បានទទួលចំណេះដឹងនេះ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ វប្បធម៌បែបប្រជាប្រិយ និង/ឬពាក្យសម្តីពីមាត់មួយទៅមាត់មួយមុនពេលមកដល់កន្លែងទេសចរណ៍។ អ្នកទេសចរភាគច្រើនបានលើកឡើងអំពីការកេងប្រវ័ញ្ចលើកុមារក្នុងទម្រង់ជាសាធារណៈ និង ធ្ងន់ធ្ងរដូចជា "ការជួញដូរកុមារ" និង "ទេសចរណ៍ផ្លូវភេទកុមារ" ជាដើម។ អ្នកទេសចរមួយចំនួន ក៏បានផ្សារភ្ជាប់បញ្ហា ស្តីពីការកេងប្រវ័ញ្ចកុមារ ទៅនឹងប្រភេទជាក់លាក់នៃអ្នកទេសចរផងដែរ ដូចជា "អ្នករួមភេទជាមួយកុមារ" ឬ "អ្នកទេសចរផ្លូវភេទ" ជាដើម។ អ្នកទេសចរតិចតួចប៉ុណ្ណោះ ដែលបានដឹងអំពីលក្ខណៈពហុមុំនៃការរំលោភ បំពាន និង ដឹងពីអាកប្បកិរិយាផ្សេងៗរបស់អ្នកទេសចរ (ដូចជា ការឲ្យលុយកុមារសុំទាន ឬ "ទេសចរណ៍ទៅកាន់ មណ្ឌល កុមារកំព្រា") ជាដើម អាចធ្វើឲ្យកុមារ និងមនុស្សវ័យក្មេងមានភាពងាយរងគ្រោះចំពោះការកេងប្រវ័ញ្ច។

២. **អ្នកទេសចរស្ទើរទាំងអស់ (៩៥% នៃអ្នកចូលរួមការស្ទាបស្ទង់មតិ) បានជួបជាមួយកុមារក្នុងស្រុក ហើយទំនាក់ទំនងអន្តរបុគ្គលជាច្រើនបានធ្វើឲ្យអ្នកទេសចរមានអារម្មណ៍ក្រៀមក្រំ មានកំហុស បារម្ភ និងខកចិត្ត។** ក្នុងករណីមួយចំនួន អ្នកទេសចរបង្ហាញចំណាប់អារម្មណ៍ចង់ឲ្យខ្លួនឯង អាចមានសមត្ថភាពជួយកាន់តែច្រើនថែមទៀត ប៉ុន្តែក្នុងករណីមួយចំនួនទៀត ពួកគេបានបង្ហាញភាពអស់អែក ដោយសារពួកគេពុំឃើញមានអ្វីច្រើនត្រូវបាន ធ្វើឡើងនៅកម្រិតមូលដ្ឋានដើម្បីប្រយុទ្ធប្រឆាំងនឹងការកេងប្រវ័ញ្ចលើកុមារ។ អ្នកទេសចរជាច្រើនបានរងផលប៉ះពាល់ជាពិសេស នៅពេលពួកគេឃើញកុមារធ្វើការនៅតាមចិញ្ចើមថ្នល់ ឬសុំទាន។ អ្នកទេសចរមួយចំនួន ថែមទាំងបានបញ្ជាក់ថា ការធ្វើដំណើររបស់ពួកគេទៅកាន់តំបន់នេះពិតជាអាចប្រសើរជាងនេះ ប្រសិនបើពួកគេអាច មើលឃើញកុមារទទួលបានការការពារពីហានីភ័យនៃគ្រោះថ្នាក់ឲ្យបានកាន់តែប្រសើរ។

៣. **បទពិសោធន៍ការធ្វើដំណើរកន្លងមក និង/ឬសាវតាសង្គមវប្បធម៌របស់អ្នកទេសចរជះឥទ្ធិពលលើប្រតិកម្មរបស់ពួកគេ ចំពោះការកេងប្រវ័ញ្ចលើកុមារក្នុងវិស័យទេសចរណ៍។** អ្នកទេសចរមួយចំនួន មិនសូវភ្ញាក់ផ្អើលប៉ុន្មានទេពេលពួកគេមើលឃើញបញ្ហាទាំងអស់នេះ ដោយសារតែបទពិសោធន៍របស់ពួកគេក្នុងការធ្វើដំណើរនាពេលកន្លងមកនៅក្នុងតំបន់នេះ ឬនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍដទៃទៀត។ អ្នកទេសចរមួយចំនួនមកពីតំបន់អាស៊ីក៏មិនសូវបង្ហាញក្តីបារម្ភដែរ ជាពិសេសប្រសិនបើប្រទេសរបស់ពួកគេផ្ទាល់ ក៏ជួបប្រទះបញ្ហាប្រហាក់ប្រហែលគ្នាដែរនោះ។

៤. **អ្នកទេសចរចង់ជួយកុមារដែលពួកគេជឿថាកំពុងប្រឈមគ្រោះថ្នាក់ ប៉ុន្តែពួកគេជាច្រើនមានការភ័ន្តភាំងមិនដឹងថាតើមានសកម្មភាពអ្វីខ្លះដែលពួកគេអាចធ្វើបាន។** ការឆ្លើយតបរបស់អ្នកទសចរ ចំពោះសកម្មភាពដែលពួកគេគិតថាកុមារកំពុងរងការកេងប្រវ័ញ្ច ឬប្រឈមគ្រោះថ្នាក់នៃការកេងប្រវ័ញ្ច គឺកម្រជាការឆ្លើយតបលក្ខណៈដោយត្រង់ៗណាស់។ អ្នកទេសចរច្រើនតែវាយតម្លៃនៅក្នុងខ្លួនដោយយកចិត្តទុកដាក់ ថាតើមានវិធីអ្វីខ្លះដែលអាចឆ្លើយតបបានល្អបំផុត។ ការវាយតម្លៃរបស់ពួកគេផ្អែកលើកត្តាស្ថានភាព និងការឆ្លើយតបផ្អែកមនោសញ្ចេតនារបស់ពួកគេ ក៏ដូចជាផ្អែកលើគោលការណ៍ផងដែរ។ អ្នកទេសចរជាច្រើនមានការភ័ន្តភាំងមិនដឹងថាតើមានសកម្មភាពអ្វីខ្លះដែលពួកគាត់អាចធ្វើបានដើម្បីជួយកុមារ ហើយពួកគេបានសាកសួររកវិធីប្រកបដោយប្រសិទ្ធភាពដែលពួកគេអាចធ្វើបាន។

៥. **អ្នកទេសចរភាគច្រើនជឿជាក់ថា ឧស្សាហកម្មទេសចរណ៍ និង/ឬរដ្ឋាភិបាលក្នុងតំបន់ គួរធ្វើសកម្មភាពបន្ថែមទៀត ដើម្បីឆ្លើយតបបញ្ហាការកេងប្រវ័ញ្ចលើកុមារ រួមទាំងតាមរយៈការអប់រំ អ្នកទេសចរស្ដីពីវិធីដែលពួកគេអាចជួយបានផងដែរ។** អ្នកទេសចរ ចង់ចូលរួមវិភាគទានជាវិជ្ជមាន និងចង់បានព័ត៌មានបន្ថែមទៀត អំពីរបៀបដែលពួកគេអាចធ្វើបាន។ អ្នកទេសចរមួយចំនួនបានបង្ហាញចំណាប់អារម្មណ៍យ៉ាងខ្លាំង ដោយចង់ឲ្យមានព័ត៌មាន មិនត្រឹមតែនៅឯគោលដៅទេសចរណ៍ប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវមានព័ត៌មានពេលពួកគេនៅក្នុងប្រទេសរបស់ខ្លួនផងដែរ ដើម្បីឲ្យពួកគេអាចដឹងអំពីបញ្ហាបន្ថែមទៀត និងអំពីរបៀបឆ្លើយតបពេលពួកគេមកដល់។ អ្នកទេសចរជាច្រើនបាននិយាយថា ពួកគេទំនងជាចង់គាំទ្រអាជីវកម្មទេសចរណ៍ទាំងឡាយណា ដែលជម្រុញការអនុវត្តដើម្បីរក្សាសុវត្ថិភាពកុមារ (ជាពិសេស ប្រសិនបើគ្រឹះស្ថានទាំងនោះ មានតម្លៃសមរម្យ និងមានការត្រួតពិនិត្យត្រឹមត្រូវពីសំណាក់អង្គការខាងក្រៅ)។

៦. **អ្នកទេសចរបានឆ្លើយតបជាវិជ្ជមានចំពោះសម្ភារៈការទំនាក់ទំនង ស្ដីពីសុវត្ថិភាពកុមារក្នុងវិស័យ ទេសចរណ៍ ហើយសារនេះបានជះឥទ្ធិពលជាវិជ្ជមាន លើអាកប្បកិរិយារបស់អ្នកទេសចរ។** ភាគច្រើននៃអ្នកទេសចរ ត្រូវបានសម្ភាសមានអារម្មណ៍ថា ខ្លួនបានទទួលព័ត៌មានកាន់តែប្រសើរ បន្ទាប់ពីបានមើលសម្ភារៈយុទ្ធនាការ ដែលជាផ្នែកមួយនៃការសម្ភាស។ ពួកគេបាននិយាយថា  សម្ភារៈទាំងនេះ ពិតជាអាចជះឥទ្ធិពលខ្លះលើអាកប្បកិរិយាទេសចរណ៍របស់ពួកគេ នាពេលអនាគត។ អ្នកទេសចរដែលបានរាយការណ៍ថាធ្លាប់ឃើញសារប្រភេទនេះពីមុនមក មានអត្រានៃការធ្វើអន្តរកម្មជាមួយកុមារដែលអាចធ្វើឲ្យសាយភាយ ឬ ដែលអាចបង្កឲ្យកុមារមានភាពងាយរងគ្រោះ  ចំពោះការរំលោភបំពាន (ដូចជា “ទេសចរណ៍ទៅកាន់មណ្ឌលកុមារកំព្រា” ការឲ្យទានទៅកុមារសុំទាន ឬការទិញទំនិញ ពីកុមារលក់តាមចិញ្ចើមថ្នល់) កម្រិតទាបជាងអ្នកដែលមិនធ្លាប់បានឃើញសារនេះពីមុនមក។

## អនុសាសន៍សំខាន់ៗបួនដែលទទួលបានពីការរកឃើញ៖

១. ត្រូវផ្ដល់ព័ត៌មានបន្ថែមទៀតដល់អ្នកទេសចរ អំពីភាពងាយរងគ្រោះរបស់កុមារចំពោះការរំលោភបំពាន និងការកេងប្រវ័ញ្ចក្នុងវិស័យទេសចរណ៍។

២. ត្រូវផ្ដល់ព័ត៌មានច្បាស់លាស់ដល់អ្នកទេសចរអំពី របៀបដើម្បីក្លាយជាអ្នកទេសចរ ដែលជួយរក្សាសុវត្ថិភាពកុមារ។

៣. ត្រូវផ្ដល់ជម្រើសដល់អ្នកប្រើប្រាស់ និងជម្រើសដទៃទៀតដល់អ្នកទេសចរ ដែលអនុលោមតាមគោលការណ៍សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។

៤. ត្រូវទទួលស្គាល់ជាសាធារណៈ និងជម្រុញការយល់ដឹងថា សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍គឺជាការទទួលខុសត្រូវរួមគ្នារវាងរដ្ឋាភិបាល ឧស្សាហកម្មទេសចរណ៍ និងអ្នកធ្វើដំណើរ។

# សារតានៃការសិក្សា

វិស័យទេសចរណ៍ គឺជាឧស្សាហកម្មដែលរីកដុះដាលជាសកល។ ដោយឃើញមានកំណើនយ៉ាងធំធេងក្នុងអំឡុងប្រាំមួយទៅប្រាំពីរទសវត្សរ៍ចុងក្រោយនេះ អង្គការសហប្រជាជាតិសម្រាប់ទេសចរណ៍ពិភពលោក (UNWTO) បានប៉ាន់ប្រមាណថា ការមកដល់នៃភ្ញៀវទេសចរអន្តរជាតិទូទាំងពិភពលោកនឹងកើនឡើងជាមធ្យម ៣.៣% ក្នុងឆ្នាំចាប់ពីឆ្នាំ ២០១០ ដល់ ២០៣០ (UNWTO ឆ្នាំ ២០១៣)។ អង្គការ UNWTO (២០១៣) បានព្យាករណ៍ថា កំណើនទេសចរណ៍ខ្លាំង បំផុតនឹងត្រូវកើតឡើងក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិកក្នុងអំឡុង ២០ ឆ្នាំ ខាងមុខ (ដោយក្នុងនោះគេរំពឹងថា ការមកដល់នៃភ្ញៀវទេសចរនឹងកើនឡើង ៤.៩% ក្នុងមួយឆ្នាំ)។ ដូច្នេះ យើងអាចមើលឃើញលទ្ធភាពដែលវិស័យទេសចរណ៍ក៏ដូចជា ការពឹងផ្អែកលើវិស័យនេះនឹងបន្តកើនឡើងនៅក្នុងប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសថៃ និង ប្រទេសវៀតណាម។ ថ្វីបើការលូតលាស់នេះប្រាកដជាផ្តល់អត្ថប្រយោជន៍ផ្នែកសេដ្ឋកិច្ចដោយឥតសង្ស័យក្តី ប៉ុន្តែ ក៏មានឯកសារបញ្ជាក់យ៉ាងច្បាស់ថា ថ្វីបើទេសចរណ៍នាំយកអត្ថប្រយោជន៍ក្តី ក៏វាមានសក្តានុពលនាំមកនូវបញ្ហាផ្នែកវប្បធម៌ បរិស្ថាន និងសង្គមយ៉ាងច្រើនផងដែរ (សូមមើលជាឧទាហរណ៍ Mowforth & Munt, ឆ្នាំ ២០០៩ ; Scheyvens ឆ្នាំ ២០០២; Smith ឆ្នាំ ១៩៨៩; Telfer & Sharpley ឆ្នាំ ២០០៨)។ បញ្ហាទាំងអស់នេះ ត្រូវរីកកាន់តែធំថែមទៀត សម្រាប់បរិបទដែលមានការអភិវឌ្ឍទេសចរណ៍ យ៉ាងឆាប់រហ័សពុំបានគ្រោងទុក ពុំមានការតាមដាន និងពុំមាននិរន្តរភាព។ កង្វល់ដ៏សំខាន់មួយរបស់ផ្នែកបង្ការនៃគម្រោងកុមារភាព (ពិភាក្សាលម្អិតបន្ថែមទៀតនៅខាងក្រោម) គឺទាក់ទងនឹងលទ្ធភាពដែលកុមារនៅតាមតំបន់ទេសចរណ៍ អាចនឹងរងផលប៉ះពាល់ជាអវិជ្ជមាន។

គួរឲ្យសោកស្តាយ យើងអាចមើលឃើញចំណងទាក់ទងរវាងវិស័យទេសចរណ៍ និងការកេងប្រវ័ញ្ចលើកុមារ ជាពិសេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។ ភាពទាក់ទាញនៃចំណូលអាចមានន័យថា កុមារប្រហែលជាត្រូវចូលទៅធ្វើការក្នុងឧស្សាហកម្មទេសចរណ៍ មិនថាក្រោមការរៀបចំផ្នែកមុខរបរជាលក្ខណៈផ្លូវការ ឬក្រៅផ្លូវការក្តី និងនៅក្នុងលក្ខខណ្ឌដែលគ្រោះថ្នាក់ចំពោះសុខុមាលភាពផ្លូវកាយ ផ្លូវចិត្ត និងផ្លូវអារម្មណ៍របស់កុមារ (Bliss, 2006; UNICEF, 2012)។ បន្ថែមលើនេះទៀត កុមារដែលរកប្រាក់បានពីអ្នកទេសចរតាមទម្រង់ផ្សេងៗនៃពលកម្មកុមារ ច្រើនតែមិនសូវទៅសាលា និងប្រឈមកាន់តែខ្ពស់ចំពោះភាពងាយរងគ្រោះនៃការកេងប្រវ័ញ្ចទម្រង់ដទៃទៀត រួមទាំងការរំលោភបំពានផ្លូវភេទផងដែរ (Bliss, ឆ្នាំ ២០០៦; Keane ឆ្នាំ ២០០៦; Sanchez Taylor ឆ្នាំ ២០១០; UNICEF ឆ្នាំ ២០១២ )។

បន្ថែមលើពលកម្មកុមារ ការកេងប្រវ័ញ្ចផ្លូវភេទ គឺជាគ្រោះថ្នាក់ដ៏ធំមួយសម្រាប់កុមារនៅក្នុងតំបន់ទេសចរណ៍ ជាពិសេសនៅក្នុងផ្នែកផ្សេងៗនៃទ្វីបអាស៊ី អាមេរិកកណ្តាល អាមេរិកខាងត្បូង និងអាហ្វ្រិក (សូមមើលឧទាហរណ៍ Tepelus ឆ្នាំ ២០០៨; George & Panko ឆ្នាំ ២០១១; Sanchez Taylor ឆ្នាំ ២០១០)។ ភស្តុតាងប្រមូលបានពីករណី ដែលត្រូវបានកំណត់ឃើញ និងរបាយការណ៍ពីតំបន់អាស៊ីអាគ្នេយ៍ បានបង្ហាញឲ្យឃើញថា ជនល្មើសផ្លូវភេទកុមារជាអ្នកធ្វើដំណើរជារឿយៗ តែងផ្តោតគោលដៅលើកុមារ ដែលធ្វើការនៅតាមចិញ្ចើម ឬនៅក្នុងគ្រឹះស្ថានអាជីវកម្មក្រៅផ្លូវការផ្សេងៗក្នុងទីកន្លែងទេសចរណ៍ (សូមមើលជាឧទាហរណ៍ Keane ឆ្នាំ ២០០៦; UNICEF ឆ្នាំ ២០១២)។ បន្ថែមលើនេះទៀត ពួកគេក៏អាចមានលទ្ធភាព ចូលទៅរកកុមារងាយរងគ្រោះដោយមិនមាននរណាចាំឃ្លាំមើល តាមរយៈការធ្វើការក្នុងសាលារៀន ឬតាមស្ថាប័ន/មណ្ឌលថែទាំកុមារ។ ដោយសារកង្វះការត្រួតពិនិត្យ  និងការពារគ្រប់គ្រាន់ ពេលខ្លះឧស្សាហកម្មទេសចរណ៍ បានជួយសម្រួលឲ្យជនល្មើស មានលទ្ធភាពចូលទៅរកកុមារា និង កុមារី ហើយអាចជួយជម្រុញដល់ការកេងប្រវ័ញ្ចដោយមិនដឹងខ្លួន។ ចំណុចទាំងអស់នេះអាចកើតមាន ឡើងក្នុងអាជីវកម្មទេសចរណ៍ទ្រង់ទ្រាយធំ (ដូចជា សណ្ឋាគារ ភោជនីយដ្ឋាន ក្លឹបកំសាន្ត ផ្សារ និងបរិវេណសម្រាកលំហែរបស់អ្នកទេសចរ) ក៏ដូចជានៅក្នុងអ្វីដែលគេហៅថា “អាជីវកម្មទេសចរណ៍ប្រកបដោយការទទួលខុសត្រូវ” ឬ “ទេសចរណ៍បែបវប្បធម៌” ផងដែរ។ ឧទាហរណ៍ “ទេសចរណ៍ទៅកាន់មណ្ឌលកុមារកំព្រា”[១]  អាចធ្វើឲ្យកុមារមានភាព ងាយរងគ្រោះចំពោះផលប៉ះពាល់មិនមានសុខភាពល្អក្នុងទម្រង់ផ្សេងៗ រួមទាំងការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ (Guiney ឆ្នាំ ២០១២, Csaky ឆ្នាំ ២០០៩)។ ជាលទ្ធផល សូម្បីតែអ្នកទេសចរដែលមានចេតនាល្អក៏អាចធ្វើឲ្យកុមារ ប្រឈមនឹងគ្រោះថ្នាក់ដោយអចេតនាផងដែរ។

---

[១] សូមមើលការពន្យល់អត្ថន័យប្រយោគសំខាន់ៗ លើទំព័រ vi.

ក្នុងកិច្ចខិតខំប្រយុទ្ធប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទកុមារក្នុងកក្នុងវិស័យទេសចរណ៍ និងការធ្វើដំណើរ ក្នុងប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសថៃ និងប្រទេសវៀតណាម រដ្ឋាភិបាលអូស្ត្រាលីបានមានគំនិតផ្តួចផ្តើមបង្កើត គម្រោងមួយ ដែលមានឈ្មោះថា គម្រោងកុមារភាព ដែលមានពីរផ្នែកគឺការបង្ការ និង ការការពារ។ ការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) ក្នុងភាពជាដៃគូជាមួយ INTERPOL បានអនុវត្តផ្នែកការពារនៃគម្រោង កុមារភាព ដើម្បីពង្រឹង ការឆ្លើយតបផ្នែកការអនុវត្តច្បាប់។ ចំណែកអង្គការទស្សនៈពិភពលោក ជាអ្នកអនុវត្តផ្នែកបង្ការនៃគម្រោង កុមារភាព ដើម្បីឆ្លើយតបចំពោះកត្តានានាដែលធ្វើឲ្យកុមារមានភាពងាយរងគ្រោះ ចំពោះការកេងប្រវ័ញ្ចផ្លូវភេទក្នុងតំបន់ទេសចរណ៍។ ផ្នែកមួយនៅក្នុងការងារនេះ អង្គការទស្សនៈពិភពលោក បានបង្កើតការផ្តួចផ្តើមគំនិតមួយមានឈ្មោះថា សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ដោយសហការជាមួយវិស័យទេសចរណ៍ និងមានការចូលរួមពីរដ្ឋាភិបាល ឧស្សាហកម្មទេសចរណ៍ ក៏ដូចជាអ្នកធ្វើដំណើរផងដែរ។ យុទ្ធនាការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ មានគោលបំណងផ្តល់ព័ត៌មាន និងផ្តល់ភាពអង់អាចដល់អ្នកដែលធ្វើដំណើរមកកាន់តំបន់ឲ្យចេះធ្វើសកម្មភាពជាវិជ្ជមានដើម្បីការពារកុមារ។ អង្គការទស្សនៈពិភពលោក កំណត់និយមន័យពាក្យ "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" ថាជាទេសចរណ៍ដែល៖

១. ទទួលស្គាល់តួនាទី និងផលប៉ះពាល់ជាសក្តានុពលរបស់ខ្លួន លើការកេងប្រវ័ញ្ចកុមារ។

២. ទទួលខុសត្រូវក្នុងការកាត់បន្ថយផលប៉ះពាល់ប្រកបដោយគ្រោះថ្នាក់ (ដោយផ្ទាល់ ឬ ដោយប្រយោល) ចំពោះកុមារងាយរងគ្រោះឲ្យនៅជាអប្បបរមា។

៣. ដើរតួនាទីយ៉ាងសកម្មក្នុងការពង្រឹង និងរក្សាបរិស្ថានប្រកបដោយសុវត្ថិភាពសម្រាប់កុមារទាំងអស់។

ទីបញ្ចប់ សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ត្រូវបានគេមើលឃើញថា ជាការផ្តល់ដំណោះស្រាយប្រកបដោយនិរន្តរភាពរយៈពេលវែង ដើម្បីរក្សាសុវត្ថិភាពកុមារពីការរំលោភបំពានក្នុងវិស័យទេសចរណ៍។ សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ គឺជាសមាសធាតុដ៏សំខាន់ក្នុងការអភិវឌ្ឍឧស្សាហកម្មទេសចរណ៍ឲ្យកាន់តែមាននិរន្តរភាព និងមានលក្ខណៈវិជ្ជមាន។

# វត្ថុបំណង និងវិធីសាស្ត្រនៃការស្រាវជ្រាវ

## វត្ថុបំណងសំខាន់ៗនៃការស្រាវជ្រាវគឺដើម្បី៖

១. ពិនិត្យលើការយល់ដឹងរបស់អ្នកទេសចរ ស្ដីពីការកេងប្រវ័ញ្ចលើកុមារក្នុងវិស័យទេសចរណ៍ និង ការឆ្លើយតបរបស់ពួកគេពេលជួបជាមួយកុមារនៅក្នុងតំបន់។

២. ស្វែងយល់ពីឥរិយាបទ និងការឆ្លើយតបរបស់អ្នកទេសចរ ចំពោះសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងថា តើសារទាំងនេះជះឥទ្ធិពលកម្រិតណាចំពោះអាកប្បកិរិយារបស់ពួកគេក្នុងនាមជាអ្នកទេសចរ។[២]

ដើម្បីឆ្លើយតបនឹងវត្ថុបំណងទាំងអស់នេះ និងដើម្បីបំពេញតាមអនុសាសន៍ឲ្យមានការស្រាវជ្រាវបន្ថែមទៀត ដែលមានក្នុងរបាយការណ៍ *សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍៖* ទស្សនៈរបស់អ្នកទេសចរ (អង្គការទស្សនៈពិភពលោក ឆ្នាំ២០១២) ការសិក្សាស្រាវជ្រាវ ដោយប្រើប្រាស់វិធីសាស្ត្រចម្រុះមួយ ក្នុងនោះរួមមានការស្ទាបស្ទង់មតិខ្លី ជាលាយលក្ខណ៍អក្សរ ការសម្ភាសស៊ីជម្រៅ និងការអង្កេតត្រូវបានធ្វើឡើង។ ផែនការការស្រាវជ្រាវ ត្រូវបានអនុម័តដោយគណៈកម្មការ សីលធម៌សម្រាប់ការស្រាវជ្រាវលើមនុស្ស របស់សាកលវិទ្យាល័យ Western Sydney ក្នុងខែ មីនា ឆ្នាំ ២០១៣។ ការស្រាវជ្រាវត្រូវបានធ្វើឡើងអនុលោមតាមនីតិវិធីការពារកុមាររបស់អង្គការទស្សនៈពិភពលោក និងជំនួយអូស្ត្រាលី។ នីតិវិធីទាំងនេះរួមមានដូចជាមានដំណើរការច្បាស់លាស់ដែលត្រូវគោរពតាម ក្នុងករណីមានអ្នកចូលរួមណាម្នាក់បង្ហាញប្រាប់អំពីករណីការរំលោភបំពានកុមារដល់អ្នកស្រាវជ្រាវ។ ពុំមានកុមារណាម្នាក់ចូលរួមក្នុងការស្រាវជ្រាវនេះទេ។ ការស្រាវជ្រាវត្រូវបានធ្វើឡើងក្នុងក្រុងបាងកក ប្រទេសថៃ រយៈពេលប្រាំមួយសប្ដាហ៍ក្នុងខែ មេសា ដល់ខែ ឧសភា ឆ្នាំ ២០១៣។ ក្រុងបាងកក ត្រូវបានជ្រើសរើសជាទីតាំងការស្រាវជ្រាវដោយហេតុថា ប្រទេសថៃគឺជាទីកន្លែងទេសចរណ៍ដ៏ធំជាងគេបំផុតមួយនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ (ទទួលបានភ្ញៀវអន្តរជាតិជាង ២២ លាននាក់ ក្នុងឆ្នាំ ២០១២)។ ក្រុងបាងកក គឺជាទីក្រុងប្រកទ្វារចូលទៅកាន់ប្រទេសថៃ ក៏ដូចជា មជ្ឈមណ្ឌលការធ្វើដំណើរទៅកាន់ផ្នែកដទៃទៀតក្នុងតំបន់ទាំងមូលផងដែរ។ ការធ្វើការសិក្សាក្នុងក្រុងបាងកកជួយសម្រួលឲ្យអាចទទួលបានគំរូអ្នកទេសចរទូលំទូលាយបំផុត ដោយគ្របដណ្ដប់អ្នកទេសចរ ដែលមានជាតិសាសន៍ អាយុ យេនឌ័រ និងប្រភេទទេសចរណ៍ផ្សេងៗគ្នាជាច្រើន។

មនុស្សសរុប ២៦៨ នាក់ បានចូលរួមនៅក្នុងការស្រាវជ្រាវនេះ តាមរយៈបន្សំនៃការស្ទាបស្ទង់មតិជាលាយល័ក្ខអក្សរ និងការសម្ភាសស៊ីជម្រៅ។ ទម្រង់ការស្ទាបស្ទង់មតិជាលាយល័ក្ខអក្សរត្រូវបានយកទៅចែកនៅតាមតំបន់មានសកម្មភាពទេសចរក្នុងទីក្រុង។ កិច្ចសម្ភាសពាក់កណ្ដាលរចនាសម្ព័ន្ធ ក៏ត្រូវបានធ្វើឡើងជាមួយអ្នកចូលរួម ដែលជ្រើសរើសឲ្យចូលរួមតាមរយៈការផ្សព្វផ្សាយពាណិជ្ជកម្ម និងតាមរយៈការចូលទៅរកដោយផ្ទាល់នៅឯទីតាំងទេសចរណ៍សំខាន់ៗ។ មនុស្សសរុបចំនួន ២០៩ នាក់ បានបំពេញទម្រង់ការស្ទាបស្ទង់មតិ ហើយមនុស្សចំនួន ៥៩ នាក់ បានផ្ដល់ការសម្ភាស (ក្នុងការសម្ភាសចំនួន ៣៤)។ ទាំងការស្ទាបស្ទង់មតិ និងការសម្ភាស ត្រូវបានធ្វើឡើងជាភាសាអង់គ្លេស ភាសាចិន ភាសាជប៉ុន និងភាសាកូរ៉េ (ក្នុងការសម្ភាសមានការជួយសម្រួលពីអ្នកបកប្រែ)។ ភាសាអាស៊ីទាំងបីក្រុមនេះត្រូវបានជ្រើសរើសជាពិសេស ក្នុងកិច្ចខិតខំដើម្បីស្ដាបនាឲ្យមានភាពជាតំណាងកាន់តែខ្ពស់ជាងការសិក្សាកាលពីឆ្នាំ ២០១២។ ភ្ញៀវជនជាតិចិន ជប៉ុន និងកូរ៉េគ្របដណ្ដប់ទីផ្សារទេសចរណ៍ធំជាងគេបំផុតនៅក្នុងតំបន់។[៣]

---

[២] អ្នកស្រាវជ្រាវក៏បានវិភាគលើការឆ្លើយតបរបស់អ្នកទេសចរចំពោះសម្ភារៈយុទ្ធនាការ *សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍* ផងដែរ។

[៣] ភ្ញៀវជនជាតិចិនគ្របដណ្ដប់ទីផ្សារទេសចរណ៍ធំជាងគេ (១២,៨% នៃភ្ញៀវទាំងអស់) បន្ទាប់មកគឺភ្ញៀវជនជាតិម៉ាឡេស៊ី (៨%) កូរ៉េ (៦,៣%) និងភ្ញៀវជប៉ុន (៥,៧%) នៅក្នុងប្រទេសទាំងបួននៃគម្រោងកុមារភាព ពោលគឺប្រទេសកម្ពុជា ប្រទេសឡាវ ប្រទេសថៃ និងប្រទេសវៀតណាម (ដោយផ្អែកលើស្ថិតិវិស័យទេសចរណ៍ឆ្នាំ ២០១២ ទទួលបានពីក្រសួងទេសចរណ៍ប្រទេសកម្ពុជា ស្ថានទូតឡាវប្រចាំប្រទេសថៃ ក្រសួងទេសចរណ៍ និងកីឡាប្រទេសថៃ និងក្រសួងវប្បធម៌ កីឡា និងទេសចរណ៍ប្រទេសវៀតណាម)។

## ដែនកំណត់

ដោយយោងទៅលើទំហំគំរូតូចត្រឹមតែ ២៦៨ នាក់ ការរកឃើញក្នុងការសិក្សានេះ មិនគួរត្រូវបានបកស្រាយ ថាជាការតំណាងឲ្យអ្នកទេសចរទាំងអស់មកកាន់តំបន់នោះឡើយ ថ្វីបើចំនួននេះពុំមែនជាចំនួនមិនគួរឲ្យកត់សម្គាល់ក្តី។ វិធីសាស្ត្រ ជ្រើសរើសអ្នកចូលរួមនៅនឹងកន្លែង ដែលបានជួយសម្រួលឲ្យអ្នកស្រាវជ្រាវអាចនិយាយជាមួយអ្នកទេសចរជារឿយៗតែងមានន័យថា អ្នកចូលរួមមានពេលវេលាតិចតួចដើម្បីចូលរួម។ ចំណុចនេះកាន់តែពិតថែមទៀត ចំពោះករណីនៃអ្នកចូលរួមជនជាតិអាស៊ី បូករួមជាមួយការពឹងផ្អែកលើអ្នកបកប្រែ ដែលពិតជាអាចកាត់បន្ថយលទ្ធភាពក្នុងការពន្លេចគុណភាពព័ត៌មានបន្ថែមទៀត។ បើគិតទៅលើពេលវេលា និងធនធានមានកំណត់ ការជ្រើសរើសយកទីក្រុងតែមួយពិតជាដំណើរការបានល្អ។ ទោះជាយ៉ាងនេះក្តី ការសិក្សាដែលមានលក្ខណៈទូលំទូលាយជាងនេះ នៅក្នុងប្រទេសទាំងបួន ដោយមានយុទ្ធនាការជ្រើសរើសអ្នកចូលរួមទូលំទូលាយជាងនេះ ប្រហែលជាផ្តល់លទ្ធផលនូវរូបភាពខុសប្លែកបន្តិចពីលទ្ធផលនៃការស្រាវជ្រាវលើកនេះ។ ទោះយ៉ាងណាក្តី និន្នាការ និងទម្រង់ដែលបានលេចឡើង មានលក្ខណៈដែលអាចទុកចិត្តបាន បើយោងទៅលើភាពត្រឹមត្រូវដែលស្តែងចេញ ដោយយើងអាចមើលឃើញថា ចំណុចសំខាន់ៗត្រូវបានលើកឡើងម្តងហើយម្តងទៀត ព្រមទាំងការរកឃើញដែលត្រួតស៊ីគ្នាជាមួយការរកឃើញនៅក្នុងការសិក្សា *សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍៖* ទស្សនៈរបស់ភ្ញៀវទេសចរ (អង្គការទស្សនៈពិភពលោក ឆ្នាំ ២០១២)។

# អ្នកចូលរួមក្នុងការស្រាវជ្រាវ

លក្ខណៈប្រជាសាស្ត្រនៃអ្នកចូលរួមក្នុងការស្រាវជ្រាវ មានលក្ខណៈទូលំទូលាយយ៉ាងខ្លាំង។ អ្នកចូលរួម សរុបមាន ៣៩ សញ្ជាតិ (រួមទាំងអ្នកមកពីតំបន់អាស៊ីប៉ាស៊ីហ្វិក អឺរ៉ុប និងអាមេរិក) យេនឌ័រ (៥៦% ជាស្ត្រី និង ៤៣% ជាបុរស) ក្រុមអាយុ ប្រភេទអ្នកធ្វើដំណើរ សាវតាការអប់រំ និងមុខរបរ (សម្រាប់ព័ត៌មានលម្អិតសូមមើលឧបសម្ព័ន្ធទី ១៖ *លក្ខណៈប្រជាសាស្ត្រនៃអ្នកចូលរួមក្នុងការស្រាវជ្រាវ*)។ អ្នកចូលរួមក៏បានចំណាយ រយៈពេលខុសៗគ្នានៅក្នុងតំបន់ផងដែរ។ អ្នកចូលរួមជាច្រើន បានធ្វើដំណើរទៅកាន់ប្រទេសច្រើនជាងមួយ នៅក្នុងមជ្ឈមណ្ឌលនៃការស្រាវជ្រាវនេះ (បន្ថែមទៅលើប្រទេសថៃ ៤៣% នៃអ្នកចូលរួមបានទៅកាន់ប្រទេសកម្ពុជា ១១% ទៅកាន់ប្រទេសឡាវ និង ៣៧% ទៅកាន់ប្រទេសវៀតណាម) ហើយក៏មានភ្ញៀវដែលធ្វើដំណើរច្រើនដងមកកាន់តំបន់នេះ ក្នុងចំនួនគួរឲ្យកត់សម្គាល់ផងដែរ (៤២% នៃអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិបានទៅប្រទេសថៃ ១១% ទៅកាន់ប្រទេសកម្ពុជា ៦% ទៅកាន់ប្រទេសឡាវ និង ១៨% ទៅកាន់ប្រទេសវៀតណាម គឺជាអ្នកដំណើរដែលបានទៅទស្សនាច្រើនជាងមួយលើកនៅប្រទេសទាំងនោះ)។

# ការរកឃើញសំខាន់ៗ

## អ្នកទេសចរភាគច្រើន បានដឹងអំពីបញ្ហាការកេងប្រវ័ញ្ចលើកុមារផ្សារភ្ជាប់ជាមួយវិស័យទេសចរណ៍ក្នុងតំបន់។

អ្នកទេសចរជាច្រើនបានបង្ហាញថា ពួកគេបានដឹងថា កុមារមួយចំនួនក្នុងតំបន់អាស៊ីអាគ្នេយ៍ គឺជាកម្មវត្ថុនៃការរំលោភបំពាន ឬការកេងប្រវ័ញ្ចក្នុងបរិបទទេសចរណ៍ (៧៥% នៃអ្នកឆ្លើយតបការស្ទាបស្ទង់មតិ និង ៨០% នៃអ្នកត្រូវបានសម្ភាស[៤])។ តាមធម្មតា អ្នកទេសចរច្រើននិយាយដល់ការកេងប្រវ័ញ្ចប្រភេទជាក់លាក់ណាមួយដូចជា (ដោយប្រើពាក្យសម្តីរបស់អ្នកចូលរួមផ្ទាល់) "ទេសចរណ៍ផ្លូវភេទកុមារ" "ការជួញដូរកុមារ" ឬ "ពលកម្មកុមារ"។ ភាគច្រើននៃអ្នកទេសចរបានដឹងអំពីបញ្ហាមុនពេលមកដល់តំបន់នេះ។ ពួកគេបានបង្ហាញថា ពួកគេធ្លាប់បានឮអំពីបញ្ហាទាំងនេះពីការនិយាយពី មាត់មួយទៅមាត់មួយ ពីការអប់រំផ្លូវការ តាមរយៈប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីដូចជា កាសែត និងភាពយន្តឯកសារជាដើម បានដឹងតាមរយៈប្រភពព័ត៌មានបែបវប្បធម៌ប្រជាប្រិយដូចជា ភាពយន្ត និងទូរទស្សន៍ ឬតាមប្រភពអ៊ីនធឺណែតដូចជា ប្លុក និងយុទ្ធនាការតាមបណ្តាញសង្គមជាដើម។

ថ្វីបើអ្នកទេសចរជាច្រើនបានលើកឡើងអំពី ទម្រង់ធ្ងន់ធ្ងរនៃការកេងប្រវ័ញ្ចលើកុមារ ដែលសាធារណៈជនបានដឹងយ៉ាងទូលំទូលាយក្តី ប៉ុន្តែមានអ្នកចូលរួមតិចតួចប៉ុណ្ណោះ ដែលបានបង្ហាញឲ្យឃើញនូវការយល់ច្បាស់អំពីលក្ខណៈរួមផ្សំនៃការរំលោភបំពាន ព្រមទាំងវិធីជាច្រើនបែប ដែលកុមារអាចនឹងមានភាពងាយរងគ្រោះ ចំពោះការកេងប្រវ័ញ្ច ក្នុងវិស័យទេសចរណ៍។ ខាងក្រោមនេះ គឺជាការពិភាក្សាជាមួយអ្នកចូលរួមជនជាតិបារាំងពីរនាក់ (ប្រុស អាយុ ៣៤ឆ្នាំ និងស្ត្រីអាយុ ២៧ឆ្នាំ) ដែលគូសបញ្ជាក់ឲ្យឃើញ ពីគំលាតផ្នែកចំណេះដឹងនេះ៖

| | |
|---|---|
| *អ្នកសម្របសម្រួល៖* | *តើអ្នកធ្លាប់បានឃើញករណីកុមាររងការកេងប្រវ័ញ្ច ឬទេ? ការកេងប្រវ័ញ្ចនេះមិនចាំបាច់ត្រូវតែជាការកេងប្រវ័ញ្ចផ្លូវភេទនោះឡើយ ព្រោះអ្នកបានបញ្ជាក់រួចហើយថា អ្នកមិនទំនងជាអាចមើលឃើញការកេងប្រវ័ញ្ចផ្លូវភេទនោះទេ ប៉ុន្តែ អ្វីដែលខ្ញុំចង់និយាយ គឺការកេងប្រវ័ញ្ចក្នុងទម្រង់ដទៃទៀត។* |
| *ស្ត្រី៖* | *ទេ ។* |
| *ប្រុស៖* | *ទេ តាមធម្មតាគឺទេ។* |
| *អ្នកសម្របសម្រួល៖* | *តើអ្នកធ្លាប់ជួបកុមារសុំទាន ឬសុំលុយ ឬទេ?* |
| *ប្រុស៖* | *អូ បាទធ្លាប់។* |
| *ស្រី៖* | *អូ ខ្ញុំធ្លាប់។* |

គំលាតគ្នានេះ ក៏ត្រូវបានគូសបញ្ជាក់ឲ្យឃើញនៅក្នុងរូបភាពទី ១ ដែលយើងនឹងពិភាក្សានៅផ្នែកខាងក្រោយទៀត។ ថ្វីបើ ៦៧% នៃអ្នកចូលរួមការស្ទាបស្ទង់មតិបានបង្ហាញថា ពួកគេពុំធ្លាប់ឃើញស្ថានភាពណាមួយនៃការរំលោភបំពានកុមារ ឬការកេងប្រវ័ញ្ចកុមារពេលពួកគេនៅក្នុងតំបន់នេះក្តី ប៉ុន្តែ ១៥% នៃអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិបានបញ្ជាក់ថា ពួកគេធ្លាប់ឲ្យលុយកុមារសុំទាន ២៧% និយាយថាពួកគាត់ធ្លាប់ទិញឥវ៉ាន់ពីកុមារដែលជាអ្នកលក់ ៣៣% និយាយថាពួកគាត់ធ្លាប់ឃើញកុមារធ្វើការក្នុងទីតាំង ឬគ្រឹះស្ថានទេសចរណ៍ និង ១៨% បាននិយាយថា ពួកគាត់ធ្លាប់ឃើញកុមារធ្វើការក្នុងគ្រឹះស្ថានកំសាន្តសប្បាយនាពេលយប់ដូចជា បារ និងក្លឹបរាត្រីជាដើម។ កាលដែលអ្នកទេសចរជាច្រើន ពុំបានកំណត់ស្ថានភាពទាំងអស់នេះថាជាស្ថានភាពមានសក្តានុពលក្នុងការកេងប្រវ័ញ្ច សរបញ្ជាក់ឲ្យឃើញថាអ្នកទេសចរមួយចំនួននៅមានការយល់ដឹងមានកម្រិតកំណត់ស្តីអំពីបញ្ហានេះ។ ជាលទ្ធផល ការយល់ឃើញទាំងនេះជះឥទ្ធិពលលើទស្សនៈរបស់អ្នកទេសចរចំពោះអាកប្បកិរិយារបស់ខ្លួនផ្ទាល់។

[៤] អ្នកត្រូវបានសម្ភាសចំនួន ៤៨ នាក់ ត្រូវបានសួរសំណួរនេះ។

និន្នាការមួយទៀត ដែលដើរស៊ីសង្វាក់គ្នាជាមួយនិន្នាការខាងលើនេះដែរ គឺនិន្នាការរបស់អ្នកធ្វើដំណើរ ដែលចូលចិត្តភ្ជាប់ការរំលោភបំពានទៅនឹងអ្នកទេសចរប្រភេទជាក់លាក់ណាមួយ ឬបើនិយាយឲ្យចំ គឺពួកគេចង់សំដៅលើអ្នកទេសចរដែលពួកគេច្រើនតែមិនយកខ្លួនទៅប្រឡាក់ប្រឡូសជាមួយ។ ឧទាហរណ៍ អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិអេស្ប៉ាញម្នាក់ (ប្រុសអាយុ ៤១ - ៤៥ ឆ្នាំ) បាននិយាយថា "Farangs"[៥] គឺ "ច្រើនតែ" ជាជនល្មើសផ្លូវភេទកុមារ។ ស្រដៀងគ្នានេះដែរ នៅពេលយើងសួរអំពីឧទាហរណ៍ស្តីពីករណីការរំលោភបំពានលើកុមារ អ្នកឆ្លើយតបការសម្ភាសជនជាតិអង់គ្លេសម្នាក់ (ដែលរស់នៅក្នុងក្រុងហុងកុង) មានយោបល់ថា៖

> *"មានអតិថិជនក្រុមខ្លះ ចូលចិត្តមកកាន់ [ទីតាំងទេសចរណ៍ជាក់លាក់ណាមួយ] ព្រោះកន្លែងនោះទាក់ទាញមនុស្ស ជនជាតិរបៀបនោះ។ជួនកាលអ្នកឃើញពួកគេនៅលើយាន្តជំនិះសាធារណៈជាមួយក្មេងស្រីក្នុងមូលដ្ឋាន យើងមិនដឹងថាក្មេងទាំងនោះអាយុប៉ុន្មានទេ ប៉ុន្តែមានអ្នកខ្លះ គឺជាកុមាររឿងនេះ គឺវាអាស្រ័យនៅត្រង់ថាតើអ្នកដាក់ បន្ទាត់ខ័ណ្ឌចែករវាងកុមារ និងមនុស្សធំនៅត្រង់ណាប៉ុន្តែប្រុសៗទាំងនោះប្រាកដជាមក ដើម្បីរំលោភបំពាន"។*
> (បុរសអ្នកត្រូវបានសម្ភាស ជនជាតិអង់គ្លេស អាយុ៤៦ ឆ្នាំ)

> **"មានក្មេងៗជាច្រើនក្រុមធ្វើការងារ ក្មេងខ្លះទៀតដែលមានជាងក្រុមមុន បន្តិចរកស៊ីលក់ផ្កាកូឡាប និងមាន ក្មេងស្រី ដែលផលិត និងលក់កងដៃ។ យោងតាមសម្តីស្ត្រីម្នាក់នេះបាន ឲ្យដឹងថា ពេលស្រីៗទាំងនោះគ្រប់ អាយុ១៨ឆ្នាំ ពួកគេនឹងក្លាយជា ស្រីពេស្យាចារ។"**
> (ស្ត្រីអ្នកត្រូវបានសម្ភាស ជនជាតិស៊ុយអ៊ែត អាយុ ១៩ឆ្នាំ)

ជាទូទៅ អ្នកចូលរួមជាច្រើនភ្ជាប់ទំនាក់ទំនងរវាងវិស័យទេសចរណ៍ក្នុងតំបន់ជាមួយការកេងប្រវ័ញ្ចកុមារ ដោយក្នុងករណីជាច្រើនពួកគេបានចង្អុលទៅកាន់រូបភាពអវិជ្ជមានធ្ងន់ធ្ងររបស់ទីតាំងទេសចរណ៍។ ឧទាហរណ៍៖

> *"ខ្ញុំបាននិយាយជាមួយក្មេងស្រីម្នាក់មកពីប្រទេសស៊ុយអែតជាអ្នកធ្វើការនៅក្នុងបារមួយកន្លែង [ក្នុងក្រុងឆ្នេរសមុទ្រទេសចរណ៍ដ៏មានប្រជាប្រិយមួយ] ហើយនាងបានប្រាប់ខ្ញុំថាមានក្មេងៗជាច្រើនក្រុមធ្វើការងារផ្សេងៗដូចជា មានក្មេងខ្លះដើររើសសំរាមនៅលើឆ្នេរខ្សាច់ មានក្មេងខ្លះទៀតដែលមានជាងក្រុមមុនបន្តិចរកស៊ីលក់ផ្កាកូឡាប និង មានក្មេងស្រីដែលផលិត និងលក់កងដៃ។ យោងតាមសម្តីស្ត្រីម្នាក់នេះបាន ឲ្យដឹងថា ពេលស្រីៗទាំងនោះគ្រប់អាយុ ១៨ ឆ្នាំ ពួកគេនឹងក្លាយជាស្រីពេស្យាចារ។ នាងធ្លាប់ជាមិត្តជាមួយ ក្មេងស្រីប៉ុន្មាននាក់ដែលជាអ្នកលក់ខ្សែដៃ បន្ទាប់មកនាងបានត្រឡប់ទៅផ្ទះរបស់នាងនៅប្រទេសស៊ុយអ៊ែតរយៈពេលមួយខែ ដល់ពេលនាងត្រឡប់មក វិញ [នាងនិយាយថា] ពួកគេ [ស្រាប់តែក្លាយជា] ស្រីពេស្យាចារ ហើយមកផឹកស៊ីនៅក្នុងបារ។ នាងពិតជារន្ធត់ខ្លាំងណាស់ចំពោះ រឿងនេះ.នៅពេលខ្ញុំបានឮដូច្នោះខ្ញុំមានអារម្មណ៍មិនស្រួលក្នុងចិត្តយ៉ាងខ្លាំង។ មានបុរសចាស់ៗ មកពីប្រទេសលោកខាងលិចជាច្រើន [ មកនៅក្រុងនោះដោយសារតែស្រីក្មេង ] ដែលជារឿង ធ្វើឲ្យខ្ញុំស្អប់ខ្ពើមយ៉ាងខ្លាំង។"* (ស្ត្រី អ្នកត្រូវបានសម្ភាស ជនជាតិស៊ុយអែត អាយុ ១៩ ឆ្នាំ)

បើគិតទៅលើចំណងទាក់ទង ដែលត្រូវបានចងក្រងជាឯកសារយ៉ាងច្បាស់លាស់ រវាងប្រព័ន្ធផ្សព្វផ្សាយវិស័យទេសចរណ៍ជាមួយការគិតស្រមៃរបស់អ្នកទេសចរ ការពិពណ៌នារបស់អ្នកទេសចរ ជាមួយកេរ្តិ៍ឈ្មោះរបស់គោលដៅទេសចរណ៍ ព្រមទាំងអាកប្បកិរិយារបស់អ្នកទេសចរ (សូមមើលជាឧទាហរណ៍ Crouch, Jackson & Thompson, ឆ្នាំ ២០០៥; Jenkins, ឆ្នាំ ២០០៣; Long & Robinson ឆ្នាំ ២០០៩) ចំណាប់អារម្មណ៍ទាំងនេះ (មិនថាផ្អែកលើការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ បទពិសោធន៍ផ្ទាល់ ឬពាក្យសំដីពីមាត់មួយទៅមាត់មួយក្តី) គឺមានលក្ខណៈគួរឲ្យកត់សម្គាល់យ៉ាងខ្ពស់។ ថ្វីបើរូបភាពទាំងនេះ ច្បាស់ជាពុំអាចរារាំងអ្នកទេសចរទាំងនោះមិនឲ្យទៅកាន់តំបន់នោះក្តី ប៉ុន្តែយូរៗទៅរូបភាពទាំងនេះអាចមានសក្តានុពលផ្តល់ផល ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់តម្រូវការរបស់អ្នកទេសចរ។

[៥] Farang គឺជាពាក្យថៃ ដែលគេប្រើដើម្បីពិពណ៌នាជនបរទេស ដើមកំណើតស្បែកស។

## អ្នកទេសចរស្ទើរទាំងអស់ បានជួបជាមួយកុមារក្នុងស្រុក ហើយទំនាក់ទំនងអន្តរបុគ្គលជាច្រើន បានធ្វើឲ្យអ្នកទេសចរមានអារម្មណ៍ក្រៀមក្រំ មានកំហុសបារម្ភ និងខកចិត្ត។

អ្នកទេសចរជាច្រើន បានរាយការណ៍ថាធ្លាប់មានអន្តរកម្មយ៉ាងទូលំទូលាយជាមួយកុមារ។ ៩៥% នៃអ្នកឆ្លើយតបការស្ទាបស្ទង់មតិ និងភាគច្រើននៃអ្នកត្រូវបានសម្ភាសនិយាយថា ពួកគាត់បានជួបជាមួយកុមារក្នុងមូលដ្ឋានក្នុងតំបន់ ទេសចរណ៍។ ៣២% នៃអ្នកត្រូវបានស្ទាបស្ទង់មតិបាននិយាយថា ពួកគាត់បាននិយាយ ឬលេងជាមួយកុមារក្នុងមូលដ្ឋាន ហើយ ៥% បានធ្វើការងារស្ម័គ្រចិត្តជាមួយកុមារក្នុងមូលដ្ឋាន ( សូមមើលរូបភាពទី ១ ខាងក្រោម ដែលជារូបភាពសង្ខេបរបស់អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ដែលបានជួបជាមួយកុមារក្នុងមូលដ្ឋាន )។ អ្នកត្រូវបានសម្ភាសជាច្រើនក៏បាននិយាយថាធ្លាប់បាន លេងជាមួយ ឬនិយាយជាមួយកុមារនៅទីសាធារណៈ ជាពិសេសគឺនៅតាមផ្លូវ (រួមទាំងធ្លាប់លេងជះទឹកដាក់គ្នាជាមួយក្មេងៗ ក្នុងអំឡុងពិធីបុណ្យ Songkran[៦]) ផងដែរ។ អ្នកទេសចរណ៍មួយចំនួនមានអារម្មណ៍ថា អន្តរកម្មទាំងនេះមានតម្លៃ និងគួរជាទីចងចាំខ្លាំងណាស់ ហើយថែមទាំងជាបទពិសោធន៍ដ៏ពិសេស ដែលបានធ្វើឲ្យពួកគេយល់ច្បាស់អំពីវប្បធម៌មូលដ្ឋានយ៉ាងពិតប្រាកដ[៧]។ សូមមើលយោបល់ខាងក្រោមជាឧទាហរណ៍៖

> *“ខ្ញុំចូលចិត្តជជែកជាមួយកុមារ ប៉ុន្តែខ្ញុំមើលឃើញស្ថានភាពរបស់ពួកគេគួរអាណិតខ្លាំងណាស់។ ខ្ញុំតូចចិត្តពេលឃើញកុមារនៅតាមផ្លូវ និងមានភពក្រីក្រខ្លាំង។ ខ្ញុំចង់ជួយពួកគេខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងម្តេច។”*
>
> (ស្ត្រី អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិអូស្ត្រាលី អាយុ ២៦ - ៣០ ឆ្នាំ)

*“ខ្ញុំរីករាយចំណាយពេលជាមួយពួកគេ [កុមារក្នុងមូលដ្ឋាន] សួរសំណួរ [អំពីជីវិតរបស់ពួកគេ] និងបង្រៀនពាក្យអង់គ្លេស ដល់ពួកគេ”។*

( ស្ត្រី អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិអូស្ត្រាលី អាយុ ២៦ - ៣០ ឆ្នាំ )

*"ខ្ញុំចូលចិត្តធ្វើអន្តរកម្មជាមួយក្មេងក្នុងមូលដ្ឋាន។ នេះគឺជា ចំណុចលេចធ្លោមួយនៅក្នុងវិស្សមកាលរបស់ខ្ញុំ”។*

( ស្ត្រី អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិញ៉ូវហ្ស៊ីលែន អាយុ ៤១ -៤៥ ឆ្នាំ )

ថ្វីបើអ្នកទេសចរមួយចំនួនមើលឃើញថា កុមារក្នុងមូលដ្ឋានមានភាព “រួសរាយ” និង “រីករាយ” ហើយមានអ្នកទេសចរមួយចំនួន ថែមទាំងនិយាយថា ការជួប និងជជែកជាមួយកុមារទាំងនោះគឺជាចំណុចលេចធ្លោមួយ នៅក្នុងការធ្វើដំណើររបស់គេក្តី ប៉ុន្តែមានអ្នកទេសចរមួយចំនួនទៀត បានរាយការណ៍ថាពួកគេមានអារម្មណ៍ក្រៀមក្រំ មានកំហុស ខកចិត្ត សោកស្តាយ និងរារែកចិត្ត ជាលទ្ធផលនៃអន្តរកម្មរបស់ពួកគេជាមួយកុមារ។ ការឆ្លើយតបច្រើនលើសលប់ចំពោះសំណួរដែលសួរថា *“តើអន្តរកម្មរបស់អ្នកជាមួយកុមារក្នុងមូលដ្ឋាន ធ្វើឲ្យអ្នកមានអារម្មណ៍ដូចម្តេច ?”* គឺមានលក្ខណៈជាអវិជ្ជមាន៖

*“មានក្មេងក្នុងមូលដ្ឋានខ្លះមកសុំទាននៅមុខសណ្ឋាគារ និងក្លឹបរាត្រី ជាហេតុធ្វើឲ្យខ្ញុំមានអារម្មណ៍ថាជារឿងខុសឆ្គងផ្នែកសង្គមខ្លាំងណាស់។ ខ្ញុំក៏បានឃើញក្មេងៗលក់ថ្នាំញៀន និងលក់ផ្លូវភេទយ៉ាងបើកចំហនៅតាមផ្លូវដែលជាទង្វើ គួរឲ្យរំខានចិត្តយ៉ាងខ្លាំង”។*

( ស្ត្រីអ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិបង់ក្លាដេស អាយុ ៣១ - ៣៥ ឆ្នាំ )

---

[៦] Songkran សំដៅដល់ការប្រារព្ធពិធីបុណ្យចូលឆ្នាំរបស់ថៃ នៅខែ មេសា។ មនុស្សចូលរួមក្នុងការប្រារព្ធពិធីនេះតាមរយៈការជះទឹកដាក់គ្នា (រួមទាំងមនុស្សមិនដែលស្គាល់ )។ ការប្រារព្ធពិធីបុណ្យចូលឆ្នាំប្រហាក់ប្រហែលគ្នានេះក៏ត្រូវបានធ្វើឡើងនៅទីកន្លែងដទៃទៀតក្នុងតំបន់នេះដែរ ប៉ុន្តែការសម្ភាសត្រូវបានធ្វើឡើងក្នុងក្រុងបាងកក ក្នុងអំឡុងពេល Songkran អ្នកត្រូវបានសម្ភាសជាច្រើនទើបតែបាន “ជះទឹកដាក់គ្នា” ថ្មីៗជាមួយអ្នកនៅក្នុងមូលដ្ឋាន។

[៧] ថ្វីបើយោបល់ទាំងនេះត្រូវបានធ្វើឡើងដោយឯករាជ្យពីគ្នាក្តី ប៉ុន្តែប្រហែលជាផ្អែកលើមូលដ្ឋាននេះហើយដែលប្រតិបត្តិករទេសចរណ៍មួយចំនួននៅក្នុងតំបន់ផ្តល់ឲ្យអ្នកទេសចរ ចូលរួមជាមួយមនុស្សធំ និងកុមារក្នុងមូលដ្ឋានតាមរយៈការស្នាក់នៅតាមផ្ទះប្រជាជន និងចុះទៅតាមសាលារៀន និងមណ្ឌលថែទាំកុមារផងដែរ នេះបើតាមការឲ្យដឹងពីអ្នកចូលរួមក្នុងការស្រាវជ្រាវមួយចំនួន។ ជារឿយៗ សកម្មភាពទាំងនេះត្រូវបានគេផ្សព្វផ្សាយទីផ្សារថាជា “បទពិសោធន៍ផ្នែកវប្បធម៌”។

*"ខ្ញុំចូលចិត្តជជែកជាមួយកុមារ ប៉ុន្តែខ្ញុំមើលឃើញស្ថានភាពរបស់ពួកគេគួរអោណិតខ្លាំងណាស់។ ខ្ញុំតូចចិត្តពេលឃើញកុមារនៅតាមផ្លូវ និងមានភាពក្រីក្រខ្លាំង។ ខ្ញុំចង់ជួយពួកគេខ្លាំងណាស់ ប៉ុន្តែខ្ញុំមិនដឹង ថាត្រូវធ្វើយ៉ាងម៉េច។"*

(ស្ត្រី អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិអូស្ត្រាលី អាយុ ២៦ - ៣០ ឆ្នាំ)

*"ខ្ញុំមានអារម្មណ៍ពិបាកចិត្តខ្លាំងណាស់នៅពេលឃើញក្មេងៗត្រូវធ្វើការងារ។"*

(ស្ត្រី អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិអ៊ីតាលី អាយុ ១៨ - ២០ ឆ្នាំ)

ដូចបានបញ្ជាក់រួចហើយថា រូបភាពទី ១ ខាងក្រោមបង្ហាញរូបភាពស្ដីពីប្រភេទនៃការជួប ជាមួយកុមារក្នុងមូលដ្ឋានរបស់អ្នកឆ្លើយតបក្នុងការស្ទាបស្ទង់មតិ ដែលរួមបញ្ចូលទាំងជួបជាមួយកុមារដោយពុំមាននរណាមើលខុសត្រូវនៅតាមផ្លូវ (៦០%) ធ្វើការនៅក្នុងគ្រឹះស្ថានទេសចរណ៍ (៣៣%) និងធ្វើការនៅក្នុងគ្រឹះស្ថានកំសាន្តសប្បាយនាពេលយប់ (១៨%)។ អ្នកត្រូវបានសម្ភាសជាច្រើនបានរាយការណ៍អំពីស្ថានភាពរបស់កុមារ ឬមនុស្សវ័យក្មេង ក្នុងលក្ខណៈប្រហាក់ប្រហែលនេះ ដែលបានធ្វើឲ្យពួកគេមានអារម្មណ៍មិនស្រួលចិត្តយ៉ាងខ្លាំង។ រឿងទាំងអស់នេះរួមមានដូចជា ករណីដែលពួកគាត់បានឃើញកុមារក្មេងៗធ្វើការ ឬសុំទាន ឬករណីដែលពួកគាត់ត្រូវបានគេលើកទឹកចិត្តឲ្យចូលទៅក្នុងបារ និងក្លឹបដើម្បីចូលរួមក្នុងឧស្សាហកម្មផ្លូវភេទដោយ ប្រហែលជាអាចមានអនីតិជនធ្វើការនៅក្នុងនោះ ហើយបុរសអ្នកត្រូវបានសម្ភាសពីរនាក់ធ្លាប់ទទួលការរំអុកឲ្យមានទំនាក់ទំនង ផ្លូវភេទយ៉ាងសកម្មពីស្ត្រីអនីតិជន (ដោយទាំងពីរនាក់សុទ្ធតែបានប៉ាន់ប្រមាណថា មានអាយុប្រមាណ ១២ - ១៥ ឆ្នាំ)។

## រូបភាពទី ១



បទពិសោធន៍ទាំងនេះ ជះឥទ្ធិពលយ៉ាងធំធេងចំពោះអ្នកទេសចរជាបុគ្គល ក៏ដូចជាទស្សនៈរបស់ពួកគេចំពោះទិសដៅទេសចរណ៍ទាំងនេះផងដែរ៖

*"[បទពិសោធន៍មួយរបស់ខ្ញុំគឺ] ក្មេងស្រីម្នាក់ព្យាយាមលក់ខ្លួនឲ្យខ្ញុំ។ ខ្ញុំបានបដិសេធយ៉ាងលឿនបំផុតតាមដែរខ្ញុំ អាចធ្វើបាន។ ខ្ញុំប្រាប់នាងថា ខ្ញុំមិនចាប់អារម្មណ៍ទេ។ ខ្ញុំប្រាប់នាង ឲ្យចេញឲ្យឆ្ងាយ ប៉ុន្តែខ្ញុំនៅតែមានអារម្មណ៍ញញើតយ៉ាងខ្លាំងអំពីបញ្ហានេះ ព្រោះមើលទៅនាងក្មេងខ្លាំងណាស់។ ខ្ញុំមានការភ្ញាក់ផ្អើល ព្រោះវាភ្លាមៗពេកព្រោះថាពេលនោះគឺជា [ពិធីបុណ្យចូលឆ្នាំថ្មី] ហេតុនេះ មនុស្សគ្រប់គ្នាសុទ្ធតែចេញមកតាមផ្លូវជះទឹកដាក់គ្នា ដូចនេះប្រសិនបើនរណាម្នាក់ចូលមកកេអ្នក អ្នកគិតថាវាគ្រាន់តែជាផ្នែកមួយនៃការកំសាន្តនោះ ប៉ុន្តែពេលនោះស្រាប់តែនាងមកកៀកខ្លួនខ្ញុំយ៉ាងខ្លាំង រួចប៉ះខ្លួនខ្ញុំ.នោះពិតជាបទពិសោធន៍ដ៏អាក្រក់ខ្លាំងណាស់។"*

(បុរស អ្នកត្រូវបានសម្ភាសជនជាតិ ហូឡង់ អាយុ ២២ ឆ្នាំ)

*"មនុស្សចេញក្រៅ និងផឹកទាល់តែស្រវឹងយ៉ាងខ្លាំង រួចពួកគេទាំងអស់សុទ្ធតែជាជនបស្ចឹមប្រទេស ក្រៅពីនោះ មានក្មេងស្រីក្នុងស្រុកមួយក្រុមធំអាយុប្រហែលជាក្រោម ១៨ ឆ្នាំ ដែលព្យាយាមទាក់ទាញចំណាប់អារម្មណ៍ បុរសៗនោះយ៉ាងខ្លាំងហើយមនុស្សប្រុសភាគច្រើនពុំដឹងថា អ្នកទាំងនោះគឺជាស្រីរកស៊ីនោះឡើយ។ នេះគឺជាផ្នែកមួយដែលធ្វើឲ្យខ្ញុំមិនចូលចិត្ត។ ក្រៅពីនោះ នៅមានក្មេងៗដែលមិនគេងពេលយប់ ដោយសារគេទៅសុំទាននៅម៉ោងដែលពួកគេគួរតែគេងលក់នៅឯផ្ទះ។ ជាការពិត ពួកគេមើលឃើញឱកាសរកលុយនៅខាងក្រៅ ប៉ុន្តែទង្វើទាំងអស់នេះសុទ្ធតែស្មោគគ្រោក។ខ្ញុំនឹងមិនត្រឡប់ទៅវិញទៀតទេ។"*

(ស្ត្រី អ្នកត្រូវបានសម្ភាសជនជាតិ ស៊ុយអ៊ែត អាយុ ១៩ ឆ្នាំ)

បន្ថែមលើអារម្មណ៍ខ្មើមអេីម ឬក្រៀមក្រំពេលជួបបែបនេះ អ្នកត្រូវបានសម្ភាសមួយចំនួន បាននិយាយពីអារម្មណ៍មានកំហុស អារម្មណ៍អាក្រក់ ដែលជាលទ្ធផល នៃការដែលពួកគេជួប (ប្រហែលជាទិដ្ឋភាពប្រចាំថ្ងៃ) ជាមួយកុមារក្នុងមូលដ្ឋាន៖

*"ខ្ញុំគិតថា មានរឿងមួយដែលតែងធ្វើឲ្យខ្ញុំមានអារម្មណ៍អាក្រក់ខ្លាំង គឺឧបមាថាពេលយើងកំពុងញ៉ាំហើយពួកគេ [កុមារ] ដើរមកកាន់តុរបស់យើង ហើយតាមធម្មតា វិធីរបស់យើងគឺយើងគ្រាន់តែមិនអើពើជាមួយពួកគេតែប៉ុណ្ណោះ។ ខ្ញុំគ្រាន់តែគិតថា សម្រាប់ក្មេងៗទាំងនោះ វាជារឿងដ៏អាក្រក់ខ្លាំងណាស់ចំពោះការឲ្យតម្លៃខ្លួនឯងរបស់ពួកគេ។ ពួកគេអាយុត្រឹមតែប្រាំមួយឆ្នាំ ហើយពួកគេព្យាយាមនិយាយជាមួយអ្នក... ជាពិសេសពេលអ្នកនិយាយថា "ទេ អត់ទេ! ទេ អត់ទេ!" ចំណែកពួកគេវិញព្យាយាមនិយាយថា "សូមអង្វរៗៗ!"។ នេះជារឿងគួរឲ្យតូចចិត្តណាស់ សម្រាប់មនុស្សមួយចំនួនដូចរូបខ្ញុំ ពេលឃើញនរណាម្នាក់ស្ថិតក្នុងស្ថានភាពដ៏អស់សង្ឃឹមបែបនេះ។ ប៉ុន្តែប្រសិនបើអ្នកមាន [លុយរាយ] សម្រាប់មនុស្សគ្រប់រូបដែលអ្នកចង់ឲ្យនោះ អ្នកប្រាកដជាត្រូវអស់លុយមួយធនាគារមិនខាន។"*

(ស្ត្រី អ្នកត្រូវបានសម្ភាស ជនជាតិអង់គ្លេស អាយុ ២៣ ឆ្នាំ)

*"ខ្ញុំមានអារម្មណ៍អាណិតអាសូរ និងមានអារម្មណ៍អាក្រក់ពេលខ្ញុំឃើញក្មេងៗសុំទាន និងលក់ឥវ៉ាន់នៅតាមផ្លូវប៉ុន្តែខ្ញុំមិនឲ្យ លុយទៅក្មេងៗសុំទាននោះទេ។ បើខ្ញុំឲ្យលុយក្មេងៗខ្ញុំប្រាកដជាមានអារម្មណ៍អាក្រក់មិនខានព្រោះខ្ញុំដឹងថាក្មេងៗទាំងនោះ ត្រូវឲ្យលុយទាំងនោះទៅពួកជើងកាងចិត្តអាក្រក់ ឬពួកម៉ាហ្វៀ។"*

(បុរស អ្នកបានត្រូវសម្ភាស ជនជាតិជប៉ុន អាយុ ៤២ ឆ្នាំ)

អ្នកទេសចរជាច្រើនក៏បានបង្ហាញក្តីបារម្ភ និងការស្រងំាកចិត្តដោយឃើញថា កុមារហាក់ពុំមានលទ្ធភាពទៅសាលារៀន និង/ឬមានក្តីបារម្ភអំពីបរិស្ថានមិនសមស្រប និងបរិស្ថានដែលមើលទៅហាក់មិនមានសុវត្ថិភាពដែលកុមារក្នុងមូលដ្ឋានកំពុងស្ថិតនៅ (ឧទាហរណ៍ ដោយពួកគេត្រូវធ្វើការនៅតាមផ្លូវនាពេលយប់ជាដើម)។ ឧទាហរណ៍ គូស្វាមីភរិយាវ័យក្មេងដែលធ្លាប់បានធ្វើ ដំណើរក្នុងតំបន់បាននិយាយថា នាយប់មួយ ពួកគេបានជួបក្មេងស្រីម្នាក់ ដែលបានព្យាយាមលក់ស្រាបៀរឲ្យពួកគាត់ នៅផ្សាររាត្រី។ នៅពេលសួរថា តើរឿងនេះបានធ្វើឲ្យពួកគាត់មានអារម្មណ៍ដូចម្តេច  អ្នកត្រូវបានសម្ភាសជាស្ត្រីបានលើកឡើងថា៖

*"[រឿងនេះបានធ្វើឲ្យខ្ញុំ] មានអារម្មណ៍ដូចជាចង់ឈឺ។ អ្នកចង់ឲ្យលុយ ឬឲ្យរបស់ទៅពួកគេញ៉ាំប៉ុន្តែអ្នកពុំអាចដឹងថាតើនរណានឹងបានអត្ថប្រយោជន៍តាមរយៈនេះឡើយ ហេតុនេះ អ្នកមិនដឹងថាត្រូវធ្វើយ៉ាងណានោះឡើយ។"*

(ស្ត្រី អ្នកត្រូវបានសម្ភាស ជនជាតិបារាំង អាយុ ២៧ ឆ្នាំ)

## បទពិសោធន៍ការធ្វើដំណើរកន្លងមក និង/ឬសាវតាសង្គមវប្បធម៌របស់អ្នកទេសចរជះឥទ្ធិពលលើប្រតិកម្មរបស់ពួកគេ ចំពោះការកេងប្រវ័ញ្ចលើកុមារក្នុងវិស័យទេសចរណ៍។

ការឆ្លើយតបក្នុងកិច្ចសម្ភាសស្នើឲ្យឃើញថា បទពិសោធន៍ការធ្វើដំណើរកន្លងមក (ជាពិសេសនៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍ) អាចជះឥទ្ធិពលលើទស្សនៈរបស់អ្នកទេសចរ និងការយល់ដឹងអំពីការកេងប្រវ័ញ្ចលើកុមារក្នុងវិស័យទេសចរណ៍។ ក្នុងករណីខ្លះ បទពិសោធន៍កន្លងមកមានឥទ្ធិពលខ្លាំង រហូតធ្វើឲ្យសូម្បីសកម្មភាពមួយចំនួនពាក់ព័ន្ធនឹងកុមារ ដែលនៅក្រៅនិយាមសង្គមរបស់អ្នកទេសចរផ្ទាល់ អាចប្រែក្លាយជារឿងធម្មតាទៅនៅក្នុងគំនិតរបស់អ្នកទេសចរ ដោយពួកគេចាត់ទុកថានេះជាផ្នែកមួយនៃបទពិសោធន៍ "ប្រទេសកំពុងអភិវឌ្ឍ"។ មួយវិញទៀត បទពិសោធន៍ទាំងអស់នោះ ត្រូវបានចាត់ទុកជាមោឃៈ ដោយសារតែស្ថានភាពនោះ "មិនសូវអាក្រក់" ដូចនៅកន្លែងផ្សេង។ យោបល់ខាងក្រោមនេះគឺជាឧទាហរណ៍៖

> *"ពេលអ្នកធ្វើដំណើរទៅកាន់ [ប្រទេសអាស៊ានមួយចំនួន] ឬប្រទេសតតិយលោកណាមួយអ្នកត្រូវតែទទួល ស្គាល់ថា អ្នកនឹងជួបបទពិសោធន៍ខុសប្លែកយ៉ាងខ្លាំង ហើយ [អ្នកនឹងត្រូវជួប] និយាមខុសប្លែកយ៉ាងខ្លាំងពីអ្វី ដែលអ្នកធ្លាប់មាននៅក្នុងប្រទេសកំណើតរបស់អ្នក។ ហេតុនេះ ថ្វីបើជាការគួរឲ្យតូចចិត្ត [ពេលឃើញ ក្មេងសុំទាន] ខ្ញុំមិនគិតថា អ្នកអាចយកបញ្ហានេះមកដាក់ខ្លួន ហើយគិតថានោះជាការទទួលខុសត្រូវបុគ្គល រហូតធ្វើឲ្យអ្នកធ្វើអ្វីម្យ៉ាងចំពោះរឿងនោះ ប្រសិនបើអ្នកមានមធ្យោបាយអាចកាត់បន្ថយស្ថានភាពនោះឡើយ។"*
>
> (ស្ត្រីអ្នកត្រូវបានសម្ភាស ជនជាតិ អង់គ្លេស អាយុជាង ៥០ ឆ្នាំ)

> *"អ្នកនឹងបានឃើញនៅគ្រប់ប្រទេស "កំពុងអភិវឌ្ឍ" ទាំងអស់ នូវកុមារ ធ្វើការសម្រាប់ "ឪពុកម្ដាយ" របស់ពួកគេ...ក្មេងលក់ទឹកសុទ្ធ និងរបស់របរគ្រប់យ៉ាងប្រភេទនេះ។ ជាការលំបាកណាស់ក្នុងការ [ដឹងអំពីរបៀប] ដើម្បីធ្វើសកម្មភាពត្រឹមត្រូវ [ព្រោះរឿងបែបនេះកើតឡើង ជាសាមញ្ញពេក]!"*
>
> (បុរស អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិអាឡឺម៉ង់ អាយុ ២១ - ២៥ ឆ្នាំ)

អ្នកទេសចរជនជាតិអាស៊ីជាច្រើន ដែលចូលរួមក្នុងការសិក្សានេះហាក់មិនសូវភ្ញាក់ផ្អើល ពេលឃើញកុមាររងាយរងគ្រោះក្នុងតំបន់ទេសចរណ៍។ ដោយឡែកអ្នកទេសចរជាច្រើនមកពីបណ្ដាប្រទេសជិតខាងបានចាត់ទុកកុមារសុំទាន ឬធ្វើការតាមចិញ្ចើមថ្នល់ថាជារឿងធម្មតា និងចាំបាច់សម្រាប់ស្ថានភាពបែបនេះ។ ឧទាហរណ៍៖

> *"ក្នុងប្រទេសរបស់ខ្ញុំ មានកុមារសុំទានជាច្រើនណាស់ ច្រើនជាងនៅទីនេះផង។ ហេតុនេះពេលខ្ញុំឃើញនៅទីនេះខ្ញុំគិតថា "ដូចតែគ្នា"។"*
>
> (បុរស អ្នកត្រូវបានសម្ភាស ប្រទេសអាស៊ីធំមួយ អាយុ ២៨ ឆ្នាំ)

> ***"ថ្វីបើនេះជារឿងធម្មតាដែលកើតមានឡើង ក្នុងប្រទេសកំពុងអភិវឌ្ឍក្ដីប៉ុន្តែខ្ញុំមានអារម្មណ៍ថា ចាំបាច់ត្រូវតែមានមធ្យោបាយដើម្បីការពារកុមារ។"***
>
> ស្ត្រី អ្នកត្រូវបានសម្ភាស អាស៊ីភាគឦសាន អាយុ ៣៦-៤០ ឆ្នាំ

ស្រដៀងគ្នានេះដែរនៅពេលអ្នកចូលរួមក្នុងការសម្ភាសជាបុរសអាយុ ៣០ ឆ្នាំ ម្នាក់មកពីប្រទេសក្បែរអាស៊ីអាគ្នេយ៍ត្រូវបាន ចោទសួរថា តើគាត់គិតដូចម្ដេចអំពីកុមារសុំទានគាត់បានឆ្លើយតបថា "រឿងនេះមិនជាអ្វីនោះទេ ព្រោះក្នុងប្រទេសខ្ញុំមានច្រើនជាងនេះទៅទៀត"។ គាត់ក៏បានបញ្ជាក់ថា គាត់ធ្លាប់ឃើញកុមារលក់ផ្កា ប៉ុន្តែជាថ្មីម្ដងទៀតគាត់គិតថានេះគឺជារឿងដែលអាច ទទួលយកបាន ព្រោះរឿងបែបនេះក៏កើតមានក្នុងប្រទេសកំណើតរបស់គាត់ដែរ។ ទស្សនៈដូចគ្នានេះ ត្រូវបានលើកឡើង ក្នុងការឆ្លើយតបរបស់អ្នកចូលរួមក្នុងការស្ទាបស្ទង់មតិ ជាជនជាតិអាស៊ីមួយចំនួន។ ស្ត្រីម្នាក់ (អាយុ ៣៦ - ៤០ ឆ្នាំ) មកពីប្រទេសអាស៊ីអាគ្នេយ៍មួយផ្ដល់យោបល់ថា កុមារនៅតាមចិញ្ចើមថ្នល់ និងកុមារធ្វើការងារគឺជា "រឿងធម្មតាចំពោះប្រទេសរបស់យើង"។ ស្ត្រីម្នាក់ទៀត (អាយុ ៣៦ - ៤០ ឆ្នាំ) មកពីប្រទេស អាស៊ី ភាគឦសាន បាន ពន្យល់ថា "ក្មេងៗធ្លាប់ធ្វើការ និងត្រូវបានកេងប្រវ័ញ្ច" នៅក្នុងប្រទេសកំណើតរបស់នាង ប៉ុន្តែបញ្ហានេះត្រូវបាន លុបបំបាត់ហើយ។ នាងបន្តទៀតថា៖

> *"ថ្វីបើនេះជារឿងធម្មតាដែលកើតមានក្នុងប្រទេសកំពុងអភិវឌ្ឍក្ដី ប៉ុន្តែខ្ញុំមានអារម្មណ៍ថា ចាំបាច់ត្រូវតែមានមធ្យោបាយដើម្បីការពារកុមារ។"*

យោបល់ទាំងអស់នេះស្នើឲ្យឃើញថា អ្នកទេសចរមួយចំនួនវាយតម្លៃលើការកេងប្រវ័ញ្ចកុមារដោយផ្អែកលើទស្សនៈរបស់ខ្លួន (ហើយអ្នកខ្លះមានទស្សនៈខុសឆ្គង) ទៅលើវប្បធម៌ក្នុងមូលដ្ឋាន ក៏ដូចជាឈរលើមូលដ្ឋាននៃសាវតាវប្បធម៌ និងបទពិសោធន៍របស់ពួកគេផ្ទាល់ផងដែរ។ កាលណាអ្នកធ្វើដំណើរជួបជាមួយស្ថានភាពដែលកុមារមានភាពងាយរងគ្រោះកាន់តែយូរពួកគេមានក្ដីរន្ធត់កាន់តែតិចចំពោះស្ថានភាព។ យោបល់ទាំងនេះ ក៏បញ្ជាក់ឲ្យឃើញផងដែរថា យូរៗទៅអ្នកធ្វើដំណើរឈានទៅបង្កើតការពន្យល់ផ្ទាល់ខ្លួនអំពីបញ្ហាសង្គម ដែលពេលខ្លះពួកគេពុំបានទទួលព័ត៌មានគ្រប់គ្រាន់។

## អ្នកទេសចរចង់ជួយកុមារដែលពួកគេជឿថាកំពុងប្រឈមគ្រោះថ្នាក់ ប៉ុន្តែពួកគេជាច្រើនមានការភ័ន្តភាំងមិនដឹងថាតើមានសកម្មភាពអ្វីខ្លះដែលពួកគេអាចធ្វើបាន។

អ្នកទេសចរធ្វើការបែងចែកខ្លះៗ ពេលពួកគេវាយតម្លៃលើអាកប្បកិរិយារបស់ខ្លួន និងអាកប្បកិរិយារបស់អ្នកដទៃ រួចកំណត់រកទិសដៅណាដែលល្អបំផុត ដើម្បីឆ្លើយតបចំពោះកុមារ។ ការបែងចែកទាំងនេះជាច្រើនត្រូវបានធ្វើឡើងដោយឈរលើមូលដ្ឋានវប្បធម៌ ឬលើការវាយតម្លៃចំពោះ "ផលប៉ះពាល់" មួយចំនួន (បានន័យថាតើខ្លួននឹងបង្កគ្រោះថ្នាក់ច្រើនជាងផ្ដល់ផលល្អ ឬទេតាមរយៈការមិនទិញឥវ៉ាន់ពីកុមារ ឬឲ្យអ្វីម្យ៉ាងទៅកុមារ)។ ទោះជាយ៉ាងនេះក្ដី អ្នកទេសចរជាច្រើន ហាក់ធ្វើការវាយតម្លៃដោយផ្អែកលើមូលដ្ឋាន នៃការឆ្លើយតបផ្អែកមនោសញ្ចេតនាផ្ទាល់ខ្លួនចំពោះបញ្ហា ឬករណីកើតឡើងផងដែរ។ យោបល់ខាងក្រោមគូសបញ្ជាក់ឲ្យឃើញអំពីផលប៉ះពាល់នៃភាពគួរឲ្យស្រឡាញ់របស់កុមារចំពោះអ្នកទេសចរ៖

> *"ខ្ញុំគិតថា ខ្ញុំមិនអាចទប់ចិត្តបានទេ [ប្រសិនបើខ្ញុំឃើញកុមារសុំទាន] ហើយខ្ញុំនឹងឲ្យលុយទៅពួកគេ។ តើនរណាអាចដើរចេញពីកុមារសុំអាហារ ឬសុំលុយពីអ្នកនោះ? ខ្ញុំច្បាស់ជាឲ្យអាហារទៅគេ ប្រសិនបើខ្ញុំមាន។ ចុះចំពោះរឿងលុយវិញ? បាទ ខ្ញុំគិតថា ខ្ញុំមិនអាចទប់ចិត្តបានទេ ថ្វីបើខ្ញុំដឹងថា ផ្អែកលើមូលដ្ឋានតក្កវិជ្ជានោះគឺជាយន្តការដូចគ្នា [នឹងក្មេងលក់ឥវ៉ាន់ដែរ ព្រោះថាការធ្វើបែបនេះមិនផ្ដល់អត្ថប្រយោជន៍ឲ្យកុមារដោយផ្ទាល់ឡើយ]។"* (បុរស អ្នកត្រូវបានសម្ភាស ជនជាតិអាឡឺម៉ង់ អាយុ ២៦ ឆ្នាំ)

> *"[ក្មេងដែលយើងទិញឥវ៉ាន់នោះ] នាងស្អាតណាស់ នាងពូកែញញឹម...ពួកយើងកំពុងនៅក្នុងភោជនីយដ្ឋានមួយ ហើយនាងបានសម្លឹង និងញញឹមដាក់យើង រួចដើរមកនិយាយសួស្ដីជាមួយយើង បន្ទាប់មកព្យាយាម និយាយបន្តិចបន្តួច [ជាមួយយើង] ក្រោយមកខ្ញុំគិតថា នាងរួសរាយខ្លាំងណាស់។ នាងបានឲ្យយើងមិនត្រឹមតែវត្តអនុស្សាវរីយ៍នោះឡើយ [តាមរយៈការឆ្លងឆ្លើយគ្នានោះ]។ នេះហើយគឺជាមូលហេតុធ្វើឲ្យខ្ញុំទិញឥវ៉ាន់ពីនាង។"*
> (ស្ត្រី និងបុរស អ្នកដែលត្រូវបានសម្ភាស ជនជាតិ បារាំង អាយុ ២៧ និង ៣៤ ឆ្នាំ)

ក្នុងការពិភាក្សាអំពីការឆ្លើយតបរបស់គេពេលឃើញកុមារកំពុងធ្វើការ អ្នកទេសចរមួយចំនួនក៏បានលើកឡើងយ៉ាងច្បាស់ថា ពួកគាត់មិនចង់វិនិច្ឆ័យលើវប្បធម៌ណាមួយក្រៅពីវប្បធម៌របស់ខ្លួន ហើយបានបញ្ជាក់ថា ភាពក្រីក្របានដាក់គ្រួសារ និងមនុស្សវ័យក្មេងជាច្រើនឲ្យស្ថិតក្នុងស្ថានភាពលំបាក។ អ្នកទេសចរបានបញ្ជាក់ថា មានភាពស្មុគស្មាញនៅក្នុងបញ្ហាស្ដីពីការកេងប្រវ័ញ្ច និងការរំលោភបំពានដែលពុំអាចត្រូវបានច្បិចយកតាមរយៈការឆ្លើយតបទោលណាមួយនោះឡើយ។ អ្នកទេសចរមួយចំនួនក៏ហាក់គិតថា មិនសូវមានការកេងប្រវ័ញ្ច និងមានសក្ដានុពល ធ្វើឲ្យមានការខូចខាតខ្លាំង ប្រសិនបើកុមារធ្វើការសម្រាប់គ្រួសាររបស់ខ្លួនជាជាងធ្វើឲ្យអ្នកដទៃ។ យោបល់ខាងក្រោម គឺឧទាហរណ៍បង្ហាញអំពីការគិតដែលឆ្លុះបញ្ចាំង និងអារម្មណ៍ចម្រុះគ្នារបស់អ្នកទេសចរ៖

> *"ខ្ញុំបានឮពីមិត្តភក្តិរបស់ខ្ញុំដែលជាមនុស្សក្នុងស្រុក ប្រាប់ខ្ញុំថា មនុស្សក្នុងស្រុកនេះជឿលើ លំដាប់លំដោយសង្គម ហើយពួកគេមានអារម្មណ៍ថាមិនជាការអ្វីទេដែលពួកគេ [កុមារ] ត្រូវធ្វើការងារ ផ្សេងៗ ព្រោះទាំងអស់នេះគឺគ្រាន់តែដើម្បីរកលុយប៉ុណ្ណោះ។ ម្យ៉ាងទៀតមុខរបស់ពួកគេតែងញញឹមជានិច្ច ហេតុនេះខ្ញុំមិនមានអារម្មណ៍ថាវាជារឿងអាក្រក់នោះឡើយ [ដែលកុមារត្រូវធ្វើការ]។"* (ស្ត្រី អ្នកត្រូវបានសម្ភាស ជនជាតិ ជប៉ុន អាយុ ៤៥ ឆ្នាំ)

*"វាពុំមែនជារឿងគួរឲ្យបារម្ភណាស់ណាទេ [ពេលឃើញកុមារធ្វើការនៅទីនេះ]។ ពេលខ្លះ ខ្ញុំមាន អារម្មណ៍ហាក់ដូចជា ក្មេងៗនៅក្នុងហាង ហើយឪពុកម្តាយរបស់គេនៅខាងក្រោយហាង។ ខ្ញុំមើលទៅហាក់ដូចជា ក្មេងៗអាចធំលឿនជាងមុន...។ ខ្ញុំមិនដឹងថានោះគឺជារឿងល្អ ឬជារឿងអាក្រក់ នោះទេ ប៉ុន្តែ[នេះជារឿងធម្មតានៅទីនេះ]។"*
(ស្ត្រី អ្នកត្រូវបានសម្ភាស ជនជាតិ អាមេរិក អាយុ ២៣ ឆ្នាំ)

*"[ពេលឃើញកុមារធ្វើការ ខ្ញុំមានអារម្មណ៍] ប្រេះស្រាំក្នុងចិត្ត ខ្ញុំក្រៀមក្រំដោយសារកុមារត្រូវ ស្ថិតនៅក្នុងស្ថានភាពបែបនេះ។ ខ្ញុំខឹង ដោយឃើញពួកគេជ្រើសរើសយកលុយសំខាន់ជាងការអប់រំ (ថ្ងៃនេះ យើងបានជួបក្មេងប្រុសអាយុ ១១ ឆ្នាំ រៀនថ្នាក់ទី ២ ដោយសារតែក្មេងនោះជ្រើសរើសទៅធ្វើការ នៅលើទូក ជំនួសឲ្យការទៅសាលារៀន)។ ការជ្រើសរើសបែបនេះនឹងធ្វើឲ្យបញ្ហាក្នុងប្រទេសនេះ កាន់តែរីកធំទៅមុខទៀត។ ប៉ុន្តែខ្ញុំយល់ពីតម្រូវការក្នុងការចិញ្ចឹមគ្រួសារ។ ក្មេងខ្លះគឺជាអ្នករកលុយចិញ្ចឹមគ្រួសារ។*
(ស្ត្រី អ្នកឆ្លើយតបការ ស្ទាបស្ទង់មតិ ជនជាតិ អាហ្វ្រិកខាងត្បូង អាយុ ៣១ - ៣៥ ឆ្នាំ)

*"ប្រសិនបើកុមារត្រូវបានគ្រប់គ្រងដោយនរណាម្នាក់ ហើយត្រូវរកលុយសម្រាប់អ្នកនោះ ឬសម្រាប់អ្នកផ្សេងទៀត នោះខ្ញុំពិតជាមិនសប្បាយចិត្ត [ក្នុងការទិញឥវ៉ាន់ពីពួកគេឡើយ]។ ប៉ុន្តែកុមារដែលចង់រកលុយសម្រាប់គ្រួសារនោះ ខ្ញុំសប្បាយចិត្តនឹងផ្តល់អ្វីម៉្យាងទៅឲ្យពួកគេ។"* (ស្ត្រី អ្នកត្រូវបានសម្ភាស ជនជាតិចិន អាយុ ៣០ ឆ្នាំ)

អ្នកទេសចរមិនសូវច្បាស់ ថាតើពួកគេអាចដើរតួនាទីជាផ្នែកមួយក្នុងការឆ្លើយតបចំពោះបញ្ហានេះ ដោយរបៀបណានោះទេ។ ឧទាហរណ៍ជាកិច្ចឆ្លើយតបនឹងសំណួរថា តើគាត់មានអារម្មណ៍ដូចម្តេចពេលឃើញកុមារធ្វើការ ឬឃើញកុមារតាមផ្លូវ បុរសម្នាក់ដែលជាអ្នកឆ្លើយតបនឹងការស្ទាបស្ទង់មកពីប្រទេសភូមា (អាយុ ២១ - ២៥ ឆ្នាំ) បានបញ្ជាក់ថា គាត់ "មានអារម្មណ៍សោកសៅ ជំនួសពួកគេ" ហើយចង់ជួយពួកគេ គាត់ថែមទាំងបានបញ្ជាក់ទៀតថា "ប្រសិនបើខ្ញុំអាចធ្វើបាន ខ្ញុំនឹងឲ្យអាហារ លុយ ឬអំណោយទៅពួកគេ។ ខ្ញុំបានជជែកជាមួយពួកគេអំពីស្ថានភាពរបស់ពួកគេដើម្បីឲ្យដឹងថាតើខ្ញុំអាចជួយពួកគេបានយ៉ាងណាខ្លះ"។ ស្រដៀងគ្នានេះដែរ ការឆ្លើយតបប្រកបដោយសន្ដានចិត្ត ប៉ុន្តែហាក់មានភាពផ្ទាំផ្ទួង ត្រូវបានបង្ហាញឲ្យឃើញទាក់ទងនឹងសំណួរក្នុងការស្ទាបស្ទង់មតិដែលចោទសួរ ថា"ក្នុងនាមជាអ្នកធ្វើដំណើរ មកកាន់តំបន់អាស៊ីអាគ្នេយ៍ តើអ្នកគិតថាអ្នកអាចធ្វើអ្វីបានខ្លះ ដើម្បីការពារកុមារ និង យុវជនងាយរងគ្រោះ?" ថ្វីបើមានភស្តុតាងបង្ហាញថា ការថែទាំក្នុងមណ្ឌល គឺពុំមែនជាជម្រើសដ៏ល្អបំផុត សម្រាប់កុមារ និងមនុស្សវ័យក្មេងក្នុងតំបន់នោះទេ ហើយ "ទេសចរណ៍ទៅកាន់មណ្ឌលកុមារកំព្រា" អាចមានផលប៉ះពាល់ដ៏ អាក្រក់ចំពោះសុខុមាលភាពផ្នែកសង្គម ផ្លូវកាយ និងផ្លូវចិត្តរបស់កុមារ (សូមមើលជាឧទាហរណ៍ Csaky ឆ្នាំ ២០០៩; Guiney; ឆ្នាំ ២០១២) ប៉ុន្តែអ្នកទេសចរជាច្រើនមានអារម្មណ៍ថា ការទៅទស្សនាមណ្ឌលកុមារកំព្រា (មិនថា ក្នុងនាមជាភ្ញៀវនៅពេលថ្ងៃ ឬជាអ្នកស្ម័គ្រចិត្ត) គឺជាជម្រើសត្រឹមត្រូវមួយ ជំនួសឲ្យការឲ្យលុយទៅកុមារតាមចិញ្ចើមផ្លូវ ឬទិញឥវ៉ាន់ពីកុមារ។ យើងបានជួនយោបល់ដូចខាងក្រោមនេះជាច្រើន៖

*"បង្ហាញផ្លូវពួកគេ។ យកពួកគេទៅមណ្ឌលកុមារកំព្រា ឬទទួលចិញ្ចឹមពួកគេ។"*
(បុរស អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិអាមេរិក អាយុ ២១ - ២៥ ឆ្នាំ)

*"ខ្ញុំអាចឲ្យលុយទៅពួកគេ។"*
(ស្ត្រី អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិចិន អាយុ ១៨ - ២០ ឆ្នាំ)

ឆ្លើយតបទៅនឹងចំណុចស្តីពីការយល់ដឹងមានកម្រិតកំណត់របស់អ្នកទេសចរ ស្តីពីអ្វីដែលពួកគេអាចធ្វើបាន ការរកឃើញបានបង្ហាញថា មានតែការឆ្លើយតបការស្ទាបស្ទង់មតិចំនួន ១១ នាក់ ក្នុងចំណោម ៥៤ នាក់ (២០%) ប៉ុណ្ណោះដែលបានរាយការណ៍ថា បានឃើញករណីការកេងប្រវ័ញ្ចលើកុមារ ហើយបានរាយការណ៍ទៅសមត្ថកិច្ច។ អ្នកឆ្លើយតបសរុបចំនួន ៣៧ នាក់ (៦៩%) ពុំបានរាយការណ៍ទេ (អ្នកទេសចរ ៦ នាក់ បានចំហសំណួរនេះចោល)។ អ្នកដែលពុំបានរាយការណ៍បានបញ្ជាក់ថា ពួកគេខកខានពុំបានរាយការណ៍ដោយសារពួកគេពុំមានព័ត៌មានគ្រប់គ្រាន់ស្តីពីការពិតដែលបានកើតឡើង ពួកគេពុំដឹងច្បាស់ថា តើត្រូវរាយការណ៍ទៅនរណា ឬពុំដឹងថាតើបណ្តឹងរបស់ខ្លួនត្រូវបានយកចិត្តទុកដាក់ ឬអត់។ យោបល់ខាងក្រោមឆ្លុះបញ្ចាំងអំពីភាពមិនច្បាស់លាស់នេះ៖

*"ខ្ញុំពុំដឹងថាត្រូវប្រាប់ទៅនរណា [អំពីកុមារសុំទាននៅតាមផ្លូវ] ហើយខ្ញុំគិតថា បើខ្ញុំរាយការណ៍ទៅក៏ពុំដឹងអាចជួយអ្វីបានដែរ។"* (ស្ត្រី អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិតៃវ៉ាន់ អាយុ ២៦ - ៣០ ឆ្នាំ)

*“ខ្ញុំពុំដឹងថាតើខ្ញុំគួរទំនាក់ទំនងទៅនរណា ហើយខ្ញុំគិតថាពួកគេប្រហែលមិនធ្វើអ្វីលើបញ្ហានោះឡើយ ដោយសារតែបញ្ហាទាំងនេះ [ក្មេងស្រីក្រោមអាយុធ្វើការជាអ្នករាំរបាំនៅបង្គោលដែក និងក្មេងស្រីលក់ផ្កានៅក្នុងបារទេសចរណ៍] គឺជារឿងសាមញ្ញ ខ្លាំងណាស់នៅទីនេះ។”*

( ស្ត្រី អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិអូស្ត្រាលី អាយុ ២៦ - ៣០ ឆ្នាំ )

*“ខ្ញុំមានអារម្មណ៍ថា ប្រសិនបើខ្ញុំទៅស្ថានទូត ហើយរាយការណ៍អំពីរឿងនេះពួកគេប្រាកដជានិយាយថា “អូ មែនហើយរឿងនេះពិតជាកើតឡើង។ យើងដឹងថាមានបញ្ហាច្រើនណាស់”។ ខ្ញុំមិនរំពឹងថាមាននរណានឹងនិយាយថា “តើរឿងនេះកើតនៅទីណា ? តើយើងអាចទៅរកឃើញនៅកន្លែងណា?” ព្រោះថាមើលទៅរឿងនេះហាក់ដូចជា អ្វីដែលមនុស្សគ្រប់រូបឃើញ ប៉ុន្តែពុំមាននរណាប្រឈមមុខឡើយ។”*

( បុរស អ្នកឆ្លើយតបការសម្ភាស អាយុ ២៦ ឆ្នាំ )

*“ខ្ញុំមិនដឹងថាត្រូវចាប់ផ្តើមពីកន្លែងណា។ ខ្ញុំគ្រាន់តែមានអារម្មណ៍ថា គេប្រាកដជានិយាយថា “នេះជារឿងធម្មតាចំពោះវប្បធម៌របស់យើង” ថ្វីបើមើលទៅជារឿងខុសឆ្គងយ៉ាងច្បាស់ក្តី...ខ្ញុំក៏មានអារម្មណ៍តិចៗដែរថា ប្រសិនបើអ្នករាយការណ៍ពីនរណាម្នាក់ ដែលនោះគឺជាស្ថានភាព ក្នុងជីវិតរបស់ពួកគេ ហើយពួកគេពុំអាចចេញរួចពីស្ថានភាពនោះ រួចគេត្រូវបានចាប់ខ្លួនតែម្តង រឿងនេះកាន់តែធ្វើឲ្យពួកគេកាន់តែលំបាក។”*

( ស្ត្រី អ្នកត្រូវបានសម្ភាស ជនជាតិអង់គ្លេស អាយុ ២២ ឆ្នាំ )

ភាពមិនច្បាស់លាស់ថាតើគួររាយការណ៍ ឬអត់ ប្រហែលជាមានប្រភព មួយចំនួនផងដែរមកពីអារម្មណ៍ចម្រុះស្តីអំពី “ការទទួលខុសត្រូវ”។ នៅពេលយើងសួរថា តើពួកគេគិតថាខ្លួនត្រូវទទួលខុសត្រូវក្នុងការការពារ កុមារងាយរងគ្រោះ នៅក្នុងវិស័យទេសចរណ៍ក្នុងតំបន់ ឬ ទេ ៥១% នៃអ្នកឆ្លើយតបការស្ទាបស្ទង់មតិបញ្ជាក់ថាពួកគេមានការទទួលខុសត្រូវ។ យោបល់ដូចខាងក្រោមនេះចង្អុលយ៉ាងច្បាស់អំពីទស្សនៈនេះ៖

*“ចាស ការការពារកុមារគឺជាការទទួលខុសត្រូវរបស់ មនុស្សគ្រប់រូប។”*

( ស្ត្រីជនជាតិចិន អាយុ ២១ - ២៥ ឆ្នាំ )

> **“ក្នុងនាមជាប្រជាពលរដ្ឋរមពិភពលោក ខ្ញុំត្រូវទទួលខុសត្រូវចំពោះសុខសុវត្ថភាពកុមារទូទាំងពិភពលោក។ ”**
>
> ស្ត្រីជនជាតិចិនអាយុ ២៦ ដល់ ៣០ឆ្នាំ

*“ចាស។ ក្នុងនាមជាមនុស្សធំ ខ្ញុំជឿជាក់ថា ខ្ញុំត្រូវទទួលខុសត្រូវក្នុងការសម្លឹងរក និងការពារកុមារមិនថាខ្ញុំនៅទីណានោះឡើយ។ កុមារនៅតូចណាស់ មិនអាចការពារខ្លួនឯងបានឡើយ ហេតុនេះមនុស្សធំត្រូវធានាថា កុមារមានសុវត្ថិភាព”។*

( ស្ត្រីជនជាតិ អូស្ត្រាលី អាយុ ២៦ - ៣០ ឆ្នាំ )

*“ក្នុងនាមជាពលរដ្ឋរមពិភពលោក ខ្ញុំត្រូវទទួលខុសត្រូវចំពោះសុខសុវត្ថិភាពកុមារទូទាំងពិភពលោក។”* ( ស្ត្រី ជនជាតិចិន អាយុ ២៦ - ៣០ ឆ្នាំ )

ទោះយ៉ាងនេះក្តី ៨% នៃអ្នកចូលរួមការស្ទាបស្ទង់មតិបានបង្ហាញថា ពួកគេពុំមានអារម្មណ៍ថា ពួកគេត្រូវទទួលខុសត្រូវ នោះឡើយ ហើយអ្នកឆ្លើយតបការស្ទាបស្ទង់មតិជាច្រើន ( ៤២% ) ពុំឆ្លើយតបចំពោះសំណួរនេះ ឬបង្ហាញ ភាពស្រពេចស្រពិលក្នុងចម្លើយរបស់ពួកគេ ( មិនបានផ្តល់ចម្លើយ បាទ/ចាស ឬទេ ឲ្យច្បាស់នោះឡើយ )។ អ្នកត្រូវបានសម្ភាសមួយចំនួនផ្តល់ការឆ្លើយតបប្រកបដោយគំនិតយ៉ាងជ្រាលជ្រៅនៅពេលពួកគេត្រូវបានសួរថា តើអ្នកទេសចរ គួរទទួលខុសត្រូវក្នុងការការពារកុមារពីការរំលោភ បំពាន និងការកេងប្រវ័ញ្ចឬទេ។ ពួកគេបានដឹងថា អ្នកទេសចរបាន ចូលរួមវិភាគទានធ្វើឲ្យកើតមានបញ្ហាជាច្រើន តាមរយៈការបង្កើតឲ្យមានតម្រូវការទំនិញ ឬសេវាកម្មមួយចំនួន ( ដូចជា វត្ថុអនុស្សាវរីយ៍តម្លៃថោកដែលកុមារលក់ ) ឬតាមរយៈការមិនបង្ហាញចេញមកយ៉ាងច្បាស់លាស់ អំពីគោលជំហរមិនលើកទឹកចិត្តដល់ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារ ដោយការចៀសវាង មិនទៅកាន់ទិសដៅទេសចរណ៍ទាំងឡាយណាដែលធ្វើឲ្យទង្វើទាំងអស់មានលក្ខណៈសាយភាយជាទូទៅ៖

*“ប្រសិនបើមិនមានអ្នកទេសចរទេនោះ មនុស្សទាំងនេះប្រាកដជាពុំមានលុយច្រើនដូច្នេះឡើយ។ ហេតុនេះពួកគេពឹងផ្អែកលើអ្នកទេសចរឲ្យនាំយកលុយទៅឲ្យពួកគេ ប៉ុន្តែស្របពេលជាមួយគ្នានោះដែរ ប្រសិនបើពួកគេប្រើប្រាស់ឧបករណ៍ខុសឆ្គងក្នុងការទាក់ទាញអ្នកទេសចរនោះ សម្រាប់ខ្ញុំវាពិតជាមិនមានផលល្អឡើយ [ដោយសារតែវាមិនមាននិរន្តរភាព]។ ខ្ញុំច្បាស់ជាមិនចង់ត្រឡប់ទៅកាន់ កន្លែងណាមួយដែលផ្ទុយនឹងសីលធម៌របស់ខ្ញុំម្តងទៀតឡើយ។ ប៉ុន្តែអ្នកទេសចរអាចធ្វើអ្វីម្យ៉ាង អំពីរឿងនេះ [តាមរយៈការមិនទៅទីនោះ]។”*
( ស្ត្រី អ្នកត្រូវបានសម្ភាស ជនជាតិអង់គ្លេស អាយុ ២៣ ឆ្នាំ )

## អ្នកទេសចរភាគច្រើនជឿជាក់ថា ឧស្សាហកម្មទេសចរណ៍ និង/ឬរដ្ឋាភិបាលក្នុងតំបន់ គួរធ្វើសកម្មភាពបន្ថែមទៀតដើម្បីឆ្លើយតបបញ្ហាការកេងប្រវ័ញ្ចលើកុមារ រួមទាំងតាមរយៈការអប់រំអ្នកទេសចរស្តីពីវិធីដែលពួកគេអាចជួយបានផងដែរ។

អ្នកទេសចរ ចង់ទទួលបានព័ត៌មានបន្ថែមទៀត អំពីរបៀបដែលពួកគេអាចកាន់បន្ថយការកេងប្រវ័ញ្ចលើកុមារ ឬយ៉ាងហោចណាស់ក៏ចង់ធ្វើដំណើរ ក្នុងលក្ខណៈមួយដែលពុំធ្វើឲ្យបញ្ហានេះរីកសាយភាយទៅទៀត។ អ្នកទេសចរក៏បានជឿជាក់ផងដែរថា ឧស្សាហកម្មការធ្វើដំណើរ និងទេសចរណ៍មានតួនាទីយ៉ាងសំខាន់ក្នុងការចែករំលែកព័ត៌មាននេះ។ សូមមើលជាឧទាហរណ៍ នូវការអង្កេតខាងក្រោម៖

*“ខ្ញុំគិតថា ឧស្សាហកម្មបដិសណ្ឋារកិច្ចមានការទទួលខុសត្រូវមួយផ្នែកមិនថាក្នុងរូបភាពបែបណានោះឡើយ ប៉ុន្តែគេត្រូវជួយ អប់រំអ្នកទេសចរដែលធ្វើដំណើរចូលមកដើម្បីឲ្យយើងបានដឹងអំពីការឆ្លើយតបដែលសមស្រប។”*
( ស្ត្រី អ្នកត្រូវបានសម្ភាស ជនជាតិអាមេរិក អាយុ ៥៣ ឆ្នាំ )

*“ចំពោះខ្ញុំ តាមពិតខ្ញុំគិតថាជារឿងសំខាន់ ហើយស្ទើរតែ ជាកាតព្វកិច្ចទៀតផង ដែលភ្នាក់ងារទេសចរនៅប្រទេស របស់យើងត្រូវផ្តល់ព័ត៌មានអំពីរឿងទាំងអស់នេះ [ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារក្នុងវិស័យទេសចរណ៍ និងអំពីរបៀបដែលយើងអាចទប់ស្កាត់រឿងនេះបាន]។ ពួកគេប្រាប់អ្នកអំពីរឿងដូចជា “អូ ការជិះម៉ូតូគឺគ្រោះថ្នាក់ណាស់ ជាការពិតការឲ្យលុយ ៥០ សេន ទៅកុមារគឺគ្រោះថ្នាក់យ៉ាង ខ្លាំង!”* ( ស្ត្រី អ្នកត្រូវបានសម្ភាស ជនជាតិអង់គ្លេស អាយុ ២៣ ឆ្នាំ )

*“ចាស [អ្នកទេសចរគួរទទួលខុសត្រូវ] ប៉ុន្តែសំខាន់ជាងនេះទៅទៀត ខ្ញុំគិតថា ឧស្សាហកម្មទេសចរណ៍ មិនថាជាសណ្ឋាគារប្រតិបត្តិករទេសចរណ៍ ក្រុមហ៊ុនអាកាសចរ គួរតែសកម្មជាងនេះទៅទៀត។ ក្នុងនាមជាអ្នកធ្វើដំណើរ អ្នកគួរ [បានទទួល] ព័ត៌មានហេតុនេះ ហើយទើបយុទ្ធនាការផ្សព្វផ្សាយលើយន្តហោះអាចជួយបានយ៉ាងច្រើន។”*
( ស្ត្រី អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិអាឡឺម៉ង់  អាយុ ២១ - ២៥ ឆ្នាំ )

> **“តាមពិតខ្ញុំគិតថា ភ្នាក់ងារទេសចរនៅ ប្រទេសរបស់យើង [អាច] ផ្តល់ព័ត៌មានឲ្យយើងអំពីរឿងទាំងអស់នេះ។ ពួកគេប្រាប់អ្នកអំពីរឿងដូចជា “អូ ការជិះម៉ូតូ គឺគ្រោះថ្នាក់ណាស់”។ ជាការពិតការឲ្យលុយ ៥០ សេន ទៅកុមារគឺគ្រោះថ្នាក់យ៉ាងខ្លាំង !”**
>
> ស្ត្រី អ្នកត្រូវបានសំភាសន៍ ជនជាតិអង់គ្លេស អាយុ ២៣ ឆ្នាំ

អ្នកទេសចរជាច្រើនក៏បាននិយាយថា ពួកគេតែងចង់គាំទ្រគ្រឹះស្ថានទេសចរណ៍ទាំងឡាយណាដែលអនុវត្ត ការរក្សាសុវត្ថិភាពកុមារ។ អ្នកទេសចរម្នាក់បានបញ្ជាក់ថា នាងមានក្តីរីករាយយ៉ាងខ្លាំងដោយសារនាងអាចចូលរួម វិភាគទានជាវិជ្ជមាន ចំពោះតំបន់៖

*“យើងពុំបានឲ្យលុយទៅកុមារដោយផ្ទាល់នោះទេ ប៉ុន្តែយើងចង់ធ្វើអ្វីម្យ៉ាងដើម្បីអាចជួយកុមារ ហេតុនេះខ្ញុំទៅទិញរបស់ខ្លះ ពីហាងដែលដំណើរការដោយអង្គការដែលលក់ទំនិញផលិតដោយឪពុកម្តាយអតីតក្មេង តាមចិញ្ចើមថ្នល់។*

*លុយដែលខ្ញុំផ្តល់ ទៅឲ្យតាមរយៈការទិញកាបូបមួយគឺចូលទៅក្នុងលុយមនុស្សធម៌ ដែលក្រោយមកនឹងអាចជួយកែទម្រង់កុមារតាមចិញ្ចើមថ្នល់ ហើយឲ្យគេទៅសាលារៀន។"* (ស្រ្តី អ្នកត្រូវបានសម្ភាស ជនជាតិអង់គ្លេស អាយុ ២៤ ឆ្នាំ)

ថ្វីបើពុំមែនអ្នកទេសចរទាំងអស់ សុទ្ធតែបានជួបសហគ្រាសសសង្គម ឬអាជីវកម្មសហគមន៍ប្រភេទនេះក្តី ប៉ុន្តែអ្នកទេសចរជាច្រើន បានបង្ហាញចំណាប់អារម្មណ៍លើសហគ្រាស ឬអាជីវកម្មទាំងអស់ ហើយចាប់អារម្មណ៍ចង់ទទួលបានព័ត៌មានបន្ថែមទៀតអំពីទីតាំង និងរបៀបដែលពួកគេទៅរកទីកន្លែងទាំងអស់នោះបាន។ ដោយឡែកអ្នកទេសចរចង់បានបញ្ជីឈ្មោះអង្គការមនុស្សធម៌ និង សហគ្រាសសង្គមសម្រាប់កុមារដែលមានកេរ្តិ៍ឈ្មោះនៅក្នុងតំបន់ដែលពួកគេអាច គាំទ្រព្រមទាំងចង់ឲ្យដាក់អាជីវកម្មទេសចរណ៍ដែលរក្សាសុវត្ថិភាព កុមារចូលក្នុងបញ្ជី ឬ ទិន្នន័យ ដែលមានការធ្វើសវនកម្មពីខាងក្រៅប្រភេទណាមួយ។

*"ការធ្វើបែបនោះប្រាកដជាជះឥទ្ធិពលយ៉ាងធំធេងលើការសម្រេចចិត្តរបស់ខ្ញុំស្តីពី ការទៅកន្លែងណាមួយ។ ប៉ុន្តែតើធ្វើ យ៉ាងណាដើម្បីឲ្យខ្ញុំដឹងថា ត្រូវចាប់ផ្តើមពីកន្លែងណាដើម្បីស្វែងរក [ព័ត៌មាន] ទាំងនោះបាន ? ឧទាហរណ៍ ប្រសិនបើ ខ្ញុំចូលទៅក្នុងអ៊ីនធឺណែត ហើយខ្ញុំទៅបើកមើលតាមទីកន្លែង និងតម្លៃក៏ដូចជាតាមចំណាត់ប្រភេទទាំងអស់នោះ ហើយខ្ញុំបើក មើលលើគេហទំព័ររបស់ក្រុមហ៊ុនមួយរួចពុំមាន អ្វីទាល់តែសោះនៅលើគេហទំព័រនោះ អញ្ចឹងវាគឺជាការងារបន្ថែមដ៏ច្រើនណាស់សម្រាប់ខ្ញុំ នេះខ្ញុំសូមនិយាយត្រង់ៗ ប្រាប់អ្នក។ ហេតុនេះខ្ញុំគិតថា ខ្ញុំនឹងខំខ្នះខ្នែងបន្ថែមទៀត ប៉ុន្តែអាជីវកម្មចាំបាច់ត្រូវតែជួយយើងដើម្បីជាផ្នែកមួយនៃដំណោះស្រាយ។* (ស្រ្តី អ្នកត្រូវបានសម្ភាស ជនជាតិអាមេរិក អាយុ ៥៣ ឆ្នាំ)

*"អញ្ចឹង ធ្វើដូចម្តេចទើបខ្ញុំអាចដឹងថាសណ្ឋាគារ ឬអាជីវកម្មណាមួយកំពុងអនុវត្តស្តង់ដារការពារកុមារបាន ? ខ្ញុំមិនដឹងទេ។ ខ្ញុំមិនទាំងដឹងផងដែរថា វាមានន័យដូចម្តេចនោះ។ ប៉ុន្តែ ប្រសិនបើមានអ្វីម៉្យាងដូចជា និមិត្តសញ្ញាដែលខ្ញុំអាចដឹងថា វាមានន័យថាជាតំបន់មានសុវត្ថិភាពចំពោះកុមារ ឬថាពួកគេកំពុងអនុវត្ត ឬប្រតិបត្តិការក្រមស្តង់ដារ ឬអ្វីម៉្យាងនោះ ហើយពួកគេបានទទួលវិញ្ញាប័ណ្ណបត្របញ្ជាក់ នោះប្រាកដជាការល្អ។"*

(បុរស អ្នកត្រូវបានសម្ភាស ជនជាតិអាមេរិក អាយុ ២៦ ឆ្នាំ)

> *“ខ្ញុំគិតថា ខ្ញុំប្រាកដជាខំខ្នះខ្នែងបន្ថែមទៀត ប៉ុន្តែអាជីវកម្មចាំបាច់ត្រូវតែជួយយើង ដើម្បីជាផ្នែកមួយនៃដំណោះស្រាយ។”*
>
> ស្រ្តី អ្នកត្រូវបានសម្ភាស ជនជាតិអាមេរិក អាយុ ៥៣ ឆ្នាំ

ប្រយោគខាងក្រោមនេះ បង្ហាញអំពីសារៈសំខាន់ដែលអ្នកទេសចរ ផ្តល់តម្លៃទៅលើការចូលរួមរបស់រដ្ឋាភិបាល៖

*"ប្រសិនបើខ្ញុំជួបកុមារសុំទាន ឬលក់ឥវ៉ាន់ ខ្ញុំមានអារម្មណ៍អាណិតអាសូរ ហើយប្រសិនបើខ្ញុំអាចជួយបាន ខ្ញុំប្រាកដជាចង់ជួយ។ ប៉ុន្តែខ្ញុំគិតថា រដ្ឋាភិបាលគួរជួយកុមារ។ ប្រសិនបើ ខ្ញុំជួយកុមារ ខ្ញុំមានអារម្មណ៍សប្បាយចិត្ត ប៉ុន្តែប្រសិនបើខ្ញុំមកទីនេះម្តងទៀត ខ្ញុំសង្ឃឹមថា ខ្ញុំនឹងមិនឃើញកុមារសុំទានទៀតឡើយ។ ខ្ញុំសង្ឃឹមថារដ្ឋាភិបាលនឹងដោះស្រាយរឿងនេះ"។*

(ស្រ្តី អ្នកត្រូវបានសម្ភាស ជនជាតិចិន អាយុ ៣០ ឆ្នាំ)

*"ចាំបាច់ត្រូវតែមាន [ការធ្វើសកម្មភាព] រួមគ្នារវាងអ្នកធ្វើដំណើរ និងរដ្ឋាភិបាលក្នុងមូលដ្ឋាន។"*

(បុរស អ្នកត្រូវបានសម្ភាស ជនជាតិ អាមេរិក អាយុ ២៦ ឆ្នាំ)

*"ខ្ញុំគ្រាន់តែឆ្ងល់ថាតើហេតុអ្វីបានជារដ្ឋាភិបាលមិនព្យាយាម ធ្វើអ្វីម៉្យាងពីបញ្ហានេះ ? [កុមារធ្វើការរស់នៅតាមចិញ្ចើមថ្នល់ ]។"* (ស្រ្តី អ្នកឆ្លើយតបការស្ទាបស្ទង់មតិ ជនជាតិហុងកុង អាយុ ២៦ - ៣០ ឆ្នាំ)

សកម្មភាពដែលត្រូវបានធ្វើឡើងដោយរដ្ឋាភិបាល និងឧស្សាហកម្មទេសចរណ៍ ដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចលើកុមារអាចជួយប្រឆាំងតបតជាមួយកេរ្តិ៍ឈ្មោះជាអវិជ្ជមានរបស់គោលដៅទេសចរណ៍ដោយត្រូវបានបង្កើតឡើងដោយអ្នកទេសចរ នៅពេលដែលពួកគេផ្សាភ្ជាប់ជាមួយតំបន់ ទេសចរណ៍ជាក់លាក់ណាមួយ។ តាមសម្តីរបស់អ្នកទេសចរ ម្នាក់បាននិយាយថា ការលុបបំបាត់

ឬកាត់បន្ថយបញ្ហាទាំងនេះមួយចំនួនអាចជះឥទ្ធិពលជាវិជ្ជមានលើបទពិសោធន៍វិស្សមកាល របស់អ្នកទេសចរ៖

> *"ខ្ញុំគិតថា វាជារឿងវិជ្ជមានសម្រាប់ប្រទេសទាំងអស់នេះ [ក្នុងការទប់ស្កាត់ការរំលោភបំពានលើកុមារ និងការកេងប្រវ័ញ្ចលើកុមារក្នុងវិស័យទេសចរណ៍]។ ពួកគេចាំបាច់ត្រូវតែបញ្ឈប់រឿងនេះ [មិនមែនគ្រាន់តែដោយសារ វាជះឥទ្ធិពលលើកុមារតែប៉ុណ្ណោះទេ] ប៉ុន្តែដោយសារតែបញ្ហាដ៏ធំមួយដែលយើងច្រើនជួបនៅក្នុងទ្វីបអាស៊ីគឺរឿងមនុស្ស ចូលចិត្តឆាឆៅយើង។ ពេលខ្លះយើងធ្វើដំណើរទៅដោយគិតថា គេនឹងទទួលបានវិស្សមកាលដ៏សុខស្រួលមួយ៖ "យើងនឹងគេងសំដិលខ្លួនលើឆ្នេរសមុទ្រ"។ យើងពុំបានដឹងថា ពេលយើងគេងលើឆ្នេរសមុទ្រមានក្មេងៗមកផ្ទឹះផ្ទៀល និងព្យាយាមលក់ឥវ៉ាន់ឲ្យយើងឡើយ។"*
>
> (ស្រ្តី អ្នកត្រូវបានសម្ភាស ជនជាតិអង់គ្លេស អាយុ ២២ ឆ្នាំ)

> ***"ចាំបាច់ត្រូវតែមាន [ការធ្វើសកម្មភាព] រួមគ្នារវាងអ្នកធ្វើដំណើរ និង រដ្ឋាភិបាលក្នុងមូលដ្ឋាន។"***
>
> បុរស អ្នកត្រូវបានសម្ភាស ជនជាតិ អាមេរិក អាយុ ២៦ ឆ្នាំ

## អ្នកទេសចរបានឆ្លើយតបជាវិជ្ជមានចំពោះសារការសម្ភារៈទំនាក់ទំនងស្តីពី ការរក្សាសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ហើយសារនេះបានជះឥទ្ធិពលជាវិជ្ជមានលើអាកប្បកិរិយាអ្នកទេសចរ។

ជាទូទៅកម្រិតការយល់ដឹងរបស់អ្នកទេសចរអំពីប្រយោគ "ការរក្សាសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" មិនសូវមានកម្រិតខ្ពស់ប៉ុន្មានទេ។ មានអ្នកត្រូវបានសម្ភាសភាគតិចប៉ុណ្ណោះ និងត្រឹមតែ ២៦% នៃអ្នកឆ្លើយតបការស្ទាបស្ទង់មតិដែលធ្លាប់ឮពាក្យសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ឬធ្លាប់ឃើញការផ្សព្វផ្សាយពាណិជ្ជកម្មស្តីពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។ នេះពុំមែនជារឿងគួរឲ្យភ្ញាក់ផ្អើលឡើយ បើយោងទៅលើរយៈពេលដ៏ខ្លីនៃការផ្សព្វផ្សាយមានកម្រិតកំណត់របស់សារទាំងនេះក្នុងទីផ្សារ។ ទោះជាយ៉ាងនេះក្តី អ្នកទេសចរ អាចយល់អត្ថន័យពាក្យនេះយ៉ាងទូលំទូលាយ ហើយមានបំណងចង់សិក្សាបន្ថែមទៀត។

គួរឲ្យកត់សម្គាល់ថា ការយល់ដឹងអំពីការរក្សាសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងការយល់ដឹងអំពីគោលការណ៍ ដែលជាគ្រឹះនៃទស្សនៈនេះហាក់ដូចជាជះឥទ្ធិលដ៏គួរឲ្យកត់សម្គាល់លើឥទ្ធិពលលើអាកប្បកិរិយាអ្នកទេសចរ។ ឧទាហរណ៍ មានតែ ៣% នៃអ្នកឆ្លើយតបការស្ទាបស្ទង់មតិដែលធ្លាប់ឮពីការរក្សាសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍បានបញ្ជាក់ថា ពួកគេបានឲ្យលុយកុមារសុំទាន (ធៀបនឹង ១៥% នៃអត្រាទូទៅ) និងមានតែ ៩% (ធៀបនឹង ២៨% នៃអត្រាទូទៅ) ដែលបានទិញឥវ៉ាន់ពីកុមារ។ ស្រដៀងគ្នានេះដែរ មានតែ ៩% នៃអ្នកបានដឹងពីការរក្សាសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ដែលបានថតរូបកុមារ (ធៀបនឹង ២៦% នៃអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិជាទូទៅ) ៧% (ធៀបនឹង ១៥% នៃអត្រាទូទៅ) ដែលបានទៅទស្សនា មណ្ឌលថែទាំ និងត្រឹមតែ ៤% (ធៀបនឹង ១២%) បានរាយការណ៍ថា បានទៅទស្សនាទីប្រជុំជនក្រីក្រ ឬបាន "ធ្វើទេសចរណ៍នៅតំបន់ប្រជុំជនក្រីក្រ" (សូមមើលរូបភាពទី ២)។ រូបភាពទី ២ ខាងក្រោមគឺជាតួរលេខលម្អិតបន្ថែមលើរូបភាពទី ១ (ខាងលើ) រវាងអ្នកដែលបានដឹងអំពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងអ្នកដែលពុំដឹង។ ការរកឃើញបាន បង្ហាញភស្តុតាងយ៉ាងច្បាស់ថា អ្នកទេសចរដែលធ្លាប់បានដឹងអំពីសារស្តីពីការរក្សាសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ច្រើនតែមិនសូវចូលរួមក្នុងអន្តរកម្មទាំងឡាយណា ដែលអាចធ្វើឲ្យកុមារងាយរងគ្រោះត្រូវប្រឈមនឹងគ្រោះថ្នាក់ នៃការរំលោភបំពានដោយមិនដឹងខ្លួន។

## រូបភាពទី ២

# ការយល់ដឹងរបស់អ្នកទេសចរ អំពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និង បទពិសោធន៍ជាមួយកុមារក្នុងមូលដ្ឋាន




ភាគច្រើននៃការឆ្លើយតបចំពោះសម្ភារៈយុទ្ធនាការ សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ មានលក្ខណៈជាវិជ្ជមាន ហើយបានបង្ហាញនូវការគាំទ្រក្នុងកម្រិតដ៏ខ្ពស់ចំពោះការផ្តួចផ្តើមគំនិតនេះ។ យោបល់ខាងក្រោម ចង្អុលបង្ហាញឲ្យឃើញអំពីតម្រូវការដែលយើងអាចមើលឃើញក្នុងចំណោមអ្នកទេសចរដែលចង់ឲ្យមានយុទ្ធនាការ និងផលប៉ះពាល់ជាវិជ្ជមានដែលយុទ្ធនាការនេះនឹងអាចមានចំពោះអាកប្បកិរិយារបស់ពួកគេ៖

> *“ខ្ញុំសង្ឃឹមថា ខ្ញុំនឹងបានដឹងកាន់តែច្រើន អំពីរបៀបដែលខ្ញុំត្រូវប្រព្រឹត្តពេលខ្ញុំបានឃើញសម្ភារៈទាំងអស់នេះ ប្រហែលជាសម្ភារៈទាំងនេះ ជួយបើកភ្នែកឲ្យខ្ញុំមើលឃើញ ពេលខ្ញុំឃើញអ្វីម៉្យាងក្នុងលក្ខណៈនេះ។ វាធ្វើឲ្យអ្នកគិតថា៖ “អូពិតមែនហើយ ខ្ញុំអាចសម្លឹងរកចំណុចទាំងនេះ ហើយធ្វើសកម្មភាពបាន” ។”*
> (ស្ត្រី អ្នកត្រូវបានសម្ភាស ជនជាតិ ន័រវេ អាយុ ៣០ ឆ្នាំ)

> *“រឿងរ៉ាវទាំងនេះល្អណាស់។ ខ្ញុំនិងមិត្តភក្តិខ្ញុំអាចសន្យា [ថានឹងដើរតាមសកម្មភាពដែលបានគូសបញ្ជាក់]។ វាពិតជាល្អមែន។”* (បុរស អ្នកត្រូវបានសម្ភាស ជនជាតិកូរ៉េ អាយុ ២៨ ឆ្នាំ)



# សន្និដ្ឋាន

ថ្វីបើនេះជាការឆ្លុះបញ្ចាំងក្នុងការសិក្សាកម្រិតតូចក្តី ការរកឃើញទាំងនេះជួយពង្រឹង និងអះអាងបន្ថែមលើការសន្និដ្ឋាន ដែលមាននៅក្នុងឯកសារ *សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍៖ ទស្សនៈរបស់ភ្ញៀវទេសចរ* (អង្គការទស្សនៈពិភពលោក ឆ្នាំ ២០១២)។ ដោយឡែក ការសិក្សានេះផ្តល់ភស្តុតាងស្តីពីចំណាប់អារម្មណ៍ និង ការចូលរួមកម្រិតខ្ពស់របស់អ្នកទេសចរ លើបញ្ហាស្តីពីការកេងប្រវ័ញ្ចលើកុមារ ហើយជាលទ្ធផល ចំណុចនេះក៏ស្តែងចេញឲ្យឃើញនូវអារម្មណ៍ទទួលខុសត្រូវរួមដ៏រឹងមាំ របស់ពួកគេ ដើម្បីជួយការពារកុមារផងដែរ។

ការស្រាវជ្រាវចង្អុលបង្ហាញឲ្យឃើញថា អ្នកទេសចរបានដឹងថា មានការរំលោភបំពាន និងការកេងប្រវ័ញ្ចចំពោះកុមារកើតមានក្នុងវិស័យទេសចរណ៍។ មិនមានអ្វីគួរឲ្យសង្ស័យទេថា ការយល់ដឹងនេះ គឺជាលទ្ធផលនៃជោគជ័យរបស់យុទ្ធនាការ ដែលផ្តោតការ យកចិត្តទុកដាក់ដោយផ្ទាល់លើការរំលោភបំពានផ្លូវភេទកុមារក្នុងវិស័យទេសចរណ៍។ យុទ្ធនាការនេះអំពាវនាវឲ្យអ្នកទេសចរកំណត់ និងរាយការណ៍អំពីករណី រំលោភបំពានផ្លូវភេទកុមារ ប្រសិនបើពួកគេឃើញករណីនេះកើតឡើង។ ជាការពិតណាស់ ការស្រាវជ្រាវនេះបង្ហាញឲ្យឃើញនូវគំនិតយ៉ាងច្បាស់ដែលបង្ហាញដោយអ្នកទេសចរ មួយចំនួនថា តាមរយៈការមិនចូលរួមក្នុង "ទេសចរណ៍ផ្លូវភេទកុមារ" ពួកគេគឺជាអ្នកទេសចរប្រកបដោយការទទួលខុសត្រូវរួចជាស្រេចទៅហើយ។

ប៉ុន្តែការស្រាវជ្រាវរកឃើញថា អ្នកទេសចរមានការយល់ដឹងតិចតួចថាអាកប្បកិរិយា និងអន្តរកម្មដែលមើលទៅហាក់គ្មានកំហុសជាច្រើនជាមួយកុមារ អាចចូលរួមវិភាគទានដោយមិនដឹងខ្លួនចំពោះភាពងាយរងគ្រោះរបស់កុមារពីការរំលោភបំពានផ្លូវភេទ។ ឧទាហរណ៍ អ្នកទេសចរពុំបានមើលឃើញលទ្ធភាពដែលកុមារសុំទាននៅតាមផ្លូវម្នាក់ អាចក្លាយជាជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទនោះឡើយ។ អ្នកទេសចរជាច្រើនក៏ពុំបានដឹងថាការទៅទស្សនាកុមារក្នុង "មណ្ឌលកុមារកំព្រា" អាចមានផលប៉ះពាល់យ៉ាងខ្លាំងដល់សុខុមាលភាពកុមារ ហើយទេសចរណ៍ប្រភេទនេះបង្កើនលទ្ធភាពឲ្យជនប្លែកមុខដែលមិនបានទទួលការត្រួតពិនិត្យអាចមានលទ្ធភាពចូលទៅរកកុមារងាយរកគ្រោះបំផុតក្នុងសង្គមដោយរបៀបណានោះដែរ។ មានសំណួរត្រូវលើកឡើងថាតើមិនជាការមានប្រសិទ្ធភាពជាងក្នុងការទប់ស្កាត់ការរំលោភបំពានកុំឲ្យកើតឡើងតាំងពីដំបូង ជាជាងការកំណត់ និងរាយការណ៍ការរំលោភបំពានពេលរឿងទាំងនោះកើតឡើងហើយ ឬយ៉ាងណា។ សម្រាប់កុមារណាម្នាក់ ជម្រើសខាងក្រោយនេះពិតជារឿងហួសពេលប្រកបដោយសោកនាដកម្មសម្រាប់គេ។

អ្នកទេសចរជាច្រើនបង្ហាញកង្វល់យ៉ាងជ្រាលជ្រៅ អំពីស្ថានភាពរបស់កុមារងាយរងគ្រោះនៅពេលធ្វើដំណើរនៅក្នុងតំបន់ នេះដោយបង្ហាញឲ្យឃើញនូវភាពក្រៀមក្រំ ការខកចិត្ត អារម្មណ៍មានកំហុស និងភាពអល់អែក ពេលមើលឃើញកុមារសុំទាន និងធ្វើការនៅក្នុងទីកន្លែងគោលដៅទេសចរណ៍។ ប៉ុន្តែជារឿយៗ អ្នកទេសចរទាំងនេះពុំបានចាត់ទុកស្ថានភាពដែលធ្វើឲ្យគ្រាំគ្រាបេះដូង ទាំងអស់នេះថាជាការកេងប្រវ័ញ្ចនោះទេ ប៉ុន្តែផ្ទុយទៅវិញពួកគេចាត់ទុកថា នេះគឺជាតថភាពដ៏សែនលំបាកបង្កឡើងដោយ កាលៈទេសៈ។ ជារឿងសមហេតុផលដែលយើងត្រូវមើលឃើញថា តើហេតុអ្វីអ្នកធ្វើដំណើរពីបរទេសមិនអាចយល់ច្បាស់អំពីបញ្ហាក្នុងមូលដ្ឋាន ហើយត្រូវពឹងផ្អែកលើព័ត៌មានដែលផ្តល់ទៅឲ្យពួកគេ។

យើងទទួលស្គាល់ថា អាចមានការលំបាក ក្នុងការបែងចែករវាងស្ថានភាពដែលមនុស្សធំណាម្នាក់ដែលដាក់កុមារចូលទៅក្នុងស្ថានភាពកេងប្រវ័ញ្ចដោយចេតនាដូចជា ឲ្យកុមារសុំទាន និងលក់ឥវ៉ាន់តាមចិញ្ចើមថ្នល់ ជាមួយនឹងស្ថានភាពដែល កុមារធ្វើសកម្មភាពចេញពីឆន្ទៈរបស់ខ្លួន។ ទោះជាយ៉ាងនេះក្តី ពិតជាគ្មានអ្វីគួរឲ្យសង្ស័យទេថា គ្រប់កុមារទាំងអស់នៅក្នុងស្ថានភាពទាំងនេះសក្តិសមនឹងបានទទួលដំណោះស្រាយប្រសើរជាងនេះ។ ស្រដៀងគ្នានេះដែរ ស្របពេលដែលទីភ្នាក់ងារការពារកុមារកំពុងងាកចេញពីការថែទាំក្នុងស្ថាប័នកុមារងាយរងគ្រោះ ឆ្ពោះទៅរកជម្រើសការថែទាំជំនួសនៅក្នុងគ្រួសារ និងសហគមន៍ កំណើនទេសចរណ៍ និងការគាំទ្រផ្នែកហិរញ្ញវត្ថុចំពោះ "មណ្ឌលកុមារកំព្រា" គឺជាការប្រឆាំងនឹងផលិតភាព ឬអាក្រក់ជាងនេះទៅទៀតអាចជាការកេងប្រវ័ញ្ច។

បើយោងទៅលើចំណុចដែលថា អ្នកទេសចរបង្ហាញយ៉ាងច្បាស់ថា ពួកគេចង់ដឹងកាន់តែច្រើនថែមទៀតអំពី ការកេងប្រវ័ញ្ចលើកុមារ និងចង់ក្លាយខ្លួនជាអ្នកធ្វើដំណើរដែលការពារសុវត្ថិភាពកុមារ នោះជាឱកាសល្អបំផុតសម្រាប់ ារងារនេះ។ អ្វីដែលជាដំណឹងល្អគឺថា ការស្រាវជ្រាវបានបង្ហាញឲ្យឃើញ នូវចំណងទាក់ទងយ៉ាងច្បាស់រវាងបទពិសោធន៍ជាមួយសារស្តីពីការរក្សា

សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ជាមួយនឹងអាកប្បកិរិយា និងការសម្រេចចិត្តកាន់តែប្រសើរជុំវិញបញ្ហាទាក់ទងជាមួយកុមារ។ ឧទាហរណ៍ អ្នកដែលធ្លាប់មានបទពិសោធន៍ជួបជាមួយសារស្ដីពីការរក្សាសុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍ មិនសូវឲ្យលុយដល់កុមារសុំទាន និងមិនសូវទៅទស្សនកិច្ចនៅ "មណ្ឌលកុមារកំព្រា" នោះឡើយ។ នោះមានន័យថា សាររបស់យុទ្ធនាការបានទទួលលទ្ធផលហើយ។

ការបិទភ្ជិតគំលាតផ្នែកការយល់ដឹងនេះ ពាក់ព័ន្ធជាពិសេសនៅពេលយើងគិតថា គឺកុមារទាំងអស់នេះហើយដែលងាយរងគ្រោះបំផុត និងត្រូវប្រឈមគ្រោះថ្នាក់ចំពោះការកេងប្រវ័ញ្ចក្នុងទម្រង់ធ្ងន់ធ្ងរបំផុត រួមទាំងការរំលោភបំពានផ្លូវភេទផងដែរ។ ជាការល្អដែលចាំបាច់ត្រូវធ្វើសកម្មភាព ដើម្បីកាត់បន្ថយភាពងាយរងគ្រោះទាំងអស់នេះ មុនពេលស្ថានភាពក្លាយជាអាក្រក់សម្រាប់កុមារណាម្នាក់។

ការរក្សាសុវត្ថិភាពកុមារ ក៏ផ្តល់អត្ថប្រយោជន៍ផ្នែកអាជីវកម្មផងដែរ។ ការស្រាវជ្រាវបានសង្កត់ធ្ងន់ថា អន្តរកម្មជាមួយកុមារ អាចជួយបង្កើន ឬបំបាត់បទពិសោធន៍ការធ្វើដំណើររបស់អ្នកទេសចរ។ អ្នកទេសចរជាច្រើន បានពិពណ៌នាថា ការលេងនិងជជែកកំសាន្តជាមួយកុមារ គឺជាបទពិសោធន៍មួយដែលគួរជាទីចងចាំបំផុត ក្នុងចំណោមបទពិសោធន៍ដទៃទៀតរបស់ពួកគេ។ ហេតុនេះប្រហែលជាមិនគួរឲ្យភ្ញាក់ផ្អើលទេដែលថា ការមើលឃើញភាពឈឺចាប់របស់កុមារអាចប្រែក្លាយទៅជាអារម្មណ៍ ប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរយ៉ាងងាយស្រួល ដែលជាលទ្ធផលធ្វើឲ្យមានការសម្រេចចិត្ត ចាកចេញពីគោលដៅទេសចរណ៍មុនពេលគ្រោងទុក និងការសន្យាថាមិនត្រឡប់មកកាន់ទៅទីនោះម្តងទៀត។ អារម្មណ៍ដ៏ខ្លាំងទាំងអស់នេះជះឥទ្ធិពលលើទស្សនៈយល់ឃើញ របស់អ្នកធ្វើដំណើរចំពោះរដ្ឋាភិបាល សហគមន៍ក្នុងមូលដ្ឋាន ក៏ដូចជាឧស្សាហកម្មទេសចរណ៍ទាំងមូល ដែលពួកគេគិតថា គួរតែមានចំណែកការទទួលខុសត្រូវដើម្បីឆ្លើយតប និងដោះស្រាយបញ្ហាទាំងអស់នេះ។ ថ្វីបើមានអ្នកទេសចរមួយចំនួនមានអារម្មណ៍ថា ពួកគេមិនអាចធ្វើអ្វីបានច្រើនដើម្បីជួយកុមារក្តី ប៉ុន្តែអ្នកទេសចរភាគច្រើនយល់ស្របថា ការទទួលខុសត្រូវចម្បងគឺស្ថិតក្នុងដៃរដ្ឋាភិបាលក្នុងមូលដ្ឋាន និង ឧស្សាហកម្មទេសចរណ៍។ អារម្មណ៍ក្រៀមក្រំ ខកចិត្ត និងអារម្មណ៍អល់អែក មិនមែនត្រឹមតែជាលទ្ធផល កើតចេញពីការយល់ឃើញ អំពីដែនកំណត់ដែលមានក្នុងសមត្ថភាព ក្នុងនាមជាអ្នកទេសចរប៉ុណ្ណោះទេ ប៉ុន្តែក៏ពាក់ព័ន្ធជាមួយកង្វះការទទួលខុសត្រូវដែលស្តែងចេញ និងកង្វះការទទួលខុសត្រូវ ដែលគេគិតស្តីពីសកម្មភាពរបស់អ្នកដើរតួក្នុងមូលដ្ឋាន។ ជាការច្បាស់ណាស់ថា ប្រតិកម្មដ៏ខ្លាំងក្លាទាំងអស់នេះមានឥទ្ធិពលគួរឲ្យកត់សម្គាល់លើបទពិសោធន៍ របស់អ្នកទេសចរ។ ផ្ទុយទៅវិញអ្នកទេសចរដែលមានសមត្ថភាពអាចលើកឡើងនូវអ្វីម្យ៉ាងដែលពួកគាត់អាចធ្វើបានដូចជា ទិញទំនិញពីអាជីវកម្មប្រកបដោយសីលធម៌ និងអាជីវកម្មរបស់សហគមន៍អារម្មណ៍រីករាយ និងសប្បាយចិត្តអំពីសមត្ថភាពរបស់ខ្លួនក្នុងការជួយការពារ ព្រមទាំងចូលរួមវិភាគទានចំពោះសហគមន៍មូលដ្ឋាន និងកុមាររបស់ពួកគេ។

ស្របពេលដែលទេសចរណ៍មកកាន់តំបន់នេះមានការរីកលូតលាស់យ៉ាងឆាប់រហ័ស ហើយឱកាសសម្រាប់ប្រាក់ចំណូល និងការអភិវឌ្ឍមានកំណើនយ៉ាងខ្ពស់ នេះគឺជាឱកាសដ៏ល្អដើម្បីឆ្លុះបញ្ចាំងលើផលប៉ះពាល់ជាអវិជ្ជមានរបស់វិស័យនេះមកលើការកេងប្រវ័ញ្ចចំពោះកុមារ។ ទាំងទេសចរណ៍ និងកុមារក្នុងមូលដ្ឋានមានផលប៉ះពាល់ជាក់ស្តែង និងដោយផ្ទាល់ចំពោះគ្នាទៅវិញទៅមក ហើយបរិស្ថានទេសចរណ៍មានផលប៉ះពាល់គួរឲ្យកត់សម្គាល់ទៅលើថាតើឥទ្ធិពលទាំងនោះមានលក្ខណៈជាការស្ថាបនាឬអត់។ វិស័យទេសចរណ៍ទទួលបានផលប្រយោជន៍យ៉ាងធំធេងពីការធ្វើសកម្មភាពដើម្បីកាត់បន្ថយគ្រោះថ្នាក់ចំពោះកុមារ ដើម្បីធានានូវសុខុមាលភាព និងអនាគតរបស់កុមារ។



# អនុសាសន៍

**១. ត្រូវផ្ដល់ព័ត៌មានបន្ថែមទៀតដល់អ្នកទេសចរ អំពីវិធីដែលកុមារមានភាពងាយ រងគ្រោះចំពោះការរំលោភបំពាន និងការកេងប្រវ័ញ្ចក្នុងវិស័យទេសចរណ៍។**

ថ្វីបើអ្នកទេសចរ ជាច្រើនបានដឹងអំពីការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារក្នុងវិស័យទេសចរណ៍ក្ដី ប៉ុន្តែការយល់ដឹងរបស់ពួកគេពុំបានផ្សារភ្ជាប់រួចជាស្រេច នូវចំណងទាក់ទងរវាងថាតើសកម្មភាពជាក់លាក់មួយចំនួនដែលពួកគេធ្វើ អាចបង្កើន ឬ កាត់បន្ថយគ្រោះថ្នាក់ទាំងនោះ ដោយរបៀបណានោះឡើយ។ ឧទាហរណ៍ ដូចជាអ្នកទេសចរអាចបង្កើនភាពងាយរងគ្រោះរបស់កុមារ និងដាក់កុមារឲ្យប្រឈមគ្រោះថ្នាក់ នៃការរំលោភបំពានតាមរយៈការឲ្យលុយកុមារដែលសុំទាន ឬទៅទស្សនាកុមារងាយរងគ្រោះនៅក្នុងស្ថាប័នផ្ដល់ការថែទាំ។

**២. ត្រូវផ្ដល់ព័ត៌មានច្បាស់លាស់ឲ្យអ្នកទេសចរ អំពីរបៀបដើម្បីធ្វើជាអ្នកធ្វើដំណើរ ដែលការពារសុវត្ថិភាពកុមារ។**

អ្នកទេសចរយកចិត្តទុកដាក់ចំពោះកុមារ និងចង់ធានាបានថាពួកគេផ្ដល់ ផលប៉ះពាល់ជាវិជ្ជមានលើ កុមារក្នុងកន្លែងគោលដៅទេសចរណ៍។ ការស្រាវជ្រាវបានបង្ហាញថា សូម្បីតែព័ត៌មានជាមូលដ្ឋាន ស្ដីពីការរក្សាសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ ក៏អាចជះឥទ្ធិពលជាវិជ្ជមានគួរឲ្យកត់សម្គាល់ និងដោយផ្ទាល់លើអាកប្បកិរិយាទេសចរ ពាក់ព័ន្ធជាមួយកុមារងាយរងគ្រោះផងដែរ។

**៣. ត្រូវផ្ដល់ជម្រើសអ្នកប្រើប្រាស់ និងជម្រើសដទៃទៀតដល់អ្នកទេសចរ ដែលអនុលោមជាមួយគោលការណ៍ការ រក្សាសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍។**

អ្នកទេសចរចង់ក្លាយខ្លួនជាអ្នកធ្វើដំណើរដែលជួយរក្សាសុវត្ថិភាពកុមារ។ ក្រៅពី “អ្វីដែលត្រូវធ្វើ និងអ្វីមិនត្រូវធ្វើ” ចំពោះមុខ អ្នកទេសចរជាច្រើនចង់ឈានមួយជំហានទៀត និងទទួលបានការធានាឲ្យប្រាកដក្នុងចិត្តថា លុយចំណាយលើការទេសចរណ៍របស់ពួកគេអាចជួយ ហើយពុំរារាំងដល់សុវត្ថិភាពកុមារក្នុងតំបន់នោះឡើយ។ ពួកគេចង់បានផលិតផល និងសេវាទេសចរណ៍ដែល គាំទ្រដល់ការបង្កើតឲ្យមានបរិស្ថានទេសចរណ៍ដែលមានសុវត្ថិភាពចំពោះកុមារ។ បន្ថែមលើនេះទៀត ពួកគេចង់មានលទ្ធភាពទទួលបានព័ត៌មានកាន់តែច្រើន ស្ដីពីអាជីវកម្ម និងការផ្ដួចផ្ដើមគំនិតទេសចរណ៍ដែលជួយរក្សាសុវត្ថិភាពកុមារ ដែលពួកគេអាចគាំទ្របាន។

**៤. ត្រូវទទួលស្គាល់ជាសាធារណៈ និងជម្រុញការយល់ដឹងដែលចាត់ទុកថាសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ គឺជាការទទួលខុសត្រូវរួមគ្នារវាងរដ្ឋាភិបាល ឧស្សាហកម្មទេសចរណ៍ និងអ្នកធ្វើដំណើរ។**

អ្នកទេសចរ មានអារម្មណ៍ថាខ្លួនមានចំណែកក្នុងការធានាឲ្យបានថាពួកគេពុំជម្រុញដល់ការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារឲ្យកើតមានឡើយ។ ស្របពេលជាមួយគ្នានេះដែរ ពួកគេបង្ហាញ ឲ្យឃើញនូវភាពអល់អែកចំពោះភាពមានកម្រិតកំណត់របស់ខ្លួន ហើយមានអារម្មណ៍ថាបញ្ហាដ៏ធំនេះទាមទារនូវការទទួល ខុសត្រូវជាសកម្ម ដែលត្រូវធ្វើឡើងដោយរដ្ឋាភិបាលក្នុងមូលដ្ឋាន និងឧស្សាហកម្មទេសចរណ៍។ ការស្រាវជ្រាវបានបង្ហាញ ឲ្យឃើញនូវរូបភាពជាអវិជ្ជមាន ដែលអ្នកទេសចរណ៍ស្រូបយកនៅពេលពួកគេមានអារម្មណ៍ថាការកេងប្រវ័ញ្ចលើកុមារ ត្រូវបានចាត់ទុកជារឿងធម្មតា ពីសំណាក់សហគមន៍មូលដ្ឋាន។ ហេតុនេះ ជាការសំខាន់ណាស់ដែលត្រូវផ្ដល់ឲ្យពួកគេនូវ ព័ត៌មានស្ដីពីកិច្ចខិតខំ និងការផ្ដួចផ្ដើមគំនិតដែលកំពុងត្រូវបានធ្វើឡើងជាបន្ត។ ព្រមជាមួយនេះ ក៏មានតម្រូវការឲ្យមានការទទួលខុសត្រូវរួមគ្នាដែលត្រូវប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក និងទទួលស្គាល់ជាសាធារណៈ ដើម្បីឲ្យអ្នកទេសចរប្រាកដក្នុងចិត្តចំពោះការប្ដេជ្ញាចិត្ត និងការងារដែលត្រូវបានបន្តធ្វើឡើងពីសំណាក់វិស័យទេសចរណ៍។

# ឯកសារយោង


Bliss, S. (2006) *Child Labour in Tourism Industry in Developing Countries*. Proceedings of the Social Educators' Association of Australia Biennial National Conference, Brisbane, January 12 2006.

Csáky, C. (2009) *Keeping Children Out of Harmful Institutions:* Why we should be investing in family-based care. London: Save the Children Fund.

Crouch, D., Jackson, R. and Thompson, F. (eds) (2005) *The Media and the Tourist Imagination: Converging Cultures*. Oxon, UK: Routledge.

Euromonitor International (2012) Tourism Flows Inbound in Thailand, August 2012. Accessed 6/10/13, www.euromonitor.com/travel-and-tourism-in-thailand/report.

George, B.P. and Panko, T. R. (2011) Child sex tourism: Facilitating conditions, legal remedies, and other interventions. *Vulnerable Children and Youth Studies*, 6(2): 134-143.

Guiney, T. (2012) 'Orphanage Tourism' in Cambodia: When Residential Care Centres Become Tourist Attractions. *Pacific News*, 38: 9-14.

Jenkins, O. (2003) Photography and travel brochures: the circle of representation. *Tourism Geographies*, 5 (3): 305-328.

Keane, K. (2006) *Street-Based Child Sexual Exploitation in Phnom Penh and Sihanoukville: A Profile of Victims*. Action Pour Les Enfants, Phnom Penh Cambodia. Accessed 2/10/13, www.humantrafficking.org/publications/456

Lao National Tourism Administration (2010) *2010 Statistical Report on Tourism in Laos*. Planning and Cooperation Department, Tourism Statistics Division: Lao PDR.

Lao People's Democratic Republic (2012) Presentation at Project Childhood Coordinating Committee, Bangkok, 10 July 2012.

Long, P. and Robinson, M. (2009) Tourism, Popular Culture and the Media. In Jamal, T. and Robinson, M. (Eds.) *The SAGE Handbook of Tourism Studies*. London, Thousand Oaks, New Delhi & Singapore: SAGE Publications, Chapter 6: 98-114.

Ministry of Tourism Cambodia (2012) *Tourism Statistics Annual Report*. Accessed 8/10/13, www.tourismcambodia.org/images/mot/statistic_reports/tourism_statistics_annual_report_2012.pdf.

Ministry of Culture, Sports and Tourism, Vietnam (2012) *Tourism Statistics*. Accessed 8/10/13, www.vietnamtourism.gov.vn/english/index.php?cat=012041&itemid=6308.

Ministry of Tourism and Sports, Thailand (2012) Tourism Statistics.

Mowforth, M. and Munt, I. (2009) *Tourism and sustainability: development, globalization and new tourism in the Third World* (3rd edn). London: Routledge.

Sánchez Taylor, J. (2010) Sex Tourism and Inequalities. In Coles, S. and Morgan, N. (Eds) *Tourism and Inequality: Problems and Prospects*. Oxon, UK: CABI Publishing.

Scheyvens, R. (2002). Backpacker Tourism and Third World Development. *Annals of Tourism Research* 29(1): 144-164.

Smith, V. (ed.) (1989) *Hosts and Guests: The Anthropology of Tourism*. Philadelphia, University of Pennsylvania Press.

Telfer, D. & Sharpley, R. (2008) *Tourism and Development in the Developing World*. Milton Park & New York: Routledge.

Tepelus, C.M. (2008) Social Responsibility and Innovation on Trafficking and Child Sex Tourism: Morphing of Practice into Sustainable *Tourism Policies? Tourism and Hospitality Research*, 8(2): 98-115.

United Nations Children's Fund (2012) Child Maltreatment: Prevalence, Incidence and Consequences in East Asia and the Pacific: A Systematic Review of Research. *Measuring and Monitoring Child Protection Systems: Proposed Core Indicators for the East Asia and Pacific Region*, Strengthening Child Protection Series No. 1., UNICEF EAPRO, Bangkok, 2012.

UNWTO *Tourism Highlights* (2013) Madrid, Spain: World Tourism Organization. Accessed, 8/8/13, www.unwto.org/facts/menu.html.

World Travel and Tourism Council (2013a) *Travel and Tourism Economic Impact 2013: Cambodia*. Accessed 1/10/13, www.wttc.org/research/.

World Travel and Tourism Council (2013b) *Travel and Tourism Economic Impact 2013: Laos*. Accessed 27/9/12, www.wttc.org/research/.

World Travel and Tourism Council (2013c) *Travel and Tourism Economic Impact 2013: Thailand*. Accessed 27/9/12, www.wttc.org/research/.

World Travel and Tourism Council (2013d) *Travel and Tourism Economic Impact 2013: Vietnam*. Accessed 27/9/12, www.wttc.org/research/.

World Vision (2012) *Child Safe Tourism: The Tourist Perspective. www.childsafetourism.org/wp-content/uploads/2013/10/Tourist-Perspective-report.pdf.*


BẢO VỆ, CHĂM SÓC TRẺ EM
LÀ TRÁCH NHIỆM
CỦA GIA ĐÌNH & XÃ HỘI

# លក្ខណៈប្រជាសាស្ត្រនៃអ្នកចូលរួមការស្រាវជ្រាវ

## សញ្ជាតិ និងភាសា

ក្នុងចំណោមឯកសារស្ទាបស្ទង់មតិទាំង ២០៩ ច្បាប់ដែលត្រូវបានបំពេញ ១០ ច្បាប់គឺជាភាសាកូរ៉េ (៥%) ៩ ច្បាប់ជាភាសាចិន (៤%) ៦ ច្បាប់ជាភាសាជប៉ុន (៣%) និងចំនួនដែលនៅសល់ គឺជាភាសាអង់គ្លេស។ ថ្វីបើទម្រង់ស្ទាបស្ទង់មតិជាភាសាអង់គ្លេសត្រូវបានបំពេញក្នុងអត្រាខ្ពស់ជាងការស្ទាបស្ទង់មតិដែលពុំមែនជាភាសាអង់គ្លេសក្តី តួលេខលម្អិតផ្នែកប្រជាសាស្ត្រ បង្ហាញឲ្យឃើញនានាភាពគួរឲ្យកត់សម្គាល់។ នានាភាពក្នុងកម្រិតប្រហាក់ប្រហែលគ្នានេះដែរ ត្រូវបានមើលឃើញនៅក្នុងការសម្ភាស។ ក្នុងចំណោមកិច្ចសម្ភាសសរុបទាំង ៣៤ (មួយចំនួនត្រូវបានធ្វើឡើងក្នុងក្រុមតូចៗ) មានការសម្ភាសចំនួន ៥ (ជាមួយអ្នកចូលរួម ៨ នាក់) ត្រូវបានធ្វើឡើងជាភាសាចិន ការសម្ភាសចំនួន ៥ (ជាមួយអ្នកចូលរួម ៨ នាក់) ត្រូវបានធ្វើឡើងជាភាសាជប៉ុន ការសម្ភាសចំនួន ៤ (ជាមួយអ្នកចូលរួមចំនួន ៦ នាក់) ត្រូវបានធ្វើឡើងជាភាសាកូរ៉េ និងការសម្ភាសចំនួន ២០ (ជាមួយអ្នកចូលរួមចំនួន ៣៧ នាក់) ត្រូវបានធ្វើឡើងជាភាសាអង់គ្លេស។

ក្នុងចំណោមអ្នកឆ្លើយតបការស្ទាបស្ទង់មតិ មានអ្នកតំណាងសញ្ជាតិសរុបចំនួន ៣៦ សញ្ជាតិ ដោយភាគច្រើនអ្នកចូលរួមមកពីប្រទេសអូស្ត្រាលី (២៥%) ចក្រភពអង់គ្លេស (១៣%) និងសហរដ្ឋអាមេរិក (៨%)។ អ្នកចូលរួមដទៃទៀតមកពីប្រទេសកូរ៉េ (៥%) ប្រទេសចិន (៤%) ប្រទេសអាឡឺម៉ង់ (៤%) ប្រទេសបារាំង (៤%) ប្រទេសឥណ្ឌា (៤%) និងប្រទេសញូហ្សេឡែន (៤%)។ តួលេខលម្អិតផ្នែកប្រជាសាស្ត្រសម្រាប់ប្រទេសតាំងទីលំនៅ បង្ហាញឲ្យឃើញរូបភាពប្រហាក់ប្រហែលគ្នានេះដែរ ថ្វីបើអ្នកឆ្លើយតបការស្ទាបស្ទង់មតិមួយចំនួន រស់នៅក្នុងនាមជាជនបរទេសក្នុងប្រទេសមួយផ្សេង ក្រៅពីប្រទេសកំណើតរបស់ខ្លួន ហើយនេះ ក៏ពុំមែនជារឿងគួរឲ្យភ្ញាក់ផ្អើលសម្រាប់ការសិក្សាដែលពិនិត្យទៅលើអ្នកធ្វើដំណើរនោះដែរ។ ថ្វីបើទំហំសញ្ជាតិ ក្នុងចំណោមអ្នកចូលរួមក្នុងការសម្ភាសមិនមានលក្ខណៈទូលំទូលាយដូចនៅក្នុងការស្ទាបស្ទង់មតិក្តី ប៉ុន្តែមានជនជាតិអឺរ៉ុប និងអាមេរិកខាងជើងក្នុងចំនួនខ្ពស់ប្រហាក់ប្រហែលគ្នានៅក្នុងសំណាក ប៉ុន្តែមានជនជាតិអូស្ត្រាលីតិចជាងឆ្ងាយ ហើយមានចំនួនអ្នកចូលរួមជន ជាតិអាស៊ីក្នុងចំនួនច្រើនជាង។ ក្នុងចំណោមអ្នកត្រូវបានសម្ភាសសរុបចំនួន ៥៩ នាក់ អ្នកត្រូវ បានសម្ភាសភាគច្រើនមកពីចក្រភពអង់គ្លេស (១៥%) សហរដ្ឋអាមេរិក (១៤%) ប្រទេសចិន (១៤%) ប្រទេសជប៉ុន (១៤%) កូរ៉េខាងត្បូង (១០%) ប្រទេសបារាំង (៩%) និងប្រទេសអាឡឺម៉ង់ (៧%) (សូមមើលរូបភាពទីបីខាងក្រោម ស្តីពីការបែងចែកអ្នកចូលរួមក្នុងការស្រាវជ្រាវទៅតាមតំបន់)។

### រូបភាពទី ៣៖



## អាយុ និងយេនឌ័រ

ភាគច្រើននៃអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិមានអាយុចន្លោះពី ២៦-៣០ ឆ្នាំ (២៥%) ឬ ៣១-៣៥ ឆ្នាំ (២១%) ហើយស្ត្រីមានចំនួនច្រើនជាងបុរសបន្តិច ដោយមានអត្រានៃការឆ្លើយតបចំនួន ៥៦% ធៀបនឹង ៤៣%។ ការបែងចែកអ្នកត្រូវបានសម្ភាសទៅតាមយេនឌ័រ និងអាយុ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាគួរឲ្យភ្ញាក់ផ្អើល ដោយមានអត្រា ៤២% នៃគំរូ គឺជាបុរស និង ៥៨% គឺជាស្ត្រី ហើយភាគច្រើន (ប្រមាណ ៥១%) នៃអ្នកចូលរួម មានអាយុស្ថិតនៅក្នុងខ្ទង់ ២០ ដល់ ខ្ទង់ ៣០។

## មុខរបរ

មានមុខរបរផ្សេងៗជាច្រើន ត្រូវបានលើកឡើងដោយអ្នកចូលរួមក្នុងការស្ទាបស្ទង់មតិ ដោយគ្របដណ្តប់លើមុខរបរវិជ្ជាជីវៈ ក៏ដូចជាឧស្សាហកម្មសេវា និងពាណិជ្ជកម្មផ្សេងៗជាច្រើន។ ចំណាត់ប្រភេទ សាមញ្ញបំផុតនៃមុខរបរដែលអ្នកឆ្លើយតប ការស្ទាបស្ទង់មតិបានរៀបរាប់មាន “សិស្ស/និស្សិត” (៧,២% ) “លេខា/រដ្ឋបាលការិយាល័យ” (៦,៧%) “បង្រៀន” (៥,៧%) “ព័ត៌មានវិទ្យា/ការរចនាគេហទំព័រ” (៤,៣%) “អ្នកធ្វើផ្ទះ” (៣,៨%) “អ្នកលក់រាយ/អ្នកលក់” (៣,៨%) និង “និវត្តន៍ជន” (៣,៤%)។ យើងឃើញថាហាក់មានទំនោរខ្ពស់បន្តិចក្នុង ចំណោមអ្នកចូលរួមការសម្ភាសទៅរកមុខរបរវិជ្ជាជីវៈ  និង (បើតាមការប្រៀបធៀប) មានកម្រិតការអប់រំខ្ពស់ជាងបន្តិច (តាមពិត សម្រាប់អ្នកឆ្លើយតបការស្ទាបស្ទង់មតិ អ្នកត្រូវបានសម្ភាសជាច្រើន គឺជានិស្សិតសាកលវិទ្យាល័យ ឬអ្នកទើបបញ្ចប់ការសិក្សាសាកលវិទ្យាល័យនាពេលថ្មីៗ)។ ប៉ុន្តែការស្រាវជ្រាវបន្ថែមទៀតចាំបាច់ត្រូវកំណត់ថាតើអថេរនេះជះឥទ្ធិពលកម្រិតណាទៅលើឥរិយាបថរបស់អ្នកធ្វើដំណើរ។

## ផែនការធ្វើដំណើរ និងប្រភេទនៃការធ្វើដំណើរ

សមមាត្រដ៏ធំនៃអ្នកឆ្លើយតបការស្ទាបស្ទង់មតិ ធ្វើដំណើរក្នុងក្រុមទេសចរណ៍ (២៩,២%) ឬជាមួយមិត្តភក្តិ (២៩,២%) ជាមួយដៃគូ (២៨,២%) ឬធ្វើដំណើរម្នាក់ឯង (២៤,៩%)។ ក្នុងចំណោមអ្នកឆ្លើយតប ការស្ទាបស្ទង់មតិ ពុំសូវមានអ្នកធ្វើដំណើរជាមួយកូនៗ (១១%) ឬមិត្តរួមការងារ (៥,៣%) នោះទេ។ ទម្រង់នេះ ក៏ត្រូវបានឆ្លុះបញ្ចាំងក្នុងចំណោមសំណាកសម្រាប់ការសម្ភាសផងដែរ ដោយអ្នកត្រូវបានសម្ភាសភាគច្រើនធ្វើដំណើរជាមួយមិត្តភក្តិ (៤៩%) ឬគ្រួសារ (១៩%) ឬតែម្នាក់ឯង (១២%) យ៉ាងហោចណាស់ក្នុងពេលខ្លះ ថ្វីបើប្រហែលដោយសារតែរយៈពេលនៃការសម្ភាស មានអ្នកត្រូវបានសម្ភាសចំនួនតិចតួចដែលបានលើកឡើងថាធ្វើដំណើរតាមក្រុមទេសចរណ៍ (១៤%) ជាមួយកូនៗ (៦%) ឬជាមួយអ្នករួមការងារ (៣,៤%)។ ថ្វីបើការសិក្សានេះមិនត្រូវបានតាក់តែងឡើងឲ្យមានលក្ខណៈជាតំណាងក្តី ប៉ុន្តែហាក់មានចំណងទាក់ទងយ៉ាងទូលំទូលាយរវាងរបាយទាំង អស់នេះ ជាមួយនឹងរបាយដែលយើងឃើញនៅក្នុងស្ថិតិទេសចរណ៍ប្រចាំតំបន់ (ដូចជា Euromonitor ឆ្នាំ ២០១២ ជាដើម)។

ភាគច្រើនលើសលប់នៃអ្នកឆ្លើយតបការស្ទាបស្ទង់មតិ បានដាក់គោលបំណងចម្បងនៃការធ្វើដំណើររបស់ពួកគេថាជាវិសមកាល/ការសម្រាកលំហែ (៧៩,៩%) ថ្វីបើអ្នកចូលរួមមួយចំនួនក៏ធ្វើដំណើរដើម្បីធ្វើការងារ (១៣,៩%) ដើម្បីសួរសុខទុក្ខមិត្តភក្តិ និងគ្រួសារ (៤,៨%) ដើម្បីធ្វើការងារស្ម័គ្រចិត្ត (<១%) ឬសម្រាប់គោលបំណងសាសនា (<១%) (សូមមើលរូបភាពទី ៤ ខាងក្រោម)។ ស្រដៀងគ្នានេះដែរ ភាគច្រើននៃអ្នកត្រូវបានសម្ភាស គឺមកប្រទេសថៃដើម្បីសម្រាកវិស្សមកាល ថ្វីបើយ៉ាងហោចណាស់ ៨% ក៏ធ្វើការងារស្ម័គ្រចិត្តមួយចំនួនផងដែរ។ ឆ្លើយតបជាមួយ អត្រាដ៏ខ្ពស់នៃអ្នកដើរកំសាន្ត សកម្មភាពនានាដែលត្រូវបានរៀបរាប់ក្នុងកម្រិតខ្ពស់នៅក្នុងផែនការធ្វើដំណើររបស់អ្នកឆ្លើយតបការស្ទាបស្ទង់មតិរួមមានការទៅទស្សនកិច្ចទីតាំងប្រវត្តិសាស្ត្រ និងវប្បធម៌ (៨១,៨%) ទិញទំនិញ (៦២,២%) ទៅលេងឆ្នេរសមុទ្រ (៥៣,៦% បានទៅលេងរួចហើយ ឬកំពុងតែទៅលេង) សកម្មភាពផ្សេងព្រេង (៣៤%) ទៅទស្សនាឧទ្យានជាតិ (២៧,៨%) និងទៅលេងក្លិបរាត្រី (២០,៦%)។ ថ្វីបើអ្នកត្រូវបានសម្ភាសពុំត្រូវបានសាកសួរចំៗអំពីចំណុចនេះក្តី ប៉ុន្តែមានអ្នកត្រូវបានសម្ភាសជាច្រើនពន្យល់ប្រាប់ថាពួកគេប្រើប្រាស់ទីក្រុងបាងកកជាមូលដ្ឋានដើម្បីរុករកទីតាំងវប្បធម៌ និងបរិស្ថានដទៃទៀត (ដូចជាឈៀងម៉ៃ

និងឈៀងរ៉ៃ ភូកេត និងកោះសាម៉ុយជាដើម) ហើយមានចេតនាចង់ធ្វើសកម្មភាពផ្សេងៗដូចជាការជ្រមុជទឹករាក់ (snorkeling) និងការជ្រមុជទឹកជ្រៅ (scuba diving) ចម្អិនអាហារថៃ និងមើលកីឡាប្រដាល់ថៃជាដើម ពេលពួកគេនៅក្នុងប្រទេស។

## រូបភាពទី ៤៖

### គោលបំណងនៃការធ្វើដំណើររបស់អ្នកឆ្លើយតបការស្ទាបស្ទង់មតិ




ទាក់ទងនឹងចំណូលចិត្តផ្នែកកន្លែងស្នាក់នៅ ភាគច្រើននៃអ្នកឆ្លើយតបការស្ទាបស្ទង់មតិបានបញ្ជាក់ថា ពួកគេស្នាក់នៅសណ្ឋាគារផ្កាយ ២-៣ (៤១,២%) សណ្ឋាគារផ្កាយ ៤-៥ (២០,៦%) ឬផ្ទះសំណាក់ (១៨,៧%) (សូមមើលរូបភាពទី ៥)។ ថ្វីបើរបាយចំនួននេះអាចជាលទ្ធផលកើតចេញពីរបាយប្រភេទទីកន្លែងស្ទាបស្ទង់មតិក្តី ចំណុចដែលថាអ្នកចូលរួមដទៃទៀតក៏ស្នាក់នៅក្នុងវីសេត (៥,៣%) កន្លែងស្នាក់សម្រាប់អ្នកទេសចរបែបសន្សំសំចៃ (backpacker) (៤,៣%) ជាមួយគ្រួសារ និងមិត្តភក្តិ (៤,៣%) ឬនៅតាមផ្ទះសំណាក់តាមភូមិ (១,៤%) គឺជាសញ្ញាណចង្អុលបង្ហាញ (ពេលបូកផ្សំជាមួយការឆ្លើយតបខាងលើ) អំពីភាពដ៏ទូលំទូលាយនៃប្រភេទអ្នកធ្វើដំណើរដែលបានចូលរួមក្នុងការសិក្សានេះ។

បន្ថែមលើទស្សនកិច្ចមកកាន់ប្រទេសថៃ ៤២,៦% នៃអ្នកធ្វើដំណើរដែលត្រូវបានស្ទាបស្ទង់មតិ ក៏ធ្លាប់បាន ឬកំពុងតែទៅកាន់ប្រទេសកម្ពុជា ១០,៥% ធ្លាប់បានទៅ ឬកំពុងទៅប្រទេសឡាវ និង ៣៦,៨៤% ធ្លាប់បានទៅ ឬកំពុងទៅប្រទេស វៀតណាមផងដែរ។ អ្នកចូលរួមការស្ទាបស្ទង់មតិជាច្រើនធ្លាប់បានធ្វើដំណើរ ឬកំពុងធ្វើដំណើរនៅក្នុងប្រទេសត្រូវបានស្រាវជ្រាវ ទាំងបី (៣១,១%) ឬទាំងបួន (៤,៣%) ហើយអ្នកធ្វើដំណើរក្នុងចំនួនគួរឲ្យកត់សម្គាល់ (២១,១%) ក៏បានបញ្ជាក់ថាពួកគេកំពុងធ្វើដំណើរទៅបណ្តាប្រទេសដទៃទៀតក្រៅតំបន់ផងដែរ (រួមទាំងអូស្ត្រាលី ចិន ហ្វីជី ហុងកុង ឥណ្ឌា ឥណ្ឌូនេស៊ី ជប៉ុន ម៉ាឡេស៊ី មីយ៉ាន់ម៉ា សិង្ហបុរី និង សហរដ្ឋអាមេរិកផងដែរ)។



# ការស្ទាបស្ទង់មតិជាភាសាអង់គ្លេស

## សូមប្រាប់ព័ត៌មានខ្លះៗអំពីខ្លួនអ្នក៖

១. តើអ្នកអាយុប៉ុន្មាន?

| | | | | |
|---|---|---|---|---|
| ១៨-២០ ☐ | ២១-២៥ ☐ | ២៦-៣០ ☐ | ៣១-៣៥ ☐ | ៣៦-៤០ ☐ |
| ៤១-៤៥ ☐ | ៤៦-៥០ ☐ | ៥១-៥៥ ☐ | ៥៦-៦០ ☐ | ៦០-៦៥ ☐ |
| ៦៦-៧០ ☐ | ៧១-៧៥ ☐ | ៧៦-៨០ ☐ | ៨១-៨៥ ☐ | ៨៦ + ☐ |

២. តើអ្នកជា៖ ប្រុស ☐ ស្រី ☐

៣. តើអ្នកមានមុខរបរអ្វី? ____________________

៤. តើអ្នកមានសញ្ជាតិអ្វី? ____________________

៥. តើអ្នកស្នាក់នៅក្នុងប្រទេសណា? ____________________

## សូមប្រាប់ព័ត៌មានខ្លះៗអំពីការធ្វើដំណើររបស់អ្នក៖

៦. តើអ្នកកំពុងធ្វើដំណើរ (សូមជ្រើសរើសគ្រប់ចម្លើយដែលត្រឹមត្រូវ)៖

| | |
|---|---|
| ម្នាក់ឯង ☐ | ជាមួយដៃគូ ☐ |
| ជាមួយកូនៗ ☐ | ជាមួយមិត្តរួមការងារ ☐ |
| ជាមួយមិត្តភក្តិ ☐ | ជាផ្នែកមួយនៃក្រុមទេសចរណ៍ ☐ |

ផ្សេងទៀត ____________________

៧. តើអ្វីជាគោលបំណងចម្បងបំផុតនៃការធ្វើដំណើររបស់អ្នក (សូមជ្រើសយកចម្លើយតែមួយ)៖

| | |
|---|---|
| ធុរៈ/ការងារ ☐ | សួរសុខទុក្ខមិត្តភក្តិ និង/ឬគ្រួសារ ☐ |
| វិស្សមកាល/លំហែកាយ ☐ | ធ្វើការងារស្ម័គ្រចិត្ត ☐ |
| សិក្សា ☐ | ដើម្បីស្វែងរកការព្យាបាលផ្នែកវេជ្ជសាស្ត្រ ☐ |
| គោលបំណងផ្នែកសាសនា ☐ | |

ផ្សេងទៀត ____________________

៨. ក្នុងការធ្វើដំណើរលើកនេះ អ្នកស្នាក់អាស្រ័យ/នឹងស្នាក់អាស្រ័យភាគច្រើននៅក្នុង៖

| | |
|---|---|
| ផ្ទះសំណាក់ ☐ | រីសត ☐ |
| សណ្ឋាគារផ្កាយ ២-៣ ☐ | សណ្ឋាគារផ្កាយ ៤-៥ ☐ |
| កន្លែងស្នាក់សម្រាប់ backpacker ☐ | ស្នាក់នៅផ្ទះអ្នកភូមិ ☐ |
| ផ្ទះរបស់គ្រួសារ/មិត្តភក្តិ ☐ | |

ផ្សេងទៀត____________________

៩. តើអ្នកបានធ្វើអ្វីខ្លះ/នឹងធ្វើអ្វីខ្លះពេលអ្នកធ្វើដំណើរលើកនេះ? (សូមជ្រើសរើសចម្លើយទាំងអស់ដែលត្រូវ)

| | |
|---|---|
| ទៅលេងឆ្នេរសមុទ្រ ☐ | រៀនភាសា ☐ |
| ទៅទស្សនាទីតាំងវប្បធម៌/ប្រវត្តិសាស្ត្រ ☐ | ទៅលេងឧទ្យានជាតិ ☐ |
| ទៅលេងក្លិបរាត្រី ☐ | ថ្នាក់រៀនចម្អិនអាហារ ☐ |
| ទៅទិញទំនិញ ☐ | សកម្មភាពផ្សងព្រេង ☐ |

ផ្សេងទៀត ____________________
(ឧ. ការជ្រមុជទឹកជ្រៅ ការជិះស្គីលើទឹក ការជិះពោងទឹក)

១០.ក្រៅពីប្រទេសថៃ តើអ្នកនឹងធ្វើដំណើរ ឬបានធ្វើដំណើរទៅកន្លែងណាខ្លះទៀតក្នុងការធ្វើដំណើរលើកនេះ?
(សូមជ្រើសរើសចម្លើយទាំងអស់ដែលត្រូវ)
ប្រទេសកម្ពុជា ☐ ប្រទេសឡាវ ☐ ប្រទេសវៀតណាម ☐ ផ្សេងទៀត ____________________

១១.តើអ្នកនឹងធ្វើដំណើរក្នុងប្រទេសថៃ និង/ឬតំបន់អាស៊ីអាគ្នេយ៍ក្នុងរយៈពេល (សរុប) ប្រហែលប៉ុន្មាន?

| | | | | |
|---|---|---|---|---|
| < ១ សប្តាហ៍ ☐ | ១-២ សប្តាហ៍ ☐ | ២-៣ សប្តាហ៍ ☐ | ១ ខែ ☐ | ១-២ ខែ ☐ |
| ២-៣ ខែ ☐ | ៣-៦ ខែ ☐ | ៦-១២ ខែ ☐ | > ១ ឆ្នាំ ☐ | |

១២.តើអ្នកធ្លាប់បានមកទស្សនកិច្ចនៅប្រទេសថៃ ប្រទេសឡាវ ប្រទេសវៀតណាម ឬប្រទេសកម្ពុជាពីមុនមកទេ?

បាទ/ចាស ☐ ទេ ☐

ប្រសិនបើធ្លាប់នាពេលកន្លងមក តើអ្នកធ្លាប់មកកាន់ប្រទេសទាំងអស់នេះចំនួនប៉ុន្មានលើក?

| | | | | |
|---|---|---|---|---|
| ប្រទេសថៃ៖ | ១-២ លើក ☐ | ៣-៥ លើក ☐ | ៦-១០ លើក ☐ | លើសពី ១០ លើក ☐ |
| ប្រទេសកម្ពុជា៖ | ១-២ លើក ☐ | ៣-៥ លើក ☐ | ៦-១០ លើក ☐ | លើសពី ១០ លើក ☐ |
| ប្រទេសឡាវ៖ | ១-២ លើក ☐ | ៣-៥ លើក ☐ | ៦-១០ លើក ☐ | លើសពី ១០ លើក ☐ |
| ប្រទេសវៀតណាម៖ | ១-២ លើក ☐ | ៣-៥ លើក ☐ | ៦-១០ លើក ☐ | លើសពី ១០ លើក ☐ |

១៣.ជាមធ្យម តើអ្នកធ្វើដំណើរជាលក្ខណៈអន្តរជាតិញឹកញាប់កម្រិតណា?

| | |
|---|---|
| នេះគឺជាការធ្វើដំណើរកម្រិតអន្តរជាតិលើកទីមួយរបស់ខ្ញុំ ☐ | តិចជាងម្តងក្នុងមួយឆ្នាំ ☐ |
| ម្តងក្នុងមួយខែ ☐ | ២-៣ ដងក្នុងមួយឆ្នាំ ☐ |
| លើសពីម្តងក្នុងមួយខែ ☐ | ៤-៦ ដងក្នុងមួយឆ្នាំ ☐ |
| យ៉ាងតិចម្តងក្នុងមួយឆ្នាំ ☐ | ៧-១០ ដងក្នុងមួយឆ្នាំ ☐ |

## សូមប្រាប់ព័ត៌មានខ្លះបន្ថែមទៀតអំពីការរៀបចំផែនការសម្រាប់ការធ្វើដំណើរលើកនេះ៖

១៤.តើអ្នកបានស្រាវជ្រាវសម្រាប់ការធ្វើដំណើរនេះដោយរបៀបណា (សូមជ្រើសរើសចម្លើយទាំងអស់ដែលត្រូវ)៖

តាមអ៊ីនធើណេត ☐ គេហទំព័រមួយណា? ____________

ប្រើប្រាស់សៀវភៅមគ្គុទេសក៍ ☐ មួយណា? ____________

ជាមួយភ្នាក់ងារធ្វើដំណើរ ☐ មួយណា? ____________

អានខិត្តប័ណ្ណធ្វើដំណើរ ☐ មួយណា? ____________

តាមពាក្យសម្តីឮតាមគេ ☐

ផ្សេងទៀត ☐ សូមបញ្ជាក់៖ ____________

ខ្ញុំពុំបានធ្វើការស្រាវជ្រាវណាមួយមុនពេលមកកាន់ទីនេះឡើយ ☐

១៥. តើអ្នកកក់ការធ្វើដំណើររបស់អ្នកដោយរបៀបណា៖

តាមអ៊ីនធើណេត ☐

តាមភ្នាក់ងារធ្វើដំណើរ ☐

ផ្សេងទៀត ☐ សូមបញ្ជាក់៖ ____________

## សូមប្រាប់ព័ត៌មានខ្លះៗអំពីអ្វីដែលអ្នកដឹង ទាក់ទងនឹងសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

១៦.ក្រៅពីការស្ទាបស្ទង់មតិមួយនេះ កន្លងមកតើអ្នកធ្លាប់បានឮប្រយោគ "អ្នកធ្វើដំណើរដែលជួយរក្សាសុវត្ថិភាពកុមារ" ឬ "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" ឬទេ?

បាទ/ចាស ☐ ទេ ☐

ប្រសិនបើធ្លាប់ តើកន្លងមកអ្នកធ្លាប់ឮពាក្យទាំងនេះពីទីណា?

____________

១៧.តាមគំនិតអ្នក តើពាក្យ "អ្នកធ្វើដំណើរដែលជួយរក្សាសុវត្ថិភាពកុមារ" ឬ "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" មានន័យដូចម្តេច?

____________

១៨.តើអ្នកបានដឹង ឬទេថា កុមារមួយចំនួនគឺជាកម្មវត្ថុនៃការរំលោភបំពាន ឬការកេងប្រវ័ញ្ចផ្សារភ្ជាប់ជាមួយវិស័យទេសចរណ៍ និងការធ្វើដំណើរក្នុងតំបន់អាស៊ីអាគ្នេយ៍?

បាទ/ចាស ☐ ទេ ☐

ប្រសិនបើដឹង តើអ្នកបានដឹងអំពីរឿងនេះមុនពេលអ្នកមកកាន់តំបន់អាស៊ីអាគ្នេយ៍ ឬទេ?

បាទ/ចាស ☐ ទេ ☐

ប្រសិនបើដឹង តើអ្នកមានបានធ្វើការស្រាវជ្រាវ ឬទទួលព័ត៌មានណាមួយអំពីការរក្សាសុវត្ថិភាពកុមារក្នុងមូលដ្ឋានឲ្យរួចផុតពីការរំលោភបំពាន ឬការកេងប្រវ័ញ្ច មុនពេលអ្នកធ្វើដំណើរលើកនេះ ឬទេ?

បាទ/ចាស ☐ ទេ ☐

ប្រសិនបើបាន តើអ្នកធ្វើការស្រាវជ្រាវ/ទទួលព័ត៌មានទាំងនេះនៅទីណា/ដោយរបៀបណា?

____________

____________

១៩.ចាប់តាំងពីអ្នកបានមកដល់តំបន់នេះ តើអ្នកបានឃើញសម្ភារៈផ្សព្វផ្សាយពាណិជ្ជកម្មណាមួយ ស្តីពីការរក្សាសុវត្ថិភាពកុមារ ក្នុងមូលដ្ឋានពីការរំលោភបំពាន ឬការកេងប្រវ័ញ្ច ឬទេ ?

បាទ/ចាស ☐ ទេ ☐

ប្រសិនបើធ្លាប់ តើអ្នកឃើញសម្ភារៈផ្សព្វផ្សាយពាណិជ្ជកម្មទាំងអស់នេះនៅទីណា ហើយតើនោះជាអ្វី ?

______________________________

______________________________

២០.ពេលអ្នកធ្វើដំណើរ តើអ្នកបាន ( សូមគូសចម្លើយទាំងអស់ដែលត្រឹមត្រូវ ដោយកត់សម្គាល់ថា សម្រាប់គោលបំណងនៃការស្រាវជ្រាវ កុមារត្រូវបានកំណត់ថាជាមនុស្សដែលមានអាយុក្រោម ១៨ ឆ្នាំ )៖

ឲ្យលុយទៅកុមារសុំទាន ☐
ទិញទំនិញពីកុមារ ☐
ថតរូបជាមួយកុមារម្នាក់/ច្រើននាក់ ( មិនមែនជាកូនអ្នក/ផ្នែកនៃក្រុមធ្វើដំណើររបស់អ្នក ) ☐
ទៅទស្សនាមណ្ឌលកុមារកំព្រា ☐
ទៅទស្សនាតំបន់ “ប្រជុំជនក្រីក្រ” ☐
លេង/និយាយជាមួយកុមារក្នុងមូលដ្ឋាន ☐
ធ្វើការងារស្ម័គ្រចិត្តជាមួយកុមារក្នុងមូលដ្ឋាន ☐
បានឃើញកុមារដែលគ្មានមនុស្សធំមើលការខុសត្រូវនៅតាមចិញ្ចើមថ្នល់ ☐
ឃើញកុមារធ្វើការក្នុងគ្រឹះស្ថានទេសចរណ៍ ( ឧ. សណ្ឋាគារ តៀមកាហ្វេ ភោជនីយដ្ឋាន ) ☐
ឃើញកុមារធ្វើការនៅក្នុងគ្រឹះស្ថានកំសាន្តសប្បាយនាពេលយប់ ( ឧ. បារ ក្លិប ) ☐

២១.តើអ្នកមានអារម្មណ៍ដូចម្តេចចំពោះអន្តរកម្មជាមួយកុមារ និងមនុស្សវ័យក្មេងក្នុងមូលដ្ឋានទាំងអស់នេះ ?

______________________________

______________________________

២២. តើអ្នកធ្លាប់ឃើញ ឬបានដឹងអំពីករណីណាមួយស្តីពីការរំលោភបំពានលើកុមារពេលអ្នកនៅក្នុងតំបន់នេះ ឬទេ ?

បាទ/ចាស ☐ ទេ ☐

ប្រសិនបើធ្លាប់ តើអ្នកបានឃើញអ្វី ឬតើអ្នកត្រូវបានធ្វើឲ្យដឹងអំពីអ្វីខ្លះ ?

______________________________

______________________________

ប្រសិនបើធ្លាប់ តើអ្នកបានតឿនប្រាប់ទៅនរណាម្នាក់អំពីអ្វីដែលអ្នកបានឃើញ ឬទេ ?

បាទ/ចាស ☐ ទេ ☐

ប្រសិនបើធ្លាប់ តើអ្នកបានតឿនប្រាប់ទៅនរណា ហើយដោយវិធីណា ? ប្រសិនបើមិនធ្លាប់ទេ ហេតុអ្វីបានជាមិនធ្វើ ?

______________________________

______________________________

២៣.ក្នុងនាមជាអ្នកធ្វើដំណើរមកកាន់តំបន់អាស៊ីអាគ្នេយ៍ តើអ្នកគិតថាអ្នកត្រូវទទួលខុសត្រូវក្នុងការធ្វើសកម្មភាពដើម្បីការពារ□ កុមារ ងាយរងគ្រោះ ឬទេ ? ហេតុអ្វីបានជាអ្នកត្រូវទទួលខុសត្រូវ/ហេតុអ្វីបានជាអ្នកមិនត្រូវទទួលខុសត្រូវ ?

______________________________

______________________________

២៤ក្នុងនាមជាអ្នកធ្វើដំណើរមកកាន់តំបន់អាស៊ីអាគ្នេយ៍ តើអ្នកគិតថាអ្នកអាចធ្វើអ្វីបានខ្លះដើម្បីការពារកុមារ និងមនុស្សវ័យក្មេងងាយរងគ្រោះ ?

______________________________

______________________________

តើអ្នកមានយោបល់អ្វីបន្ថែម ឬទេ ?

______________________________

______________________________

## ឧបសម្ព័ន្ធទី ៣៖

# ប្រធានបទសម្រាប់ការសម្ភាសពាក់កណ្ដាលរចនាសម្ព័ន្ធ

**លក្ខណៈប្រជាសាស្ត្រ**

**ផ្លូវគោចរ និងផែនការការធ្វើដំណើរ ព្រមទាំងបែបបទនៃការធ្វើដំណើរ**

**បទពិសោធន៍ការធ្វើដំណើរកន្លងមក និងកត្តាជម្រុញទឹកចិត្តឲ្យធ្វើដំណើរ**

**ការយល់ដឹងអំពីសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍ និងទម្រង់ដទៃទៀតនៃការធ្វើដំណើរ "ប្រកបដោយការទទួលខុសត្រូវ"៖**

១. ក្រៅពីពាក់ព័ន្ធជាមួយការស្រាវជ្រាវនេះ តើកន្លងមកអ្នកធ្លាប់ឮប្រយោគ "អ្នកធ្វើដំណើរដែលជួយរក្សាសុវត្ថិភាពកុមារ" ឬ "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍" ឬទេ? ប្រសិនបើធ្លាប់ តើនៅកន្លែងណា?

២. តាមទស្សនៈរបស់អ្នក តើពាក្យ "អ្នកធ្វើដំណើរដែលរក្សាសុវត្ថិភាពកុមារ" ឬ "សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍មានន័យដូចម្ដេច?

៣. កន្លងមកតើអ្នកធ្លាប់ឮពាក្យ៖ ការធ្វើដំណើរប្រកបដោយការទទួលខុសត្រូវ/ប្រកបដោយសីលធម៌/ប្រកបដោយនិរន្តរភាព/អេកូទេសចរណ៍? តាមទស្សនៈរបស់អ្នក តើពាក្យទាំងនេះមានន័យដូចម្ដេច? តើគំនិតទាំងអស់នេះជះឥទ្ធិពលលើការធ្វើដំណើររបស់អ្នកដោយរបៀបណាមួយ ឬទេ?

**ការយល់ដឹងអំពីបញ្ហាការរំលោភបំពាន និងការកេងប្រវ័ញ្ចលើកុមារក្នុងតំបន់ទេសចរណ៍៖**

៤. តើអ្នកបានដឹង ឬទេថា កុមារមួយចំនួនគឺជាកម្មវត្ថុនៃការរំលោភបំពាន ឬកេងប្រវ័ញ្ច ផ្សារភ្ជាប់ជាមួយវិស័យទេសចរណ៍?

៥. ប្រសិនបើអ្នកដឹង តើអ្នកបានដឹងអំពីបញ្ហានេះមុនពេលអ្នកមកកាន់តំបន់អាស៊ីអាគ្នេយ៍ ឬទេ?

៦. ប្រសិនបើអ្នកបានដឹងមុន តើអ្នកបានធ្វើការស្រាវជ្រាវណាមួយ ឬតើអ្នកបានទទួលព័ត៌មានអំពីការរក្សាសុវត្ថិភាពកុមារក្នុងមូលដ្ឋានពីការរំលោភបំពាន ឬការកេងប្រវ័ញ្ចមុនពេលអ្នកចាកចេញពីប្រទេសរបស់អ្នក ឬទេ?

៧. តាំងពីអ្នកមកដល់តំបន់នេះ តើអ្នកធ្លាប់បានឃើញសម្ភារៈផ្សព្វផ្សាយពាណិជ្ជកម្មណាមួយស្ដីពីការរក្សាសុវត្ថិភាពកុមារក្នុងមូលដ្ឋានពីការរំលោភបំពាន ឬកេងប្រវ័ញ្ច ឬទេ? ប្រសិនបើធ្លាប់បានឃើញ តើអ្នកឃើញនៅទីណា ហើយនោះជាសម្ភារៈអ្វី?

៨. តើព័ត៌មាននេះបានជះឥទ្ធិពលលើការធ្វើដំណើររបស់អ្នកតាមវិធីណាមួយ ឬទេ?

**ការជួបជាមួយកុមារក្នុងមូលដ្ឋានក្នុងតំបន់ទេសចរណ៍ និងការឆ្លើយតប៖**

៩. តើអ្នកមានបានធ្វើអ្វីខ្លះ ជាមួយកុមារក្នុងមូលដ្ឋានក្នុងពេលធ្វើដំណើរនេះ (ឧ. ឲ្យលុយទៅកុមារសុំទាន ថតរូបជាមួយកុមារ។ល។)?

១០.តើអ្នកមានអារម្មណ៍ដូចម្ដេច ចំពោះទង្វើទាំងនេះ?

១១.តើអ្នកធ្លាប់បានឃើញ ឬធ្លាប់បានដឹងអំពីករណីនៃការកេងប្រវ័ញ្ចលើកុមារណាមួយពេលអ្នកនៅក្នុងតំបន់នេះ ឬទេ?

១២.ប្រសិនបើធ្លាប់ តើអ្នកបានតឿនប្រាប់ដល់នរណាម្នាក់អំពីអ្វីដែលអ្នកបានឃើញ ឬទេ? តើនរណា/ដោយរបៀបណា? ប្រសិនបើមិនបានតឿនប្រាប់ទេ តើហេតុអ្វីបានជាមិនធ្វើ?

១៣.តើអ្នកនឹងធ្វើដូចម្ដេចប្រសិនបើអ្នកឃើញកុមារសុំទាន?

១៤.តើអ្នកនឹងធ្វើដូចម្ដេចប្រសិនបើអ្នកឃើញកុមារលក់ឥវ៉ាន់នៅតាមផ្លូវ?

១៥.តើអ្នកនឹងធ្វើដូចម្ដេចប្រសិនបើអ្នកឃើញកុមារធ្វើការនៅទីកន្លែងទេសចរណ៍/អ្នកផ្ដល់សេវាដទៃទៀត?

**ឥរិយាបថចំពោះកុមារ៖**

១៦.តើអ្នកគិតថាអ្នកធ្វើដំណើរគួរធ្វើសកម្មភាពដើម្បីការពារកុមារងាយរងគ្រោះ ឬទេ? ហេតុអ្វី/ហេតុអ្វីក៏មិនត្រូវ?

១៧.ក្នុងនាមជាអ្នកធ្វើដំណើរមកកាន់តំបន់អាស៊ីអាគ្នេយ៍ តើសកម្មភាពអ្វីខ្លះដែលអ្នកនឹងធ្វើដើម្បីការពារកុមារងាយរងគ្រោះ

**ការឆ្លើយតបចំពោះសម្ភារៈយុទ្ធនាការសុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍៖**

១៨.ក្រោយពេលបានឃើញយុទ្ធនាការនេះ តើអ្នកមានគំនិតដូចម្ដេចដែរ?តើអ្នកចូលចិត្តរូបភាព និងការរចនាសម្ភារៈផ្សព្វផ្សាយពាណិជ្ជកម្មទាំងនេះឬទេ? ហេតុអ្វីបានជាចូលចិត្ត/ហេតុអ្វីបានជាមិនចូលចិត្ត? តើអ្នកគិតថាមានអ្វីខ្លះដែលអាចកែលម្អឲ្យកាន់តែប្រសើរជាងនេះថែមទៀត?

១៩.តើមានព័ត៌មានណាមួយក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មនេះដែលបានផ្លាស់ប្ដូរគំនិតរបស់អ្នកអំពីរបៀបដែលអ្នកគួរ/មិនគួរមានសកម្មភាព ជាមួយកុមារពេលអ្នកកំពុងធ្វើដំណើរ ឬទេ? ហេតុអ្វីបានជាមាន/ហេតុអ្វីបានជាមិនមាន?

២០.តើអ្នកមានអារម្មណ៍ថាការផ្សាយពាណិជ្ជកម្មនេះផ្ដល់ព័ត៌មានគ្រប់គ្រាន់ឲ្យអ្នកស្ដីពីរបៀបដើម្បីក្លាយជាអ្នកធ្វើដំណើរដែលជួយរក្សាសុវត្ថិភាពកុមារ ឬទេ?

២១ តើអ្នករំពឹងថានឹងឃើញយុទ្ធនាការនេះនៅទីណា? តើអ្នកនឹងចែករំលែកព័ត៌មាននេះជាមួយមិត្តភក្តិ ឬគ្រួសារដែលធ្វើដំណើរមកកាន់តំបន់នេះ ឬទេ? ហេតុអ្វីបានជាចែករំលែក/ហេតុអ្វីបានជាមិនចែករំលែក?



សុវត្ថិភាពកុមារក្នុងវិស័យទេសចរណ៍

ធ្វើសកម្មភាពប្រឆាំងការរំលោភបំពាន

www.childsafetourism.org

## អ្នកដំណើរដែលជួយរក្សាសុវត្ថិភាពកុមារ

ISBN: 978-0-9874441-8-9

រក្សាសិទ្ធិ © ឆ្នាំ ២០១៣ ដោយអង្គការទស្សនៈពិភពលោក

childsafetourism@wvi.org

Australian Aid · University of Western Sydney · World Vision